# ទស្សនាវដ្ដីព្រៃឈើ



សកម្មភាព និងលទ្ធផលការងារក្នុងឆមាសទី១ ឆ្នាំ២០១៩ របស់រដ្ឋបាលព្រៃឈើ

ដំណើរការនៃការគ្រប់គ្រងទីជម្រាលស្ទឹងព្រែកត្នោត ដោយមានការចូលរួម

គោលការណ៍អនុវត្តន៍ប្រកបដោយប្រសិទ្ធភាពខ្ពស់ដើម្បីស្តារលទ្ធភាព និងបន្លាស់ទីសត្វខោច

៦០

ឆមាសទី១

រដ្ឋបាលព្រៃឈើ

២០១៩

# មាតិកាអត្ថបទ

**ល.រ ឈ្មោះអត្ថបទ** **ទំព័រ**


១- សកម្មភាព និងលទ្ធផលការងារក្នុងឆមាសទី១ ឆ្នាំ២០១៩ របស់រដ្ឋបាលព្រៃឈើ ....... ១
២- ការគ្រប់គ្រងធនធានព្រៃឈើដោយនិរន្តរភាព គាំទ្រគោលដៅអភិវឌ្ឍដោយចីរភាព ....... ៤០
៣- ដំណើរការនៃការគ្រប់គ្រងទីជម្រាលស្ទឹងព្រែកត្នោត ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ ....... ៤៣
៤- របៀបបណ្តុះគ្រាប់ឫស្សី ....... ៤៨
៥- រុក្ខជាតិឱសថ "ខ្ទម្ព" ....... ៤៩
៦- គោលការណ៍អនុវត្តន៍ប្រកបដោយប្រសិទ្ធភាពខ្ពស់ដើម្បីស្តារលទ្ធភាព និងបន្លាស់ទីសត្វទោច ....... ៥០
៧- គោព្រៃ ....... ៥៨
៨- ពីនេះពីនោះ "វិធីសាស្រ្តក្នុងការយករួចខ្លួនពីការដេញប្រហារពីសត្វសាហាវទាំង១២ ដែលអ្នកគួរតែចងចាំ" ....... ៦២
៩- កម្សាន្ត ....... ៦៨
១០- កំណាព្យ "ស្តាយស្រណោះ" (តចប់) ....... ៦៩



យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ដែលបានជួយឧបត្ថម្ភ ផ្តល់នូវអត្ថបទ និងរូបភាពសម្រាប់ចុះផ្សាយក្នុងទស្សនាវដ្តីរបស់យើងខ្ញុំៗ ទន្ទឹមនឹងនេះ យើងខ្ញុំសូមអំពាវនាវដល់ប្រិយមិត្តអ្នកអានទាំងអស់ សូមមេត្តាជួយជ្រោមជ្រែង ផ្តល់នូវមតិរិះគន់ស្ថាបនា ផ្តល់អត្ថបទមានអត្ថប្រយោជន៍ផ្សេងៗដើម្បីចុះផ្សាយក្នុងទស្សនាវដ្តីជាបន្តបន្ទាប់ទៀតៗ *(ទំនាក់ទំនងព័ត៌មាន-ផ្តល់អត្ថបទ* **077 98 17 98***)*

*សូមអរគុណ !*

***រដ្ឋបាលព្រៃឈើ***





អគារលេខ ៤០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ (កម្ពុជា)
E-mail : tech6777@gmail.com
Website: www.forestry.gov.kh




# សកម្មភាព និងលទ្ធផលការងារ ក្នុងឆមាសទី១ ឆ្នាំ២០១៩ របស់រដ្ឋបាលព្រៃឈើ

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលបានកំណត់គោលដៅជាយុទ្ធសាស្ត្រក្នុងការកែទម្រង់វិស័យព្រៃឈើ គឺការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព រួមជាមួយប្រព័ន្ធការពារធនធានធម្មជាតិ និងការអនុវត្តកម្មវិធីអភិវឌ្ឍន៍សហគមន៍ព្រៃឈើប្រកបដោយប្រសិទ្ធភាពសំដៅចូលរួមអភិវឌ្ឍសេដ្ឋកិច្ច សង្គម កាត់បន្ថយភាពក្រីក្រ និងដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងការកើនឡើងកម្ដៅនៃភពផែនដី។

ដើម្បីសម្រេចបាននូវគោលដៅខាងលើ រដ្ឋបាលព្រៃឈើ ដែលជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ អង្គភាពពាក់ព័ន្ធ និងអង្គការអន្តរជាតិជាដៃគូអភិវឌ្ឍន៍នានា បំពេញតួនាទីភារកិច្ចទៅតាមអាណត្តិរបស់ខ្លួន ដោយសម្រេចបាននូវលទ្ធផលគួរឱ្យកត់សម្គាល់ដូចខាងក្រោម ៖

## ការពង្រឹងការអនុវត្តច្បាប់ស្ដីពីព្រៃឈើ

ក្នុងឆមាសទី១ ឆ្នាំ២០១៩នេះ រដ្ឋបាលព្រៃឈើគ្រប់លំដាប់ថ្នាក់ បានសហការជាមួយកងកម្លាំងប្រដាប់អាវុធ អាជ្ញាធរដែនដី និងព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត ក្នុងទូទាំងប្រទេសធ្វើការបង្ក្រាបបទល្មើសព្រៃឈើ-សត្វព្រៃ និងបទល្មើសកាប់រានដីព្រៃ ដោយទទួលបាននូវលទ្ធផលវិជ្ជមាន។

-សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន**៤១៦**ករណី ដែលក្នុងនោះសំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន**២២៧**ករណី និងសំណុំរឿងបទល្មើសព្រៃឈើដែលត្រូវបញ្ជូនទៅតុលាការ ចំនួន**១៨៩**ករណី។ ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមាន ឈើមូល-ជ្រុងសរុបចំនួន**១៣៨**ម៉ែត្រគ្រីគុណ ឈើអារសរុបចំនួន**១០១៨**ម៉ែត្រគ្រីគុណ គ្រាក់ក្រញូងចំនួន**២**ម៉ែត្រគ្រីគុណ សត្វព្រៃចម្រុះប្រភេទសរុបចំនួន**១៧៨៩**ក្បាល និង**២៣០**គីឡូក្រាម និងអនុផលព្រៃឈើព្រមទាំងឧបករណ៍សម្ភារផ្សេងៗមួយចំនួនទៀត។ សំណុំរឿងកាប់រានដីព្រៃចំនួន**២៩**ករណី ស្មើនឹងចំនួន**១២៤៦**ហិកតាត្រូវបានបញ្ជូនទៅតុលាការ។

- បានធ្វើបច្ចុប្បន្នភាពសំណុំរឿងបទល្មើសព្រៃឈើ និងសត្វព្រៃ តាមរយៈសាលក្រម និងដីកាសម្រេចរបស់សាលាដំបូងខេត្តព្រះវិហារចំនួន១៩ករណី និងបង់ពិន័យដោយតុលាការសរុបចំនួន០៩ករណី ក្នុងនោះមាន ខណ្ឌរដ្ឋបាលព្រៃឈើកំពង់ស្ពឺចំនួន០២ករណី កំពង់ចាមចំនួន ០១ករណី និងខណ្ឌរដ្ឋបាលព្រៃឈើក្រចេះចំនួន០៦ករណី។

- បានចុះពង្រឹងការអនុវត្តច្បាប់ចំនួន៤០លើក ក្នុងខេត្តចំនួន១៦ ក្នុងនោះខេត្តកំពង់ឆ្នាំង ចំនួន០៣លើក ខេត្តពោធិ៍សាត់ចំនួន០៣លើក ខេត្តកំពង់ស្ពឺចំនួន០២លើក ខេត្តតាកែវចំនួន០២លើក ខេត្តសៀមរាបចំនួន០៥លើក ខេត្តឧត្តរមានជ័យចំនួន០៥លើក ខេត្តកំពង់ធំចំនួន០៥លើក ខេត្តព្រះវិហារចំនួន០៥លើក ខេត្តប៉ៃលិនចំនួន០១លើក ខេត្តបន្ទាយមានជ័យចំនួន០៣លើក ខេត្តកោះកុងចំនួន ០១លើក ខេត្តព្រៃវែងចំនួន០១លើក ខេត្តស្វាយរៀង ចំនួន០១លើក ខេត្តរតនគិរីចំនួន០១លើក ខេត្តកំពត ចំនួន០១លើក និងខេត្តក្រចេះចំនួន០១លើក។



ការចាប់ឃាត់រថយន្តដឹកជញ្ជូនឈើអារប្រភេទលេខ៣ និងក្រៅលំដាប់ថ្នាក់ ដោយគ្មានលិខិតអនុញ្ញាត



ការចាប់ឃាត់ឈើអារលេខ១(ស្រឡៅ)ចំនួន០៥ដុំ នៅ ភូមិអូរអាម ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី



ចាប់ឃាត់ការដឹកជញ្ជូនឈើហ៊ុបជ្រុង(រាជកុល)ដោយគ្មាន លិខិតអនុញ្ញាត នៅ ភូមិក្បែត្របូរី ឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ



ការចាប់ឃាត់រថយន្តដឹកជញ្ជូនឈើដោយ គ្មានលិខិត អនុញ្ញាតនៅ ឃុំព្រៃស្វាយ ស្រុកមោងឫស្សី ខេត្តបាត់ដំបង



ចាប់ឃាត់រថយន្តដឹកឈើដែលគ្មានលិខិតអនុញ្ញាត



ការចាប់ឃាត់រថយន្តដឹកជញ្ជូនឈើអារ ប្រភេទលេខ១(ធ្នឹក)ដោយគ្មានលិខិតអនុញ្ញាត



ការចាប់ឃាត់រថយន្តដឹកជញ្ជូនផល អនុផលព្រៃឈើ
នៅភូមិចុងដូង ឃុំបាល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ



ការចាប់ឃាត់រថយន្តដឹកជញ្ជូនអុសចម្រុះ
ដោយគ្មានលិខិតអនុញ្ញាត



សកម្មភាពចាប់ឃាត់គោយន្តសណ្ដោងរ៉ឺម៉កចំនួន០១គ្រឿង
ដឹកជញ្ជូនកូនឈើចម្រុះប្រភេទល្មើសច្បាប់



ការចាប់ឃាត់គោយន្តកែច្នៃដឹកអុសខុសច្បាប់
នៅក្នុងស្រុកស្នួល ខេត្តក្រចេះ



សកម្មភាពប្រគល់-ទទួលវត្ថុតាងបទល្មើសព្រៃឈើ ស្ថិតក្នុង
ភូមិត្រពាំងផ្ទេរ ឃុំស្រែខ្ទម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី



ការធ្វើពាណិជ្ជកម្មសំណាកសត្វព្រៃខុសច្បាប់ នៅរាជធានីភ្នំពេញ

# ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើ និង សហគមន៍ព្រៃឈើ

## ១-ការវាយតម្លៃគម្របព្រៃឈើ និងទីជម្រាល

-បានចុះពិនិត្យផ្ទៀងផ្ទាត់គម្របព្រៃឈើឆ្នាំ២០១៨ នៅទីវាលជាក់ស្តែងចំនួន ២៧៧ចំណុច ក្នុងនោះខេត្តក្រចេះ ចំនួន ៩៣ចំណុច ខេត្តព្រះវិហារចំនួន ៥០ចំណុច ខេត្តស្ទឹងត្រែងចំនួន ៣៤ចំណុច ខេត្តរតនគិរីចំនួន ៥៣ ចំណុច និងខេត្តបាត់ដំបងចំនួន ៤៧ចំណុច

-បានចុះបណ្តុះបណ្តាល បង្កើនសមត្ថភាពបច្ចេកទេសប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS) និងប្រព័ន្ធកំណត់ទីតាំងលើផែនដី(GPS) ជូនមន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើកំពង់ស្ពឺ ត្បូងឃ្មុំ ប៉ៃលិន និងខេត្តបន្ទាយមានជ័យ ដែលមានមន្ត្រីចូលរួមសរុបចំនួន ៦៤រូប។





## ២-សហគមន៍ព្រៃឈើ

### ក-ការបង្កើត និងការគ្រប់គ្រងព្រៃសហគមន៍

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ១១កន្លែង ផ្ទៃដីសរុបទំហំ ៧ ៣៤៩ហិកតា ក្នុងនោះខេត្តកំពង់ធំចំនួន០១កន្លែង ផ្ទៃដីទំហំ១ ២៧៥ហិកតា និងខេត្តបាត់ដំបងចំនួន ១០កន្លែង ផ្ទៃដីទំហំ ៦ ០៧៤ហិកតា

-ចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ពីងប្រង់ក្លង់ប៉េសថូ ផ្ទៃដីទំហំ ១ ១០៤ហិកតា ស្ថិតក្នុងឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគីរី។

### ខ-ការរៀបចំ និងការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍

បានទទួលសេចក្តីយល់ព្រមជាគោលការណ៍ពីរដ្ឋបាលព្រៃឈើ លើផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន០៥កន្លែង លើផ្ទៃដីសរុបទំហំ៥០៥៧,២៧ហិកតាក្នុងនោះ ខេត្តកំពង់ធំចំនួន០២កន្លែង ផ្ទៃដីទំហំ១៤៣៥,៦៩ហិកតា និងខេត្តស្ទឹងត្រែង ចំនួន០៣កន្លែង ផ្ទៃដីទំហំ ៣ ៦២១,៥៨ហិកតា។

### គ-ការបង្កើនជីវភាព និងផ្តល់សេវាកម្មដល់ការអភិវឌ្ឍសហគមន៍ព្រៃឈើ

-បានចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដាំបន្លែ និងដំណាំឈើហូបផ្លែ ទស្សនទានកសិ-រុក្ខកម្ម បច្ចេកទេសដាំដំណាំកសិកម្ម ការរៀបចំដី កាធ្វើជីកំប៉ុស្តិ៍ ការគ្រប់គ្រង និងអនុវត្តការបែងចែកផលប្រយោជន៍ ព្រមទាំងបានចុះកំណត់ទីតាំងជាក់ស្តែងសម្រាប់អនុវត្តកសិ-រុក្ខកម្ម ដល់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើគោលដៅ ចំនួន ០៥សហគមន៍ ស្ថិតនៅស្រុកជុំគីរី និងស្រុកឈូក ខេត្តកំពត សម្រាប់ការអនុវត្តគម្រោងកសិ-រុក្ខកម្ម នៃគម្រោងលើកកម្ពស់ជីវភាពរស់នៅប្រជាពលរដ្ឋក្នុងសហគមន៍ព្រៃឈើ។

-បានចុះផ្សព្វផ្សាយពង្រឹងយន្តការដោះស្រាយទំនាស់ក្នុងសហគមន៍ព្រៃឈើចំនួន ០៨កន្លែង នៅក្នុងខេត្តចំនួន ០៤រួមមាន ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង មានអ្នកចូលរួមសរុបចំនួន ២០៨នាក់ (ស្ត្រីចំនួន ១១៥នាក់)

-បានចុះតាមដាន ត្រួតពិនិត្យការងារសហគមន៍ព្រៃឈើ ចំនួន១៨កន្លែង ក្នុងខេត្តចំនួន០៣ មានខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តពោធិ៍សាត់ អ្នកចូលរួមសរុបចំនួន៤៥០ នាក់ (ស្ត្រី៩២នាក់)

-បានចុះកំណត់ផ្ទៃដីព្រៃសហគមន៍ត្រូវដាំស្តារឡើងវិញ នៅក្នុងសហគមន៍ព្រៃឈើចំនួន ០៨កន្លែង ក្នុងខេត្តចំនួន ០៤ មានខេត្តពោធិ៍សាត់ បាត់ដំបង កំពង់ធំ និងខេត្តកំពង់ស្ពឺ។










## ៣-ការគ្រប់គ្រងផល អនុផលព្រៃឈើ

**ក-ការចុះបញ្ជិកា ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត និងយានយន្ត**

បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត ចំនួន ១៧គ្រឿង និងយានយន្តចំនួន ១២គ្រឿង។

**ខ-ការផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ**

បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូន ផល អនុផលព្រៃឈើ(LP) មានឈើហ៊ុបមូលចំនួន២៨ ៩៩៣ម៉ែត្រត្រីគុណ ឈើអារ ចំនួន៨៤៣ម៉ែត្រត្រីគុណ ឈើប្រណីត ចំនួន ១០៨ ម៉ែត្រត្រីគុណ ឈើជ្រុងចំនួន២ ៧៩០ម៉ែត្រត្រីគុណ កូនឈើ ចំនួន១២៤០៩២ដើម អុសចម្រុះ ចំនួន៣៨៧២៦ស្ទែរ ជន្លង់ម្រេចចំនួន ៤០៣ដើម សសរចំនួន ១១ដើម ធ្យូង ចំនួន១០ ៨៨០គីឡូក្រាម គល់បេងចំនួន ៤០៩គីឡូក្រាម និង ជ័រទឹកចំនួន ១៩២តោន។

**គ-ការធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើ**

បានធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើ និងបានរាយការណ៍ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន០២ក្រុមហ៊ុន គឺក្រុមហ៊ុន ឆាយណា ហ្រ្គេតខស(ខេមបូឌា) អ៊ិនវេសមេន នៅខេត្តព្រះវិហារ និងក្រុមហ៊ុន ណោង ណា អ៊ិនវេសមេន ឯ.ក នៅខេត្តមណ្ឌលគិរី។

# ការអភិវឌ្ឍចម្ការឈើដាំ និង រុក្ខវប្បកម្ម

នាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន ទទួលខុសត្រូវអនុវត្តនូវសកម្មភាពចំនួន០៥ធំៗក្នុងចង្កោមសកម្មភាព៤.១.២"ការអភិវឌ្ឍចម្ការឈើដាំ និងរុក្ខវប្បកម្ម" នៃអនុកម្មវិធី ៤.១ "ការគ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើ"។ សកម្មភាព និងលទ្ធផលដែលសម្រេចបាននៅក្នុងឆមាសទី១ ឆ្នាំ២០១៩នេះមានដូចតទៅ៖

## ១-ការងារគ្រប់គ្រងស្ថានីយដាំឈើ ថ្នាលបណ្ដុះកូនឈើ និងសួនឧទ្យាន

### ១.១-ការដាំឈើជាចម្ការថ្មី

គម្រោងដាំឈើជាចម្ការថ្មីក្នុងឆ្នាំ២០១៩លើផ្ទៃដីទំហំ ១៥២ហិកតា ត្រូវបានអនុវត្តនៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើអន្លង់ថ្ម ស្ថិតនៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ដោយបានឈូសឆាយដីទំហំ ១៥២ហិកតា បណ្ដុះកូនឈើបានចំនួន ១០១ ៥០០ដើម និងដាំកូនឈើជាចម្ការបានទំហំ០៤ហិកតា។





### ១.២-ការថែទាំចម្ការឈើចាស់ឆ្នាំទី១ ដល់ឆ្នាំទី៥

### ការថែទាំចម្ការឈើចាស់ និងចម្ការឈើរុក្ខទិវា

មន្ត្រីប្រចាំការនៅតាមស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើកំពុងថែទាំយ៉ាងយកចិត្តទុកដាក់តាមបទដ្ឋានបច្ចេកទេសនូវចម្ការឈើចាស់ ចម្ការពូជឈើ ឡូត៍បង្ហាញកសិរុក្ខកម្ម ទំហំ៩៨០ហិកតា នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើចំនួន ០៤ទីតាំង ស្ថិតនៅក្នុងខេត្តកំពង់ធំ សៀមរាប ព្រះសីហនុ ខេត្តស្វាយរៀង និងចម្ការរុក្ខទិវា ៩ កក្កដា សរុបចំនួន៥០ហិកតា ស្ថិតក្នុងខេត្តកំពត កណ្ដាល តាកែវ និងខេត្តកំពង់ធំ។



### ១.៣-ការប្រារព្ធពិធីរុក្ខទិវាថ្នាក់ជាតិ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការជាមួយអាជ្ញាធរខេត្តក្រចេះ រៀបចំប្រារព្ធពិធី "រុក្ខទិវា" ថ្នាក់ជាតិ ០៩ កក្កដា ឆ្នាំ២០១៩ ក្រោមព្រះរាជាធិបតីភាពដ៏

ខ្ពង់ខ្ពស់របស់ **ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ដែលប្រារព្ធនៅភូមិស្រែគ្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ ដោយបានដាំកូនឈើ សរុបចំនួន ១០ ៦១៧ដើម (កកោះ៣ ០៣០ដើម ធ្នង់២ ២៣០ដើម អង្កាញ់៤ ៣៨០ដើម គ្រញូង៤០០ដើម គគីរ៤០ដើម) លើផ្ទៃដីទំហំ១០ហិកតា និងបោះបង្គោលថ្មព័ទ្ធរបងលួស ចំនួន៣ជាន់ ប្រវែង ១ ៥០០ម៉ែត្រ។







## ១.៤-ការងារបណ្ដុះកូនឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋដាំអាស្រ័យផល

បានបណ្ដុះកូនឈើគ្រប់ប្រភេទចំនួន**៥២២ ៨៥២ដើម** និងប្រគេនកូនឈើដល់ព្រះសង្ឃ ប្រជាពលរដ្ឋបាន ចំនួន **៥៣ ៥៣៤ដើម** នៅថ្នាលបណ្ដុះកូនឈើតាមបណ្ដាខណ្ឌរដ្ឋបាលព្រៃឈើ រាជធានី ខេត្ត និងថ្នាលបណ្ដុះកូនឈើចំនួន៦កន្លែង ដែលទទួលថវិកាពីរដ្ឋបាលព្រៃឈើតាមរយៈនាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន។





## ១.៥-ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្នាលបណ្ដុះកូនឈើ

បានរៀបចំ និងសាងសង់ថ្នាលបណ្ដុះកូនឈើចំនួន ៣កន្លែងមានដូចជា៖ ថ្នាលបណ្ដុះកូនឈើ**សម្ដេច ហ៊ុន សែន** ភ្នំតាម៉ៅ ថ្នាលបណ្ដុះកូនឈើតាខ្មៅ និងថ្នាលបណ្ដុះកូនឈើខេត្តកំពង់ឆ្នាំង ដើម្បីបណ្ដុះកូនឈើចែកជូនប្រជាពលរដ្ឋឆ្នាំ២០១៩-២០២០ សម្រេចបានចំនួន៧០% (ឈូសឆាយ

ដីទំហំ១ហិកតា ថ្នាលមានគម្របស៊ែរទំហំ១០០០ម² ថ្នាលលំហមិនមានគម្របទំហំ២០០០ម² ប្រព័ន្ធស្រោចស្រពចំនួន ០១ឈុត រទេះរុញចំនួន០១គ្រឿង ម៉ូទ័រ និងក្លោងទ្វារ និងស្លាកឈ្មោះធ្វើអំពីដែកលាបថ្នាំ)។



**១.៦-ការងារជីកប្រឡាយការពារតំបន់ចម្ការឈើដាំគ្រញូងនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ**

ការជីកប្រឡាយការពារចម្ការឈើដាំគ្រញូងក្នុងឆ្នាំ ២០១៩ បានប្រវែងសរុប ៥ ៤៦៥ម៉ែត្រ នៃផែនការប្រវែង ៨ ០០០ម៉ែត្រ ក្នុងនោះស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ បានប្រវែង ២ ៤៦៥ម៉ែត្រ និងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើអូរថ្ម ខេត្តព្រះសីហនុ បានប្រវែង ៣ ០០០ម៉ែត្រ។



**១.៧-ចុះសិក្សាទីតាំងដីសម្រាប់បង្កើតស្ថានីយ និងចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ**

ក្រុមការងារនាយកដ្ឋានបានចុះពិនិត្យ និងតាមដានលទ្ធផលនៃការចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ នៅខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តកំពង់ឆ្នាំង៖

- ស្ថានីយក្បាលរមាស១ និងក្បាលរមាស២ កំពុងអនុវត្តនីតិវិធីចុះបញ្ជីដោយក្រុមការងារបានចូលរួមសហការជាមួយគណៈកម្មាធិការដីរដ្ឋគ្រប់គ្រងថ្នាក់ខេត្តចុះវាស់វែងទីវាលជាក់ស្តែង និងបោះបង្គោលព្រំកាត់ឆ្វៀលផ្ទៃដីផលប៉ះពាល់សម្រេចបានលទ្ធផលប្រមាណ៩៥% ក្នុងនោះបានធ្វើការកាត់ឆ្វៀលដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋចំនួន៤៩០ហិកតា ដើម្បីបញ្ចប់នីតិវិធីក្នុងការបោះបង្គោលព្រំបិទជិត រួចបន្តនីតិវិធីបិទប្រកាសផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យក្បាលដីក្នុងពេលដ៏ខ្លីខាងមុខនេះ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញលិខិតចាត់តំណាងនីតិបុគ្គលប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង ដើម្បីបំពេញទម្រង់បែបបទក្នុងការស្នើសុំចុះបញ្ជីដីទំហំ ២ ០០០ ហិកតា ដើម្បីបង្កើតសួនភូតគាម
- បានផ្តិតមេដៃទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចំនួន០៤សន្លឹក(លេខ:11020305-0001 លេខ:11020305-0002 លេខ:11020305-0003 និង លេខ:11020305-0004) មានផ្ទៃដីសរុប ទំហំ ៩ ១០០ហិកតា១៧៩៩ (ប្រាំបួនពាន់មួយរយហិកតា និងមួយពាន់ប្រាំពីររយកៅសិបប្រាំបួនម៉ែត្រការ៉េ)
- ក្រុមការងារបានចុះអង្កេត ស្រាវជ្រាវ ប្រមូលព័ត៌មាន និងឯកសារពាក់ព័ន្ធករណីសុំប្តឹងជំទាស់លើសេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យលើក្បាលដីចំនួន០២កន្លែងរបស់រដ្ឋបាលស្រុកអូររាំង ស្ថិតនៅក្នុងភូមិសាស្ត្រភូមិពូហ្យាម ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ដែលជាន់ជាមួយចម្ការឈើស្រល់ដែលបានដាំដោយរដ្ឋបាលព្រៃឈើ អគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និងចម្ការរុក្ខទិវាដោយបានប្រើប្រាស់ហិរញ្ញវត្ថុរបស់រដ្ឋ។

### ១.៨-សិក្ខាសាលាផ្សព្វផ្សាយពិគ្រោះយោបល់ស្តីពីការដាំឈើដល់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ

ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន បានរៀបចំផ្សព្វផ្សាយសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការដាំឈើដល់សហគមន៍មូលដ្ឋានចំនួន៦ ក្នុងខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ មានអ្នកចូលរួមសរុបចំនួន ២៥២នាក់(ស្រី១១៩នាក់) ចំពោះលទ្ធផលដែលទទួលបាន ប្រជាជននឹងយល់ច្បាស់ពីសារៈសំខាន់នៃការដាំឈើ ដើម្បីកែប្រែដីរេចរឹលរបស់ខ្លួនឲ្យក្លាយជាដីព្រៃផ្តល់ផល និងសម្បូរដោយធនធានព្រៃឈើសម្រាប់បម្រើឲ្យសេចក្តីត្រូវការក្នុងសហគមន៍។ ការដាំដុះព្រៃឈើសម្រាប់កិច្ចការពារបរិស្ថាន ទប់ស្កាត់ការហូរច្រោះ ជួយបង្កើនជីជាតិដី និងរក្សាលំនឹងបរិស្ថានសម្រាប់ប្រកបការងារកសិកម្ម។







## ២-ការអភិវឌ្ឍគ្រាប់ពូជឈើ និងធនធានសេនេទិច

### ២.១-ការបង្កើតចម្ការពូជឈើក្នុងស្រុក

ការបង្កើតចម្ការពូជឈើប្រភេទក្នុងស្រុក ១២ហិកតា បានជ្រើសរើសទីតាំងដីសួនអាពាហ៍ពិពាហ៍ វល្លិយាវ ស្ថិតនៅភូមិត្រពាំងចំបក់ ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បានធ្វើការឈូសគាស់គល់សម្អាតដី និងដាំកូនឈើទំហំ១២ហិកតា និងបានបេះប្រមូលគ្រាប់ពូជឈើដែលរងការគំរាមកំហែងក្នុងស្រុកបានទម្ងន់ ៣៣៥ គីឡូក្រាម (ធ្នង់១០០គីឡូក្រាម កកោះ៨៥គីឡូក្រាម ផ្ចិក១១០គីឡូក្រាម និងគគីរ៤០គីឡូក្រាម)។



### ២.២-ពិសោធន៍លើប្រភេទអ័រម៉ូនដើម្បីសាកល្បងបណ្តុះកូនឈើតាមរយៈការកាត់ត្រួយ (Clone Bank) កូនឈើអាកាស្យា និងប្រេងខ្យល់

សកម្មភាពការងារនៅថ្នាលបណ្តុះកូនឈើម្សៅក្រដាស ហ៊ុន សែន មានកនៅស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង រៀបចំពិសោធន៍ការងារកាត់ត្រួយអាកាស្យាបណ្តុះបាន

ចំនួន ២៨ ២០០ដើម ក្នុងនោះក្រុមការងារបានពិសោធន៍លើការប្រើប្រាស់អ័រម៉ូនចំនួនបីប្រភេទគឺអ័រម៉ូនទឹកប្រភេទ Vitamin B-1 (0-2-0) អ័រម៉ូនទឹកប្រភេទ Extra TONIC root និងអ័រម៉ូនម្សៅ Hormoril 0.8% និងបានតម្លើងឧបករណ៍តាមដានទិន្នន័យអាកាសធាតុស្វ័យប្រវត្តិ (Weather Station) ចំនួន២គ្រឿង ដែល១គ្រឿងតម្លើងនៅនាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំនិងព្រៃឯកជន និង១គ្រឿងទៀតនៅស្ថានីយផ្សព្វផ្សាយម្សៅក្រដាស ហ៊ុនសែន មានក ខេត្តកំពង់ឆ្នាំង។







**២.៣-លើកកម្ពស់ការយល់ដឹងអំពីបច្ចេកទេសផលិតកូនឈើ តាមរយៈការកាត់ត្រួយ (Clone Bank) កូនឈើអាកាស្យា និងប្រេងខ្យល់ដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ**

ក្រោយពីក្រុមការងារបានពិសោធន៍ការងារកាត់ត្រួយអាកាស្យាបណ្ដុះបានចំនួន ២៨ ២០០ដើម ក្នុងនោះក្រុមការងារបានពិសោធន៍លើការប្រើប្រាស់អ័រម៉ូនចំនួនបីប្រភេទគឺអ័រម៉ូនទឹកប្រភេទ Vitamin B-1 (0-2-0) អ័រម៉ូនទឹកប្រភេទ Extra TONIC root និងអ័រម៉ូនម្សៅ Hormoril 80% ទទួលបានជោគជ័យរួចមក ក្រុមការងារក៏បានធ្វើការផ្សព្វផ្សាយពីបច្ចេកទេសផលិតកូនឈើតាមរយៈការកាត់ត្រួយ (Clone Bank) កូនឈើអាកាស្យា និងប្រេងខ្យល់ នៅឃុំធ្លកវៀន ឃុំសេដ្ឋី ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដែលមានអ្នកចូលរួមសរុបចំនួន ១៣៨នាក់(ស្រី៤៧នាក់) ជាលទ្ធផលប្រជាជនបានទទួលនូវចំណេះដឹងអំពី បច្ចេកទេសផលិតកូនឈើអាកាស្យា និងប្រេងខ្យល់តាមរយៈការកាត់ត្រួយបណ្ដុះ ការជ្រើសរើសត្រួយ ការប្រើប្រាស់អ័រម៉ូន ការរៀបចំទុកដាក់កូនឈើ និងដាំកូនឈើដោយទទួលបានផលច្រើនរយៈពេលខ្លី បង្កើនសេដ្ឋកិច្ចក្នុងគ្រួសារ ការបណ្ដុះកូនឈើលក់ និងបង្កើនគម្របព្រៃឈើតាមរយៈការដាំឈើស្ដារព្រៃឈើឡើងវិញជាចម្ការរដ្ឋ និងដាំឈើជាចម្ការឯកជន។











## ៣-កសិ-រុក្ខកម្ម

### ៣.១-ការបង្កើតឡូត៍បង្ហាញកសិ-រុក្ខកម្ម

ការបង្កើតឡូត៍បង្ហាញកសិ-រុក្ខកម្មឆ្នាំ២០១៩ ទំហំ ១២ហិកតាបានអនុវត្តក្នុងសហគមន៍ព្រៃឈើចំបក់ហោះ ស្ថិតនៅស្រុករវៀង ខេត្តព្រះវិហារ និងបានឈូសឆាយដី ទំហំ ០៥ហិកតា និងបណ្ដុះកូនឈើប្រភេទគ្រញូង បេង និង ធ្នង់ ចំនួន២ ៧០០ដើម និងកូនស្វាយចន្ទីចំនួន២ ៥០០ដើម ចេក ចំនួន ១ ៣៥០ដើម និងកូនឈើសម្រាប់ដាំក្នុងឡូត៍បង្ហាញកសិ-រុក្ខកម្ម ឆ្នាំ២០១៩។

### ៣.២-ការលើកកម្ពស់ការយល់ដឹងពីការអនុវត្តបច្ចេកទេសកសិ-រុក្ខកម្មដល់សហគមន៍មូលដ្ឋាន

បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពីការលើកកម្ពស់ការយល់ដឹងពីការអនុវត្តបច្ចេកទេសកសិ-រុក្ខកម្ម ដល់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនៅសហគមន៍វាលអូរក្តី ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ដោយមានអ្នកចូលរួមសរុបចំនួន៥៤នាក់ និងសហគមន៍ភ្នំដែកចំបក់ហោះ ស្រុករវៀង ខេត្តព្រះវិហារ ដែលមានអ្នកចូលរួមសរុបចំនួន៥៤នាក់។ ជាលទ្ធផលអ្នកចូលរួមសរុបចំនួន១០៨នាក់ បានយល់ច្បាស់ពីការអនុវត្តប្រព័ន្ធកសិ-រុក្ខកម្ម ប្រភេទកសិ-រុក្ខកម្ម អត្ថប្រយោជន៍នៃមុខងារប្រព័ន្ធកសិ-រុក្ខកម្ម និងដំណើរការនៃការរៀបចំប្រព័ន្ធកសិ-រុក្ខកម្ម និងបានសិក្សាស្វែងយល់ពីការអនុវត្តប្រកបដោយជោគជ័យនៃគម្រោងប្រព័ន្ធកសិ-រុក្ខកម្ម នៅប្រទេសវៀតណាមភាគខាងជើង តាមរយៈការចាក់បញ្ចាំងវីដេអូ។





**៣.៣-ការធ្វើបច្ចុប្បន្នភាពស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ និងចម្ការប្រភពគ្រាប់ពូជ**

ក្រុមការងារបានចុះធ្វើបច្ចុប្បន្នភាពផ្ទៃដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចាស់ចំនួន០៣កន្លែងគឺស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើស្រល់ និងតាត្រាវ ស្ថិតនៅខេត្តកំពង់ធំ និងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើបឹងទូក និងជុំគិរី ស្ថិតនៅក្នុងខេត្តកំពត និងតំបន់ប្រភពគ្រាប់ពូជឈើនាងនួន ស្ថិតនៅក្នុងខេត្តព្រះវិហារ។





## ៤-ការគ្រប់គ្រងព្រៃឯកជន និងដៃគូសហការ

**៤.១-សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពីវិធានព្រៃឯកជន និងលិខិតបទដ្ឋានគតិយុត្តដល់វិស័យឯកជន សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ**

ក្រុមការងារបានចុះរៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពីវិធានព្រៃឯកជន និងលិខិតបទដ្ឋានគតិយុត្តដល់វិស័យឯកជន សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ នៅខេត្តកោះកុង កំពង់ស្ពឺ កំពត ខេត្តតាកែវ មានអ្នកចូលរួមសរុបចំនួន ១៧៣នាក់(ស្រី៤៩នាក់) មកពីសហគមន៍ព្រៃឈើព្រែកជីខលើ ខេត្តកោះកុង សហគមន៍ព្រៃឈើជ្រោះស្វាយ ខេត្តកំពង់ស្ពឺ សហគមន៍ព្រៃឈើព្រៃយ៉ាវ ខេត្តកំពត និងសហគមន៍ព្រៃឈើត្រពាំងធំ ខេត្តតាកែវ។ ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពី វិធានព្រៃឯកជននេះមានអត្ថប្រយោជន៍ក្នុងការចូលរួមស្តារគម្របព្រៃឈើឡើងវិញ ជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុជំរុញ និងលើកទឹកចិត្តដល់វិស័យឯកជនក្នុងការចូលរួមដាំឈើបង្កើតព្រៃឯកជន ដើម្បីបង្កើនសេដ្ឋកិច្ចគ្រួសារ តាមរយៈការផ្តល់សិទ្ធិប្រើប្រាស់ និងធ្វើអាជីវកម្មបាន។

**៤.២-ចុះត្រួតពិនិត្យការអនុវត្តការងារដាំឈើវិស័យឯកជន ក្រុមហ៊ុនដៃគូសហការ និង លក្ខណៈគ្រួសារ**

ការចុះត្រួតពិនិត្យ និងតាមដានការអនុវត្តការងារដាំឈើរបស់ក្រុមហ៊ុនឯកជននិងក្រុមហ៊ុនដៃគូសហការចំនួន ០២លើក លើក្រុមហ៊ុនដៃគូសហការចំនួន៥ និងដៃគូសហការជាលក្ខណៈគ្រួសារចំនួន២ នៅក្នុងខេត្តចំនួន០៤ រួមមាន៖១.ក្រុមហ៊ុនស៊ីង បាយអូថេក ខេមបូឌា ខូអិលធីឌី (THINK BIOTECH CAMBODIA ២.ក្រុមហ៊ុនសៀម៉ុន ខេមបូឌា អាហ្គ្រីខលឈ័រ ខំព្រីហែនស៊ីវ ឌីវើលុបមីន (SIEMON CAMBODIA AGRICULTURE COMPREHANSIVE DEVELOPMENT) ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ៣.ក្រុមហ៊ុនអ៊ិន ស៊ី ស៊ី ស៊ី អេហ្គ្រីខលឈ័រ (NCCC Agriculture) ស្ថិតនៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើក្បាលរមាស១ និងក្បាលរមាស២ ក្នុងឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង ៤.ក្រុមហ៊ុន វិជ្ជរី អ៊ីមផត អិចផត ស្ថិតនៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើរយ៉១ ឃុំរយ៉ ស្រុកកោះញែក ខេត្តមណ្ឌលគិរី ៥.ក្រុមហ៊ុន ណេង ណា អ៊ិនវេសមិន ស្ថិតនៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើរយ៉១ ឃុំរយ៉ ស្រុកកោះញែក ខេត្តមណ្ឌលគិរី ៦.អ្នកស្រី សូរ្យ ចន្ទ នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើស្ទួលទ្រេត ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ៧. លោកជំទាវ ចក់ ពូក នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើតាបែនឃុំតាបែន ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

## ៥-ការងារគ្រប់គ្រងរដ្ឋបាល និងសេវាគាំទ្រ

ក្រុមការងារនាយកដ្ឋានបានចុះអនុវត្តបេសកកម្ម បន្ទាន់ចំនួន២លើកក្នុងខេត្តចំនួន៣រួមមានៈ

ក-ចុះពិនិត្យករណីប្រជាពលរដ្ឋរំលោភកាន់កាប់ដីស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើតាបែន២ និងចុះអង្កេតផ្ទៀងផ្ទាត់ទីតាំងដីស្នើសុំវាស់វែងធ្វើប័ណ្ណកម្មសិទ្ធិរបស់ឈ្មោះ ញ៉ាន ស៊ីវង៉ែម នៅស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើស្ទួលទ្រេត ខេត្តបន្ទាយមានជ័យ មានៈ

-នៅស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើតាបែន២ មានការរំលោភកាន់កាប់ពីប្រជាពលរដ្ឋ ដោយធ្វើតាមការបំផុសបំផុលពីឈ្មោះ កើត ណូត ករណីនេះកើតឡើងដោយមូលហេតុមកពីភាគីដៃគូសហការ (លោកជំទាវ ចក់ ពូក) មិនបានដាំឈើបានទាន់ពេលវេលា និងបានយកដីស្ថានីយទៅជួលឲ្យប្រជាពលរដ្ឋដាំដំឡូង(មានទាំងជនខិលខូចកំពុងចាប់យកដីនៅតំបន់នោះផងដែរ)

-ការបង្ក្រាបជនខិលខូចចូលកាន់កាប់ដីស្ថានីយតាបែន២ អាចធ្វើទៅបានលុះត្រាតែមានការចូលរួមពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងមានការគាំទ្រពីស្ថាប័នតុលាការ

ខ-ចុះត្រួតពិនិត្យ និងវាយតម្លៃកូនឈើដែលបានឆេះក្នុងស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើចំនួន០២ ក្នុងខេត្តចំនួន០២ រួមមានៈ

-ស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើអូរបឹងរូង ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ករណីភ្លើងឆេះចម្ការដែលបង្កឡើងដោយមានជនខិលខូចលួចដុតចម្ការឈើដាំ បានបំផ្លាញកូនឈើអស់លើផ្ទៃដីទំហំ ៤៨.១២ហិកតា ក្នុងនោះចម្ការឆ្នាំ២០១៣(គ្រញូង) ចំនួន៤៣.០៥ហិកតា ចម្ការឆ្នាំ២០១៥(គ្រញូង,ធ្នង់)ចំនួន១.៥៣ហិកតា ចម្ការឆ្នាំ២០១៧(គ្រញូង)ចំនួន០២ហិកតា និងចម្ការកសិ-រុក្ខកម្មឆ្នាំ២០១៧ ចំនួន១.៥៤ហិកតា (គ្រញូង ធ្នង់ គគីរ ឈើទាល អាកាស្យា)។

-ស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើខ្នារងាស់ ខេត្តសៀមរាប ភ្លើងឆេះកណ្ដាលចម្ការដោយមិនដឹងមូលហេតុច្បាស់លាស់។

តាមការចុះពិនិត្យជាក់ស្ដែងរបស់ក្រុមការងារឃើញថា ចម្ការកូនឈើនៅស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើអូរបឹងរូង ឆ្នាំ២០១៣ផ្ទៃដីទំហំ៤៣.០៥ហិកតា(គ្រញូង) អាចមានលទ្ធភាពដុះដោយខ្នែងគល់ មែកប្រមាណ៨៥% ចម្ការឆ្នាំ២០១៥ទំហំ១.៥៣ហិកតា(គ្រញូង ធ្នង់)លទ្ធភាពដុះដោយខ្នែងគល់ មែក ៩០% និងចម្ការកសិ-រុក្ខកម្មឆ្នាំ២០១៧ចំនួន ១.៥៤ហិកតា កូនឈើអាចដុះវិញបានមានកូនគ្រញូង ធ្នង់ និងគគីរ ចំពោះកូនអាកាស្យា និងឈើទាលអាចបាត់បង់ទាំងស្រុង។ ចំពោះកូនឈើស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើខ្នារងាស់៨០% អាចដុះឡើងវិញតាមខ្នែងគល់ និងតាមមែកចាស់២%។

## ៦-សកម្មភាពចុះត្រួតពិនិត្យការប្រមូលផលឈើពីចម្ការរដ្ឋដោយក្រុមហ៊ុន HMM International Co., Ltd

ក្រុមការងាររដ្ឋបាលព្រៃឈើបានសហការជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋានចុះត្រួតពិនិត្យ តាមដាន វាស់វែង និងប្រគល់-ទទួលផលឈើពីចម្ការឈើដាំរបស់រដ្ឋ នៅខេត្តតាកែវ បានចំនួន ១ ៣៨៩ស្ទែរឧប០០៦ គិតជាទឹកប្រាក់ចំនួន ២៩ ១៦៩$១៣ បង់ចំណូលចូលថវិកាជាតិ។







យោងតាមស្មារតីអង្គប្រជុំនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ ស្ដីពីការពិនិត្យ និងពិភាក្សាលើកិច្ចសន្យាជំហាន ២ ការលក់ ទិញដើមអាកាស្យា និងប្រេងខ្យល់ពីចម្ការឈើរដ្ឋរបស់ក្រុមហ៊ុន HMM International Co.,Ltd ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជន បានសហការជាមួយខណ្ឌរដ្ឋបាលព្រៃឈើតាកែវ ចុះធ្វើសារពើភ័ណ្ឌ និងវាយតម្លៃធនធានព្រៃឈើ លើទីតាំងដីស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើត្រពាំងធំ និងស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើបន្ទាយអង្គរ ខេត្តតាកែវ ដើម្បីជាមូលដ្ឋានក្នុងការពិភាក្សារវាងគណៈកម្មការ និងក្រុមហ៊ុន HMM International Co.,Ltdក្នុងការប្រគល់-ទទួល ផលឈើដាំតាមរយៈវិធីសាស្ត្រសារពើភ័ណ្ឌ ពិភាក្សាលើកិច្ចសន្យាការទិញលក់ដើមឈើអាកាស្យា ប្រេងខ្យល់ជំហាន១។ ជាលទ្ធផល ក្រុមការងារបានធ្វើសារពើភ័ណ្ឌវាយតម្លៃធនធានព្រៃឈើ និងបានអនុវត្តតាមគោលការណ៍បច្ចេកទេសសារពើភ័ណ្ឌនៅស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើត្រពាំងធំ និងបន្ទាយអង្គរសរុបផ្ទៃដីចម្ការមានឈើទំហំ ៤៣៥ហិកតា១៨ និងមានមាឌឈើឈរចំនួន ២០ ៩៦២ ម៉ែត្រត្រីគុណ៣៨២ ស្មើនឹង៣១ ៤៤៣ស្ទែរវាយ៥៧៣ ស្មើនឹង១៤ ២៩២ស្ទែរឌុប៥៣៣ និងស្មើនឹង៣២ស្ទែរឌុប៨២ ក្នុង១ហិកតា៕





# ការងារផ្សព្វផ្សាយព្រៃឈើ-សត្វព្រៃ

### ការផលិតសម្ភារផ្សព្វផ្សាយព្រៃឈើ

ដើម្បីឆ្លើយតបទៅនឹងតម្រូវការផ្សព្វផ្សាយព្រៃឈើឲ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព ក្រុមការងារបានរៀបចំបោះពុម្ព និងចែកផ្សាយសម្ភារផ្សព្វផ្សាយព្រៃឈើដែលបានផលិតរួចជាបន្តបន្ទាប់ទៅតាមបណ្ដាអង្គភាព និងស្ថាប័នមួយចំនួន ដូចជាទស្សនាវដ្ដីព្រៃឈើលេខ លេខ៥៩ សៀវភៅកម្រងពិធី"រុក្ខទិវា" ៩ កក្កដា ឆ្នាំ២០១៨ សៀវភៅទិនានុលេខន៍ ២០១៩ រូបផ្ទាំង អាវយឺត មួកសម្រាប់ប្រារព្ធពិធី"រុក្ខទិវា" ៩ កក្កដា ២០១៩ ដែលមានអត្ថន័យ "ដាំដើមឈើផ្ដើមចេញពីអ្នក" និង " ខ្ញុំបានចូលរួមដាំដើមឈើ"។

### សកម្មភាពគ្រប់គ្រងបណ្ណាល័យ

បានថែរក្សា និងសម្អាតបណ្ណាល័យព្រៃឈើជាប្រចាំដើម្បីផ្ដល់ភាពងាយស្រួល និងផាសុខភាពដល់អ្នកស្រាវជ្រាវ និងអ្នកមានចំណាប់អារម្មណ៍មកសិក្សាស្វែងយល់ និងបានសម្របសម្រួលចែករំលែកព័ត៌មាន និងផ្ដល់ឯកសារពាក់ព័ន្ធវិស័យព្រៃឈើដល់ថ្នាក់ដឹកនាំ ដល់មន្ត្រីក្រោមឱវាទរដ្ឋបាលព្រៃឈើ និងអ្នកស្រាវជ្រាវនានាទៅតាមតម្រូវការផ្សេងៗ។

### សកម្មភាពផ្សព្វផ្សាយព្រៃឈើ

ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងវិស័យព្រៃឈើឱ្យកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព ក្រុមការងារផ្សព្វផ្សាយបានអនុវត្តការងារដូចខាងក្រោម៖

-បានបោះពុម្ព និងចែកផ្សាយឯកសារទស្សនាវដ្ដីព្រៃឈើលេខ៥៩ ចំនួន១.៥០០ក្បាល សៀវភៅកម្រងពិធី "រុក្ខទិវា" ៩ កក្កដា ឆ្នាំ២០១៨ សៀវភៅទិនានុលេខន៍ ២០១៩ ជូនដល់បណ្ដាអង្គភាពផ្សេងៗ និងក្នុងពិធី "រុក្ខទិវា" ៩ កក្កដា ឆ្នាំ២០១៩

-បានរៀបចំរូបភាពសម្រាប់បោះពុម្ពលើមួក និងលើអាវយឺតក្នុងពិធី"រុក្ខទិវា" ៩ កក្កដា ២០១៩

-បានបោះពុម្ពរូបភាពអប់រំផ្សព្វផ្សាយក្នុងវិស័យព្រៃឈើ ចំនួន ៥ប្រភេទ(ទំហំA4 ចំនួន ៤ ប្រភេទ និង A1 ចំនួន ១ប្រភេទ) សម្រាប់ចែកផ្សាយក្នុងពិធី"រុក្ខទិវា" ៩ កក្កដា ២០១៩ នៅខេត្តក្រចេះ

-បានចែកឯកសារវិស័យព្រៃឈើ មានដូចជា ទស្សនាវដ្ដីព្រៃឈើលេខ៥៨ ចំនួន៨០០ក្បាល ទិនានុលេខន៍ព្រៃឈើ ឆ្នាំ២០១៩ ចំនួន៨៦០ក្បាល និងរូបភាពអប់រំផ្សព្វផ្សាយក្នុងវិស័ព្រៃឈើទំហំA1 ចំនួន៣៥០០សន្លឹកដល់មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋានដែលបានមកចូលរួមសន្និបាតបូកសរុបការងារវិស័យព្រៃឈើឆ្នាំ២០១៨ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០១៩

-បានចុះរៀបចំកម្មវិធីបណ្ដុះបណ្ដាលលើកកម្ពស់ការយល់ដឹងអំពីគុណប្រយោជន៍ទូទៅនៃព្រៃឈើជាសាធារណៈ និងការងារបច្ចេកទេសបង្កើតព្រៃឈើឡើងវិញ បានចំនួន ០៤លើក ស្ថិតក្នុងខេត្តព្រះវិហារ សៀមរាប កំពង់ធំ ក្រចេះ ស្ទឹងត្រែង កំពត និងខេត្តកែប

-បានចូលរួម និងថតរូបបិទផ្សាយជាសាធារណៈនៅរដ្ឋបាលព្រៃឈើស្ដីពីសន្និបាតបូកសរុបការងារវិស័យព្រៃឈើឆ្នាំ២០១៨ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០១៩ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ២០១៩ និងពិធីទិវាអន្តរជាតិនារី៨មីនាឆ្នាំ២០១៩ ដែលប្រារព្ធធ្វើនៅរដ្ឋបាលព្រៃឈើ

-បានចូលរួមតាំងបង្ហាញសមិទ្ធផលព្រៃឈើ ក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័លឆ្នាំ២០១៩ ដែលបានប្រព្រឹត្តទៅនៅខេត្តតាកែវ

-បានប្រមូលសម្ភារៈ ឯកសារ និងរូបភាព ដើម្បីត្រៀមចូលរួមរៀបចំតាំងពិព័រណ៍បង្ហាញអំពីសមិទ្ធិផលព្រៃឈើក្នុងពិធី "រុក្ខទិវា" ៩ កក្កដា ឆ្នាំ២០១៩ ដែលនឹងប្រព្រឹត្តទៅនៅខេត្តក្រចេះ

-បានរៀបចំបង្កើតក្រុមការងារដើម្បីរៀបចំប្រមូលចងក្រង និងផលិតទស្សនាវដ្ដីព្រៃឈើ និងបានធ្វើការប្រជុំក្រុមការងារនាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ដោយបង្កើតក្រុមតេឡេក្រាមមួយដើម្បីជាមធ្យោបាយផ្ដល់ឯកសារ និងព័ត៌មានផ្សេងៗ





ពិព័រណ៍សមិទ្ធផលវិស័យព្រៃឈើក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល ឆ្នាំ២០១៩ នៅខេត្តតាកែវ

ការផ្សព្វផ្សាយ គឺជាសកម្មភាពមួយរួមចំណែកក្នុងការផ្ទេរចំណេះដឹង ព័ត៌មាន និងកសាងសមត្ថភាពក្នុងវិស័យព្រៃឈើដល់អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសប្រជាជនមូលដ្ឋានដែលមានលំនៅដ្ឋានក្បែរឬក្នុងតំបន់ព្រៃ និងអ្នកដែលអាស្រ័យផលព្រៃឈើទាំងអស់។ ម្យ៉ាងទៀតការងារនេះបានជួយសម្របសម្រួលផ្តល់នូវលទ្ធភាពងាយស្រួលក្នុងការស្វែងយល់នូវខ្លឹមសារនៃគោលនយោបាយក្នុងវិស័យព្រៃឈើ កម្មវិធីព្រៃឈើជាតិ និងបច្ចេកទេសនៃការងារអភិវឌ្ឍន៍ក្នុងវិស័យព្រៃឈើ តាមរយៈនៃការជួបប្រជុំ ការប្រើប្រាស់រូបត្ថុក និងសម្ភារងាយយល់ និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយច្រើនយ៉ាងរួមមាន ឯកជន និងរដ្ឋ មានដូចជា វិទ្យុ ទូរទស្សន៍ វីដេអូ កាសែត និងសារព័ត៌មានជាច្រើនទៀត។ល។ ការប្រើប្រាស់នូវគ្រប់មធ្យោបាយ និងវិធីសាស្ត្រផ្សព្វផ្សាយទាំងអស់ខាងលើ ដើម្បីធានាការប្រើប្រាស់ និងការគ្រប់គ្រងធនធានព្រៃឈើឱ្យមានរយៈពេលយូរអង្វែងនៅប្រទេសកម្ពុជា។ លើសពីនេះ ការងារផ្សព្វផ្សាយក៏បានចូលរួមផងដែរក្នុងការងារសិក្សាស្រាវជ្រាវបង្ហាញនូវរបកគំហើញថ្មីនៃបច្ចេកទេសសមស្រប និងមានប្រសិទ្ធភាពសម្រាប់មុខងារស្តារព្រៃឈើឡើងវិញនៅកម្ពុជា។



សកម្មភាពចូលរួមរៀបចំតាំងពិព័រណ៍សមិទ្ធផលព្រៃឈើក្នុង ព្រះរាជពិធីច្រត់ព្រះនង្គ័ល ឆ្នាំ២០១៩ នៅខេត្តតាកែវ



កិច្ចប្រជុំក្រុមការងារដើម្បីរៀបចំប្រមូល ចងក្រង និងផលិត ទស្សនាវដ្តីព្រៃឈើ នៅរដ្ឋបាលព្រៃឈើ



សកម្មភាពវគ្គបណ្ដុះបណ្ដាលលើកកម្ពស់ការយល់ដឹងអំពីគុណប្រយោជន៍ទូទៅនៃព្រៃឈើជាសាធារណៈ និងការងារបច្ចេកទេសបង្កើតព្រៃឈើឡើងវិញនៅស្រុកសំបូរ ខេត្តក្រចេះ



សកម្មភាពវគ្គបណ្ដុះបណ្ដាលលើកកម្ពស់ការយល់ដឹងអំពីគុណប្រយោជន៍ទូទៅនៃព្រៃឈើជាសាធារណៈ និងការងារបច្ចេកទេសបង្កើតព្រៃឈើឡើងវិញជាមួយសមាជិកសហគមន៍ព្រៃឈើកំពែង និងសហគមន៍ព្រៃឈើអូរស្រាវ នៅឃុំព្រងិល ស្រុកក្រវាញ ខេត្តពោធិ៍សាត់



សកម្មភាពវគ្គបណ្ដុះបណ្ដាលលើកកម្ពស់ការយល់ដឹងអំពីគុណប្រយោជន៍ទូទៅនៃព្រៃឈើជាសាធារណៈ និងការងារបច្ចេកទេសបង្កើតព្រៃឈើឡើងវិញនៅ ស្រុកថាឡាបរីវ៉ាត់ ខេត្តស្ទឹងត្រែង






រូបភាពដែលបានរចនាឡើងសម្រាប់បោះពុម្ពលើអាវយឺត(ឆ្វេង) និងមួក(ស្ដាំ)ប្រើក្នុងពិធី "រុក្ខទិវា" ៩ កក្កដា ២០១៩ ខេត្តក្រចេះ



ការចែករូបភាពអប់រំផ្សព្វផ្សាយបន្ថែមបន្ទាប់ពីបញ្ចប់វគ្គបណ្ដុះបណ្ដាលលើកកម្ពស់ការយល់ដឹងអំពីគុណប្រយោជន៍ទូទៅនៃព្រៃឈើជាសាធារណៈ និងការងារបច្ចេកទេសបង្កើតព្រៃឈើឡើងវិញ ស្ថិតក្នុងខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់

# ការងារស្រាវជ្រាវ និងពង្រឹងសមត្ថភាពក្នុងវិស័យព្រៃឈើ

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃរដ្ឋបាលព្រៃឈើ និង មានតួនាទីសំខាន់ក្នុងការពង្រឹងសមត្ថភាពក្នុងវិស័យព្រៃឈើ ព្រមទាំងការសិក្សាស្រាវជ្រាវនូវបច្ចេកទេសថ្មីៗសំដៅចូលរួមចំណែកក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ក្នុងឆ្នាំកន្លងទៅនេះ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ឯកឧត្តមប្រតិភូ បានខិតខំស្វែងរកដៃគូសហការឧបត្ថមថវិកាក្នុងការអនុវត្តគម្រោងពង្រឹងសមត្ថភាព និងគម្រោងស្រាវជ្រាវមួយចំនួនដែលក្នុងនេះភាគច្រើន គឺផ្តោតលើបច្ចេកទេសដាំស្តារព្រៃឈើរេចរឹល និងការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន។ ក្នុងឆមាសទី១ ឆ្នាំ២០១៩បានសម្រេចនូវលទ្ធផលការងារជាសង្ខេបដូចខាងក្រោម៖

## ១. គម្រោងផ្សព្វផ្សាយ និងពង្រឹងសមត្ថភាព

**ការងារបណ្តុះបណ្តាល**





វគ្គបណ្តុះបណ្តាលស្តីពី ការបញ្ជ្រាបយេនឌ័រ និង ការធ្វើសុវ៉ុឌ្ឍកម្មព្រៃឈើដល់សហគមន៍មូលដ្ឋាន

បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន០៥វគ្គ ស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពគម្រោង បច្ចេកទេសធ្វើរបោល ការធ្វើអនាម័យព្រៃ ការងារគ្រប់គ្រងស្តារព្រៃឈើឡើងវិញ ការអនុវត្តកសិ-រុក្ខកម្មទប់ស្កាត់ការហូរច្រោះដីកសិកម្មចម្រុះ ការគ្រប់គ្រងសារធាតុចិញ្ចឹម ការប្រែប្រួលអាកាសធាតុ ការផលិតផែនទី អេកូកសិកម្ម ការផ្សព្វផ្សាយពីផែនការដែលត្រូវអនុវត្តក្នុងការស្តារព្រៃឈើ និងការរៀបចំជួយបង្កើនជីវភាពរស់នៅរបស់ប្រជាជនក្នុងភូមិ ដែលមានអ្នកចូលរួមសរុបចំនួន ៤៣៦នាក់ (ស្ត្រី ១៨៨នាក់)។

## ២. ការស្រាវជ្រាវ និងបណ្តុះពូជឈើ

**ការងារពិសោធន៍ជាលិកាវប្បកម្ម៖**

-បានធ្វើពិសោធន៍ បណ្តុះជាលិកាវប្បកម្មកូនឈើ មានដូចជា សុក្រម នាងនួន ចំរៀក ចាន់ត្រី ត្របែកព្រៃ អង្កាញ់ ត្រាច គ្រញូង សរុបចំនួន ១.៩៦៥ដើម។

-បានធ្វើការពិសោធន៍រកអត្រាដំណុះគ្រាប់ពូជឈើ សុក្រម ចាន់ត្រី តាត្រាវ នាងនួន ត្របែកព្រៃ ចំរៀក និង អង្កាញ់ចំនួន ១.០០០គ្រាប់។





សកម្មភាពធ្វើប្រព្រឹត្តកម្ម និងបណ្តុះគ្រាប់ពូជឈើ



កូនឈើចំរៀក



កូនឈើគ្រញូង



កូនអង្គាញ់



កូនត្របែកព្រៃ



កូនចាន់ត្រី



កូនសុក្រម



កូននាងនួន



កូនច្រេស

## ៣. គម្រោងកិច្ចសហប្រតិបត្តិការ

ក្រៅពីការងារបណ្តុះបណ្តាលខាងលើ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ បាននឹងកំពុងអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានាដូចខាងក្រោម៖

**ក. គម្រោងច្រករបៀងអភិរក្សជីវចម្រុះមហាអនុតំបន់មេគង្គ(ខេត្តកោះកុង និងមណ្ឌលគិរី)**

-បានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន០១ នៅខេត្តមណ្ឌលគិរី ក្រោមអធិបតីភាព **ឯកឧត្តម វេង សាខុន** រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ

-បានចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តគម្រោង ផ្អែកលើកកម្ពស់ជីវភាពរស់នៅតាមរយៈការកម្ចីថវិកាបង្កើតមុខរបរលក់ដូរ ចិញ្ចឹមសត្វ នេសាទ កសិកម្ម ។ល។ របស់សមាជិកសហគមន៍ ដែលទទួលបានការគាំទ្រថវិកាគម្រោង នៅខេត្ត មណ្ឌលគិរី និងខេត្តកោះកុង

-បានធ្វើការតាក់តែងលម្អសួនច្បារ ដាំកូនឈើ ដាក់ប្រព័ន្ធលូ និងចាក់កម្មេចថ្ម រៀបដងទង់ជាតិ ធ្វើរបង ក្នុងបរិវេណស្ថានីយស្រាវជ្រាវព្រៃឈើជីខលើ ។





ទិដ្ឋភាពនៃស្ថានីយស្រាវជ្រាវព្រៃឈើជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង បន្ទាប់ពីការកែលម្អ



សកម្មភាពចុះកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើពីងប្រង់ក្លង់ពេសចូ នៅខេត្តមណ្ឌលគិរី ក្រោមអធិបតីភាព ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ខ. គម្រោងជំរុញការងារស្តារព្រៃឈើនៅកម្ពុជា-វៀតណាម តាមរយៈការបង្កើតឡូត៍បង្ហាញ និងការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធចែកចាយគ្រាប់ពូជឈើ**





សកម្មភាពស្តារប្រឡាយក្នុងចម្ការពូជឈើច្រេស ថែទាំកូនឈើ និងធ្វើជើងកូនឈើក្នុងឡូត៍បង្ហាញស្តារព្រៃឈើដាំដោយគ្រាប់

-តាមដានការលូតលាស់របស់ដំណុះឈើ ការងារថែទាំកូនឈើមានដូចជា ការជួសជុលផ្លូវភ្លើង ប្រឡាយទឹក កាត់សម្អាត និងបាញ់ថ្នាំស្មៅ ព្រមទាំងការងារធ្វើជើងកូនឈើ ការធ្វើឲ្យរហាល និងការដាំជួស

-ស្តារប្រឡាយក្នុងចម្ការពូជឈើច្រេស ថែទាំកូនឈើ និងធ្វើជើងកូនឈើក្នុងឡូត៍បង្ហាញស្តារព្រៃឈើដាំដោយគ្រាប់។





ទិដ្ឋភាពចម្ការពូជឈើតាត្រាវបន្ទាប់ពីកាត់សម្អាតស្មៅ និងការធ្វើប្រព្រឹត្តកម្មដំណុះគ្រាប់សុក្រម

**គ. គម្រោងរៀបចំផែនការគ្រប់គ្រងព្រៃឈើនៅក្នុងតំបន់ទីជម្រាលស្ទឹងព្រែកត្នោតផ្អែកលើផែនទេសភាព**

-បានសម្របសម្រួលដំណើរចុះទស្សនកិច្ចនិស្សិតមហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម សរុបចំនួន ៣៤នាក់ (ស្ត្រី ១០នាក់) នៅតំបន់អនុវត្តន៍គម្រោង

-បណ្តុះបណ្តាលសហគមន៍មូលដ្ឋានស្តីពីការថែរក្សាជីជាតិដី នៅឃុំត្រពាំងជោរ ចំនួន ១៥នាក់ (ស្ត្រី ០៥នាក់) និងឃុំក្រាំងដីវ៉ាយ ចំនួន ១២នាក់ (ស្ត្រី ០៣នាក់)

-បានរៀបចំសិក្ខាសាលាបញ្ចប់គម្រោង ដែលមានអ្នកចូលរួមចំនួនសរុប ៨២នាក់ (ស្ត្រី០៩នាក់)។





សកម្មភាពទស្សនកិច្ចរបស់និស្សិតមហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ នៅឃុំត្រពាំងជោរ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ





សកម្មភាពបង្ហាញសហគមន៍មូលដ្ឋានស្តីពីការពិសោធន៍ pH ដី






ទិដ្ឋភាពនៃសិក្ខាសាលាបញ្ចប់គម្រោងរៀបចំផែនការគ្រប់គ្រងព្រៃឈើនៅក្នុងតំបន់ទីជម្រាលស្ទឹងព្រែកត្នោតផ្អែកលើផែនទេសភាព

**ឃ. គម្រោងបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវសេនេទិចព្រៃឈើសម្រាប់ស្តារប្រភេទឈើសំខាន់ៗនៅកម្ពុជា**

- បានធ្វើការភ្ជួរដីសម្អាតស្មៅតាមចន្លោះរង និងជុំវិញគល់កូនឈើ លាបកំបោរសកំចាត់សត្វល្អិត(ខ្មូង) ស៊ីគល់ និងធ្វើផ្លូវភ្លើងដើម្បីទប់ស្កាត់ការរាលដាលភ្លើងឆេះដល់ឡូត៍ពិសោធន៍

- តាមដានការលូតលាស់នេះ ប្រព្រឹត្តទៅរៀងរាល់ ០៦ខែម្តង ដោយធ្វើការកត់ត្រាទិន្នន័យលូតលាស់របស់អង្កត់ផ្ចិត កម្ពស់ កន្សោមស្លឹក និងចំនួនមែករបស់កូនឈើ

-គម្រោងបានផ្តល់បច្ចេកទេសដល់និស្សិតមកពីមហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ នៃសកលវិទ្យាល័យភូមិន្ទកសិកម្មចំនួន០៣រូប ក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

- ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើ និស្សិតនៃសកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាលាជាតិកសិកម្មព្រែកលៀប និងអ្នកស្រាវជ្រាវអន្តរជាតិមួយចំនួនទៀតដែលអញ្ជើញមក

ពីប្រទេសចិន កូរ៉េ អូស្ត្រាលី ឡាវ មីយ៉ាន់ម៉ា ថៃឡង់ វៀតណាម និងកាណាដា បានពិនិត្យឡូត៍ពិសោធន៍ជម្រើសដើមពូជនៅស្រុកបន្ទាយស្រី ខេត្តសៀមរាប។

- ក្រុមការងារបានបញ្ជូនមន្ត្រីរដ្ឋបាលព្រៃឈើដែលកំពុងអនុវត្តគម្រោង ចំនួន០៤រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលចាប់ពីថ្ងៃទី២៤ខែកុម្ភៈ ដល់ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៩ នៅសាធារណៈរដ្ឋកូរ៉េ

-ក្រុមការងារបានសហការណ៍ជាមួយសាស្ត្រាចារ្យ និង និស្សិតអញ្ជើញមកពីសកលវិទ្យាល័យជាតិសេអ៊ូល (SNU) នៃសាធារណៈរដ្ឋកូរ៉េ ក្នុងការប្រមូលសំណាកស្លឹកធ្នង់ពីដើមមេ ចំនួន១០០ដើម ក្នុងចម្ការពូជឈើនៃទីតាំងគម្រោងទី២ ស្ថិតនៅភូមិគោកទឹង ឃុំចាន់ស ស្រុកសូទ្រនិគម ខេត្តសៀមរាប ដើម្បីធ្វើការសិក្សាពីការប្រែប្រួលសេនេទិចរបស់កូនជំនាន់ក្រោយ។





សកម្មភាពប្រមូលទិន្នន័យលូតលាស់របស់កូនឈើក្នុងឡូត៍ពិសោធន៍ និងបទបង្ហាញពីគម្រោងស្រាវជ្រាវរបស់និស្សិត





សកម្មភាពភ្ជួរ និងកាត់សម្អាតស្មៅតាមចន្លោះរងកូនឈើ





សកម្មភាពប្រមូលសំណាកស្លឹកធ្នង់ពីដើមមេចំនួន១០០ដើម សម្រាប់ធ្វើការវិភាគពីតំណសេនេទិច



សកម្មភាពឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ចុះពិនិត្យឡូត៍ពិសោធន៍ជម្រើសដើមពូជ



សកម្មភាពវគ្គបណ្តុះបណ្តាលមន្ត្រីរដ្ឋបាលព្រៃឈើ០៤រូប នៅសាធារណៈរដ្ឋកូរ៉េស្តីពីការបង្កាត់ពូជឈើ

**ង.គម្រោងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព តាមរយៈយន្តការរេដបូក នៅខេត្តកំពង់ធំ**

-បានផ្តល់ជូននូវចង្ក្រានសន្សំសំចៃថាមពល ចំនួន ២.១៥០ចង្ក្រាន ដល់ប្រជាពលរដ្ឋក្នុងសហគមន៍គោលដៅទាំងបីក្នុងនោះមានសហគមន៍ព្រៃឈើវាលអូរក្តី សហគមន៍ព្រៃឈើក្បាលអូរក្រយ៉ាក និងសហគមន៍ព្រៃឈើក្បាលខ្លាស្ថិតក្នុងស្រុកសន្ទុក និងស្រុកសណ្តាន់ ខេត្តកំពង់ធំ

-ផ្តល់ជូនអាងស្តុកទឹកស្អាតសម្រាប់ប្រើប្រាស់នៅភូមិដោយបំពាក់ម៉ូទ័រប៉ូមទឹកដើរដោយស្វ័យប្រវត្តិ និងប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យផ្តល់ជូនអាងជីកំប៉ុស្តិ៍ និងកូនមាន់សម្រាប់ធ្វើពូជដល់កសិករគម្រូក្នុងសហគមន៍ទាំងបីផងដែរ

-បានដឹកនាំកសិករចំនួន២៥រូប ទៅទស្សនកិច្ច និងផ្លាស់ប្តូរបទពិសោធន៍ ស្តីពី ការពង្រឹងជីវភាពប្រជាជនពីរបៀបចិញ្ចឹមមាន់ និងបណ្តុះផ្សិតនៅភូមិជ័យមង្គល ឃុំជ្រាប់ ស្រុកសន្ទុក និងកសិករដាំបន្លែ នៅភូមិស្នោរ ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។





សកម្មភាពចែកចង្ក្រានសន្សំសំចៃថាមពលដល់ពលរដ្ឋ ក្នុងស្រុកសន្ទុក និងសណ្តាន់ ខេត្តកំពង់ធំ





សកម្មភាពដំឡើងអាងស្តុកទឹកស្អាតដោយបំពាក់ម៉ូទ័រប៉ូមទឹកដើរដោយស្វ័យប្រវត្តិ និងប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ

**ច. គម្រោងសមាហរណកម្មផែនការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីព្រៃឈើ និងការធ្វើគម្រោងបង្ហាញ ស្តីពីការស្តារព្រៃឈើនៅក្នុងមហាអនុតំបន់មេគង្គ**

-បានរៀបចំកិច្ចប្រជុំឆ្លងលក្ខន្តិកក្រុមប្រើប្រាស់ទឹកសម្រាប់ស្រោចស្រពដំណាំ និងប្រើប្រាស់ជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ និងសមាជិកសហគមន៍ព្រៃឈើដំរីចាក់ធ្លក ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

-បានបង្កើតឡូត៍កសិរុក្ខកម្មទំហំ០១ហិកតា និងឈើហូបផ្លែរួមមាន ស្វាយចន្ទី ក្រូចថ្លុង Mecademia និងឫស្សីផ្អែមសរុបចំនួន៥៨៤ដើម និងដំណាំរយៈពេលខ្លីមានដូចជា ពោត ឪឡឹក សណ្តែកគួរ សណ្តែកដី សណ្តែកបាយ ល្ពៅ ត្រប់ ត្រគួន រំដេង ត្រសក់។ល។

-បានតភ្លើងចូលសម្រាប់ដាក់ម៉ូទ័របូមទឹកចំនួន០២គ្រឿង ដំឡើងស៊ីតែនទឹកដែលផ្ទុកចំណុះ១.០០០លីត្រ







សកម្មភាពបង្ហាញពីរបៀបធ្វើជីកំប៉ុស៏ រងដំណាំ និងផ្តល់ជូនកូនមាន់សម្រាប់ធ្វើពូជ





សកម្មភាពទស្សនកិច្ចសិក្សារបស់កសិករអំពីរបៀបបណ្តុះផ្សិត



សកម្មភាពប្រជុំឆ្លងលក្ខន្តិកៈក្រុមប្រើប្រាស់ទឹក និងការលើកដីទប់ស្កាត់ការហូរច្រោះដី និងដាំកូនឈើជុំវិញអាងស្តុកទឹក

-បានតបណ្តាញទុយោមេ (១០ស.មX២.៥០០ម) ចូលភូមិ និងសង់អាងស្តុកទឹកចំណុះ៥.០០០លីត្រ សម្រាប់ចែកចាយទៅតាមលំនៅដ្ឋានប្រើប្រាស់សរុបចំនួន៧៤គ្រួសារ។







ការរៀបចំសួនបន្លែលំនៅដ្ឋានដល់សមាជិកសហគមន៍ព្រៃឈើដំរីចាក់ធ្លក





ការបង្ហាញពីរបៀបសម្អាតស្មៅ ជ្រួយដី ដាក់ជី ថែទាំ និងដាំជួសកូនឈើក្នុងឡូត៍ស្តារព្រៃឈើឡើងវិញ

**ឆ. គម្រោងស្តារដីរេចរឹល និងធ្វើឲ្យប្រសើរឡើងវិញនូវជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋានតាមរយៈការធ្វើកសិកម្មចម្រុះ**

-បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើ និងសហគមន៍លើវិស័យកសិកម្មចម្រុះ ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងសារធាតុចិញ្ចឹម និងអេកូកសិកម្ម មានចំនួន៤វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ១១៣នាក់(ស្រី៣៥នាក់)

- បានឈូសឆាយដី សម្រាប់អនុវត្តការដាំដុះដំណាំបន្លែ ការសាងសង់រោងជីកំប៉ុស និងជីកស្រះ

-បានសាងសង់ឡជីវឧស្ម័ន និងរៀបចំប្រព័ន្ធស្រោចស្រពដំណាំ។









ទិដ្ឋភាពវគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើ និងសហគមន៍លើវិស័យ
កសិកម្មចម្រុះ ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងសារធាតុចិញ្ចឹម និងអេកូកសិកម្ម





សកម្មភាពរៀបចំដីសម្រាប់អនុវត្តការដាំដុះដំណាំ





សកម្មភាពស្ទូងកូនបន្លែ និងដាំបន្លែសម្រាប់គ្រួសារកសិករ



សកម្មភាពសាងសង់ឡជីវឧស្ម័នសម្រាប់គ្រួសារកសិករគំរូ

**ជ.ការសិក្សាស្រាវជ្រាវអំពីការផលិតថង់បណ្ដុះកូនឈើដែលផ្ទុកសារធាតុចិញ្ចឹម និងរលួយបានដោយធម្មជាតិ**

-បានផលិតថង់បណ្ដុះកូនឈើដែលផ្ទុកសារធាតុចិញ្ចឹម និងរលួយបានដោយធម្មជាតិដែលមាន៣ប្រភេទ គឺ ថង់ដែលរលួយក្នុងរយៈពេលខ្លី(ក្រោម៨ខែ) ថង់រលួយរយៈពេលមធ្យម(១៥ខែ) និងថង់រលួយរយៈពេលវែង(៣ឆ្នាំ)

-បានដាំកូនឈើនៅក្នុងថង់ផ្ទុកសារធាតុចិញ្ចឹម និងរលួយបានដោយធម្មជាតិ ដើម្បីតាមដានអំពីការលូតលាស់របស់កូនឈើ និងបម្រែបម្រួលរបស់ថង់បណ្ដុះកូនឈើប្រភេទនេះក្នុងរយៈពេល៣ខែ។





រូបភាពការបង្កើតសូលុយស្យុង និងបន្ទះថង់បណ្ដុះ

# ការការពារ និងអភិរក្សសត្វព្រៃ

## ការអភិរក្សសត្វព្រៃ និងជីវចម្រុះ

### ១-ពង្រឹងការថែរក្សាសត្វព្រៃក្នុងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍

**ក-ការអន្តរាគមន៍សត្វព្រៃតាមបណ្ដាខេត្ត-ក្រុង**

បានសហការជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋានចុះអន្តរាគមន៍ទប់ស្កាត់ និងបង្ក្រាបការជួញដូរសត្វព្រៃនៅខេត្តមណ្ឌលគិរី រតនគិរី ស្ទឹងត្រែង កំពង់ធំ និងខេត្តព្រះវិហារ ដោយរឹបអូសបានសាច់សត្វជ្រូកព្រៃចំនួន ៤៩គ.ក សាច់សត្វឈ្លូសចំនួន ១២គ.ក សត្វអន្សងរស់ ចំនួន០២ក្បាល សត្វក្រកួតរស់ចំនួន០២ក្បាល វណារយន្តចំនួន០២គ្រឿង និងប្រទះឃើញជ្រូកព្រៃងាប់ជាប់អន្ទាក់ចំនួន០១ក្បាល។



*សកម្មភាពដោះលែងសត្វក្រកួតដែលរឹបអូសបានពីជនល្មើសចូលក្នុងព្រៃធម្មជាតិវិញ*





*សកម្មភាពការដុតកម្ទេចវត្ថុតាងសាច់សត្វជ្រូកព្រៃដែលរឹបអូសបានពីជនល្មើស*



*ការចូលរួមរបស់មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងសហគមន៍ក្នុងការអន្តរាគមន៍បទល្មើសសត្វព្រៃ*

**ខ-ការផ្សព្វផ្សាយស្ដីពីការទប់ស្កាត់ការជួញដូរសត្វព្រៃ និងសារសំខាន់សត្វព្រៃ**

បានសហការជាមួយនឹងរដ្ឋបាលព្រៃឈើមូលដ្ឋានចុះធ្វើការផ្សព្វផ្សាយស្ដីពីការទប់ស្កាត់ការជួញដូរសត្វព្រៃ និងសារសំខាន់សត្វព្រៃ នៅខេត្តមណ្ឌលគិរី កំពង់ធំ និងខេត្តពោធិ៍សាត់ ដោយមានប្រជាជនចូលរួមសរុបចំនួន ៣០០នាក់(ស្រី១៩១នាក់) ចែកជូនផ្ទាំងរូបភាពអប់រំចំនួន ៣០០សន្លឹក និងអាវយឺតចំនួន២០០អាវ។





សកម្មភាពនៃការចុះអប់រំផ្សព្វផ្សាយទប់ស្កាត់ ការជួញដូរសត្វព្រៃ និងសារសំខាន់ព្រៃឈើ



សកម្មភាពនៃការចុះចែកអាវយឺត និងផ្ទាំងរូបភាព សត្វព្រៃដល់ប្រជាជនមូលដ្ឋានចូលរួមការផ្សព្វផ្សាយ

**គ-ការសិក្សាស្រាវជ្រាវ និងកំណត់តំបន់ព្រៃឈើដែលមានសក្តានុពលសម្រាប់ទេសចរណ៍ធម្មជាតិ**

បានចុះសិក្សាព្រៃសហគមន៍ប្រាំបីមុំដែលមានទីតាំងស្ថិតនៅក្នុងឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដើម្បីកំណត់តំបន់ព្រៃឈើដែលមានសក្តានុពលសម្រាប់ធ្វើជាតំបន់ទេសចរណ៍ធម្មជាតិ ។









សកម្មភាពនៃការសិក្សាស្រាវជ្រាវ និងកំណត់តំបន់ព្រៃឈើដែលមានសក្តានុពលសម្រាប់ទេសចរណ៍ធម្មជាតិ ក្នុងសហគមន៍ប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ

## ២-ការសិក្សាស្រាវជ្រាវ និងតាមដានវត្តមានសត្វព្រៃ និងជីវចម្រុះ

### ក-ការចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យសត្វព្រៃ

-បានចុះសិក្សាស្រាវជ្រាវ និងធ្វើការតាមដានវត្តមានសត្វព្រៃនៅខេត្តស្ទឹងត្រែង បន្ទាយមានជ័យ ព្រះវិហារ ដោយបានកត់ត្រានូវប្រភេទសត្វព្រៃសំខាន់ៗ សរុបចំនួន ៦១០ ប្រភេទ ក្នុងនោះមាន ថនិកសត្វចំនួន ១៥៥ប្រភេទ សត្វស្លាបចំនួន ៣៤១ប្រភេទ និងឧរង្គសត្វ ចំនួន១១៤ប្រភេទ។
















*ការចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យសត្វព្រៃនៅខេត្តស្ទឹងត្រែង បន្ទាយមានជ័យ និងខេត្តព្រះវិហារ*

-បានសហការជាមួយអង្គការដៃគូ FFI ចុះពិនិត្យម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន២៦គ្រឿងដែលបានបំពាក់សម្រាប់តាមដានកត្តាគំរាមកំហែងចំពោះសត្វព្រៃ និងសត្វដំរីនៅតំបន់ជួរភ្នំក្រវាញ ខេត្តកោះកុង និងតំបន់ភាគខាងត្បូង និងខាងកើតនៃឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈគិរីរម្យ ខេត្តកំពង់ស្ពឺ និង ខេត្តព្រះសីហនុ ដោយថតបានសត្វដំរីព្រៃចំនួន ៧២ក្បាល និងថនិកសត្វផ្សេងទៀតចំនួន ១១ប្រភេទ ត្រូវជា ៤២១ក្បាល មានដូចជាខ្លាឃ្មុំតូច០៧ក្បាល ឆ្មាដាវ០២ក្បាល ឆ្កែព្រៃ ០៥ក្បាល កាំប្រមា១០ក្បាល ប្រើស១០ក្បាល ឈ្លូស៣៣ក្បាល ស្វាត្រោស៤០ក្បាល សំពោចអុជខ្នង០១ក្បាល ក្តាន់ញៀង ០២ក្បាល ខ្ទីង ០១ក្បាល និងជ្រូកព្រៃ ៣១០ក្បាល។







-បានសហការជាមួយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងសាកលវិទ្យាល័យជាតិសឹង្ហបុរី ចុះប្រមូលសំណាក (ឈាម ទឹកមាត់ លាមក និងដាលិកា) ពីពពួកថនិកសត្វតូចៗ និងសត្វប្រចៀវ ចំនួន ១.៩៧២ សំណាក ត្រូវជា ១៨១ក្បាល ត្រូវជា ៣០ប្រភេទ ក្នុងនោះមានប្រចៀវចំនួន ២០ប្រភេទ ថនិកសត្វតូចៗ(កណ្តុរ និងសត្វកកេរ)ចំនួន១០ប្រភេទ ពី២៤ទីតាំង នៅក្នុងខេត្តកំពត ព្រះសីហនុ កោះកុង កំពង់ស្ពឺ តាកែវ មណ្ឌលគិរី និងខេត្តរតនគិរី។





*ការតម្លើងសំណាញ់ និងឧបករណ៍ ចាប់សម្លេងសត្វប្រចៀវ និងអង្គប់ចាប់ថនិកសត្វតូចៗ*




*សកម្មភាពប្រមូលសំណាកថនិកសត្វតូចៗ និងសត្វប្រចៀវ*

### ខ. ជម្លោះរវាងមនុស្ស និងសត្វព្រៃ

បានកត់ត្រាការបំផ្លាញដំណាំដោយសត្វដំរីចំនួន ១២ករណី ដែលបានកើតឡើងនៅទីកន្លែងផ្សេងៗគ្នាក្នុងខេត្តកំពង់ស្ពឺ ព្រះសីហនុ កោះកុង និងខេត្តពោធិ៍សាត់ ដោយសត្វដំរីបានជាន់បំផ្លាញដំណាំរបស់ប្រជាជនចំនួន ៤៨គ្រួសារ ដូចជាចេក២៨០ដើម និង៥០គុម្ព ដូងទើបដាំ ៦៣០ដើម ដំឡូងមី ១០រង ផ្លែស្វាយ ១៣,៥តោន កាច់មែកស្វាយអស់ ១៥៥ដើម ផ្លែខ្នុរ ២០ផ្លែ ផ្តួលលួសក្រឡា ១០០ម ទុយោទឹក ២០ម និងខ្ទមចាំចម្ការ ៦ម៉ែត្រការ៉េ។




*ការចែកកាំជ្រួចដើម្បីដុតបង្អើលសត្វដំរីព្រៃ*




*រូបភាពនៃការបំផ្លាញរបស់សត្វដំរីព្រៃ*

### គ. ការសិក្សាស្រាវជ្រាវរុក្ខជាតិអ័រគីដេ

បានចុះប្រមូលសំណាករុក្ខជាតិកេសរកូល (អ័រគីដេព្រៃ) នៅខេត្តស្ទឹងត្រែង មណ្ឌលគិរី កោះកុង និងខេត្តព្រះវិហារ ដោយប្រមូលសំណាករុក្ខជាតិកេសរកូល (អ័រគីដេព្រៃ)បានចំនួន ៤៧០សំណាក ត្រូវជា៣៦ប្រភេទ។ ក្រៅពីនោះក៏បានប្រមូលសំណាករុក្ខជាតិប្រភេទ Hoya Nepenthes Drosera និងប្រភេទMoss យកមកសិក្សាស្រាវជ្រាវ និងថែរក្សាតាមដានបន្តពីដំណុះពូជរុក្ខជាតិនេះ

ដែលវាមានផលប្រយោជន៍ដល់វដ្ដនៃការរស់របស់អ័រគីដេព្រៃនៅក្នុងសួនអ័រគីដេភ្នំពេញថ្មីនៃរដ្ឋបាលព្រៃឈើ។









*សកម្មភាពនៃការចុះប្រមូលសំណាកកេសរកូលព្រៃ ក្នុងព្រៃធម្មជាតិខេត្តកោះកុង ព្រះវិហារ និងខេត្តសៀមរាប*

**៣. ពង្រឹងការត្រួតពិនិត្យ ការចិញ្ចឹមសត្វព្រៃតាមគ្រួសារ កសិដ្ឋាន និងសួនសត្វ**

-បានចុះប្រមូលទិន្នន័យការចិញ្ចឹមសត្វត្រចៀកកាំជាលក្ខណៈគ្រួសារនៅខេត្តកំពត ព្រះសីហនុ កោះកុង កំពង់ចាម ត្បូងឃ្មុំ និងខេត្តសៀមរាប និងបានចុះផ្សព្វផ្សាយសេចក្ដីជូនដំណឹងចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ របស់រដ្ឋបាលព្រៃឈើ ស្ដីពី ការបំពេញបែបបទចុះបញ្ជីថែរក្សា ឬចិញ្ចឹមសត្វត្រចៀកកាំជាលក្ខណៈគ្រួសារ។

-បានផ្ដល់លិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ១៤ច្បាប់ ក្នុងនោះ ០៨ច្បាប់ សម្រាប់ការថែរក្សាសត្វត្រចៀកកាំ និង០៦ច្បាប់ សម្រាប់សត្វព្រៃប្រភេទផ្សេងទៀត ដែលមានទីតាំងស្ថិតនៅខេត្តមណ្ឌលគិរី ព្រៃវែង កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ តាកែវ សៀមរាប បន្ទាយមានជ័យ និងរាជធានីភ្នំពេញ។







*សកម្មភាពនៃការចុះបំពេញបែបបទអនុញ្ញាតចិញ្ចឹមសត្វត្រចៀកកាំជាលក្ខណៈគ្រួសារ*

## ការគ្រប់គ្រងឧទ្យានសួនសត្វ និងសង្គ្រោះថែរក្សាសត្វព្រៃ

មានគោលបំណងចូលរួមដើម្បីបង្កើនការគ្រប់គ្រងព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព។

**១- ការសង្គ្រោះ ព្យាបាល និងថែរក្សាសត្វព្រៃ**

- បានសង្គ្រោះសត្វថ្មីចំនួន**៣៦០**ក្បាល
- ព្យាបាលសត្វព្រៃបានចំនួន**១៣២**ក្បាល
- កំពុងថែរក្សាសត្វព្រៃចំនួន**១៥៧៥**ក្បាល (បក្សី ៥៣ ប្រភេទ ថនិកសត្វ៤១ប្រភេទ និង ល្មូន១៣ប្រភេទ)។















## ២- ការស្តារសត្វព្រៃឡើងវិញ

បានស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន **៣៥២**ក្បាល។ ដោយឡែកគម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិមានដូចខាងក្រោម៖

- ក្រុមល្បាតសហគមន៍ចំនួន៣០នាក់បានដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន០៥ គឺនៅអារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)
- ដោះលែងក្រពើភ្នំពូជសុទ្ធ២០ក្បាលទៅក្នុងដែនជម្រកធម្មជាតិនៅស្ទឹងខៀវ ខេត្តកោះកុង
- តាមដានប្រចាំឆ្នាំវត្តមានក្រពើភ្នំតាមវិធីសាស្ត្រពំនុះកាត់ទទឹងដែនជម្រកនៅតំបន់ឆាយរាប អូរសោម ស្ទឹងដាច់ ដំណាក់ភ្លុង ស្ទឹងអារ៉ែង ស្ទឹងខៀវ បានរកឃើញលាមកក្រពើភ្នំ៩៣ដុំ ដានជើង៤២កន្លែង និងឃើញក្រពើផ្ទាល់១២ក្បាល។
- តាមដានក្រពើភ្នំដែលបានដោះលែងឆ្នាំ២០១៨ តាមរយៈRadio tracking បានរកឃើញក្រពើភ្នំលែងចំនួន០៧ក្បាល និងស្នាមដាន០១កន្លែង។
- ចុះស្រាវជ្រាវក្រពើភ្នំនៅភូមិសាស្ត្រដែនជម្រកសត្វព្រៃស្រែពកបានរកឃើញលាមកក្រពើ១២ដុំ និងបានជួយហ្វឹកហ្វឺនមន្ត្រីបរិស្ថានលើការងារស្រាវជ្រាវក្រពើភ្នំចំនួន១២នាក់។



សកម្មភាពល្បាត និងតាមដានក្រពើភ្នំ នៅស្ទឹងអារ៉ែង ខេត្តកោះកុង



សកម្មភាពល្បាត និងតាមដានក្រពើភ្នំ នៅស្ទឹងអារ៉ែង ខេត្តកោះកុង

## ៣- ការជួសជុល និងថែទាំ

ជួសជុលផ្លូវ និងលប់សំបុកមាន់ផ្លូវក្រាលក្រួសក្រហម បានប្រវែង ១៣៩៦ម កាប់ឆ្ការអនាម័យព្រៃបានទំហំ ១២,៣៧ហិកតា ជួសជុលដំបូលរោងសម្រាប់ភ្ញៀវទេសចរ បានចំនួន ១០រោង។





សកម្មភាពជួសជុលផ្លូវ និងរោងសម្រាប់ភ្ញៀវទេសចរក្នុងឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ

# ការគ្រប់គ្រង និងអភិវឌ្ឍន៍ឧស្សាហកម្ម ព្រៃឈើ ពាណិជ្ជកម្ម និងសហប្រតិបត្តិការអន្តរជាតិ

## ១-ការងារឧស្សាហកម្មព្រៃឈើ

ចុះពិនិត្យសិក្សា និងវាយតម្លៃទីតាំងជាក់ស្តែងចំពោះ៖

-ស្នើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ០៦ កន្លែង

-ស្នើសុំបន្តសុពលភាពរោងម៉ាស៊ីនអារកែច្នៃឈើ ចំនួន ១៤កន្លែង

-ចុះសិក្សាអត្រាកែច្នៃឈើនៅក្នុងរោងម៉ាស៊ីនអារកែច្នៃឈើជូនក្រុមហ៊ុនចំនួន០៤។











## ២-ការងារពាណិជ្ជកម្មផលិតផលព្រៃឈើ

### ១-ការនាំចេញផល អនុផលព្រៃឈើ

-ក្រុមហ៊ុនចំនួន ០៦ ធ្វើការនាំចេញផលិតផលគ្រឿងសង្ហារិម វានទេវតា និងឈើកែច្នៃទៅក្រៅប្រទេសមានបរិមាណសរុបចំនួន១.២៧៣ម៣ (មួយពាន់ពីររយចិតសិបបីម៉ែត្រគ្រីគុណ និងជ័រទឹកចំនួន១០០តោន (មួយរយតោន)។

-បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន០៩ មានបរិមាណឈើកែច្នៃចំនួន ១.១០៧ម៣ (មួយពាន់មួយរយប្រាំពីរម៉ែត្រគ្រីគុណ) និងផលិតផល អនុផលព្រៃឈើកែច្នៃ ១១៦តោន (មួយរយដប់ប្រាំមួយតោន) ។

### ២-ការនាំចូលផល អនុផលព្រៃឈើ

-ក្រុមហ៊ុនចំនួន ០៣ ធ្វើការនាំចូលឈើអារកែច្នៃ (MDF Wood Panel និង CHANFUTA) មានបរិមាណឈើចំនួន ១.០០៩ម៣ (មួយពាន់ប្រាំបួនម៉ែត្រគ្រីគុណ)

-បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន០៣ មានបរិមាណឈើកែច្នៃចំនួន ១.១៩៦ម៣ (មួយពាន់មួយរយកៅសិបប្រាំមួយម៉ែត្រគ្រីគុណ)។













## ៣-ការងារឥណទានកាបូនព្រៃឈើ និងការប្រែប្រួលអាកាសធាតុ

ចូលរួមកិច្ចប្រជុំក្នុងប្រទេសចំនួន ០៨លើក និងសិក្ខាសាលាក្នុងប្រទេសចំនួន០៤លើក ដែលផ្តោតសំខាន់លើ៖

-ការប្រើប្រាស់ឧបករណ៍ប្រែប្រួលអាកាសធាតុផ្អែកលើប្រព័ន្ធព័ត៌មានភូមិសាស្ត្រសម្រាប់ជាជំនួយដល់ការសម្រេចចិត្ត (DSS Toolbox) សម្រាប់ការអភិវឌ្ឍបន្សាំតាមវិស័យកសិកម្មនៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ អ្នកចូលរួមសរុប ១៤រូប ដែលអញ្ជើញមកពីរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន អគ្គនាយកសុខភាពសត្វ និងផលិតកម្មសត្វ នាយកដ្ឋានផែនការ និងស្ថិតិ មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម (AIDOC) រដ្ឋបាលជលផល និងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មកម្ពុជា។

-រៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពី "ការប្រែប្រួលអាកាសធាតុ" នៅស្រុកសំឡូត ខេត្តបាត់ដំបង។ គោលបំណងនៃសិក្ខាសាលាបណ្តុះបណ្តាលគឺដើម្បីផ្តល់

ចំណេះដឹង និងចែករំលែកនូវបទពិសោធន៍ដែលពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុដល់សហគមន៍មូលដ្ឋាន។ សមាសភាពអញ្ជើញចូលរួមមាន ៖ អភិបាលរងស្រុកសំឡូត នាយផ្នែករដ្ឋបាលព្រៃឈើរតនមណ្ឌល មន្ត្រីរដ្ឋបាលព្រៃឈើរតនមណ្ឌល ប្រធានសហគមន៍ អនុប្រធានសហគមន៍ គណៈកម្មការសហគមន៍ ហិរញ្ញិកសហគមន៍ សមាជិក សមាជិកាសហគមន៍មកពី១១សហគមន៍ និងប្រជាពលរដ្ឋស្ថិតនៅស្រុកសំឡូត ខេត្តបាត់ដំបង សរុបចំនួន១០០នាក់។











## ៤-ការងារសហប្រតិបត្តិការអន្តរជាតិ

-បានសម្របសម្រួលទំនាក់ទំនងការងារ និងរៀបចំលិខិតជូនថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាលព្រៃឈើទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចូលរួមកិច្ចប្រជុំក្រៅប្រទេសចំនួន១៥លើក សិក្ខាសាលាក្រៅប្រទេសចំនួន០៧លើក សន្និសីទចំនួន០៥លើក ទស្សនកិច្ចសិក្សាចំនួន០១លើក និងវេទិកាក្រៅប្រទេសចំនួន ០១លើក ដែលមានមន្ត្រីសរុបចំនួន ៥៦នាក់។

- គម្រោងសហប្រតិបត្តិការក្នុងរដ្ឋបាលព្រៃឈើរួមមាន ៖

១-គម្រោង Promotion of forest rehabilitation in Cambodia and Vietnam through demonstration needs and improvement of seed supply system វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

២-គម្រោង Establishment of forest genetic areas for forest restoration in Cambodia អនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

៣-គម្រោង Landscape approach to sustainable management of forests in Prek Thnot watershed អនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

៤-គម្រោង Integrated Forest Ecosystem Management Planing and demonstration Project in Great Mekong Sub-region អនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

៥-គម្រោង Research and Development (R&D) of Cambodia Natural Fiber Composites for Industrial Application អនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

៦-គម្រោង Korea-Cambodia REDD+ Joint Project (KCRP) អនុវត្តដោយនាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ

៧-គម្រោង The establishment of Korea-Cambodia Natural Recreation Forest Model Phase I អនុវត្តដោយឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ

៨-គម្រោង Sustainable forest Management through REDD+ Mechanism in Kompong Thom អនុវត្តដោយនាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ

៩-គម្រោង Forest Restoration and Promotion of Sustainable Forest Use in Southeast Asia អនុវត្តដោយឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ

១០-គម្រោង Investigating the Risk of Human Disease from Parasites of Small Mammals and Buts អនុវត្តដោយនាយកដ្ឋានសត្វព្រៃ និងជីវចម្រុះ។




THE 22nd MEETING OF THE ASEAN SENIOR OFFICIALS ON FORESTRY AND RELATED MEETINGS
Makati City, Philippines, 15-20 July 2019




THE 22nd MEETING OF THE ASEAN WORKING GROUP ON FOREST PRODUCTS DEVELOPMENT
Makati City, Philippines, 15-16 July 2019




THE 20th ASOF INTERNATIONAL SEMINAR ON CURRENT INTERNATIONAL ISSUES AFFECTING FORESTRY AND FOREST PRODUCTS
Makati City, Philippines, 17 July 2019



THE 22nd MEETING OF THE ASEAN SENIOR OFFICIALS ON FORESTRY
Makati City, Philippines, 18-19 July 2019

# ការគ្រប់គ្រងធនធានព្រៃឈើដោយមាននិរន្តរភាព គាំទ្រដល់គោលដៅអភិវឌ្ឍដោយចីរភាព



ប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើមានតួនាទីផ្ដល់ជាអាហារ ទឹកស្អាត និងថាមពល ក៏ដូចជាផលិតផល និងសេវាកម្មផ្សេងៗ ដែលមានសារសំខាន់ចំពោះមនុស្សជាតិ រួមចំណែកចំពោះកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ កាត់បន្ថយ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ការប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាព និងការអភិរក្សជីវចម្រុះ នៅក្នុងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ទាមទារក្រមគោលនយោបាយ និងការរៀបចំលិខិតបទដ្ឋានច្បាប់ដែលមានសង្គតិភាព ពាក់ព័ន្ធនឹងវិស័យ និងក្រសួងស្ថាប័ន ផ្សេងៗរបស់រដ្ឋាភិបាល ការជំរុញលើកទឹកចិត្តខាងផ្នែកសេដ្ឋកិច្ចសង្គម ស្របតាមក្របខណ្ឌដែលមាន និងពង្រីកការចូលរួមពីអ្នកពាក់ព័ន្ធ ក៏ដូចជាការត្រួតពិនិត្យ និងការអនុវត្តដ៏មានប្រសិទ្ធិភាព។ ព្រៃឈើ ចូលរួមចំណែកយ៉ាងសំខាន់ដល់គ្រប់ទិដ្ឋភាពទាំង ១៧ នៃគោលដៅអភិវឌ្ឍដោយចីរភាពរបស់អង្គការសហប្រជាជាតិ។ មានភស្តុតាងដែលជាឧទាហរណ៍ ខ្លះស្ដីពីតួនាទីតំបន់ព្រៃឈើ ដែលរួមមានដូចខាងក្រោម៖

<u>ធានាសន្តិសុខស្បៀង និងបណ្ដាញសុវត្ថិភាព៖</u> ព្រៃឈើផ្ដល់ជា បណ្ដាញសុវត្ថិភាព និងធានាសន្តិសុខស្បៀងក្នុងពេលមាន តម្រូវការបន្ទាន់ ឬវិបត្តិផ្សេងៗ។

*គោលដៅទី២៖ បញ្ចប់ភាពស្រេកឃ្លាន សម្រេចបានសន្តិសុខស្បៀង និងអាហារូបត្ថម្ភដែលត្រូវបានធ្វើឲ្យប្រសើរ ឡើង និងជំរុញនិរន្តរភាពកសិកម្ម*




*គោលដៅទី៣៖ ធានាការរស់នៅមានសុខភាពល្អ និងលើកកម្ពស់សុខមាលភាពមនុស្សគ្រប់វ័យ*




<u>លើកកម្ពស់ជីវភាព ផ្ដល់មុខរបរ និងកាត់បន្ថយភាពក្រីក្រ៖</u> នៅពាសពេញពិភពលោក តំបន់ព្រៃឈើរួមចំណែកជាសំខាន់ដល់ការលើកស្ទួយជីវភាព និងកាត់បន្ថយភាពក្រីក្រ។

*គោលដៅទី១៖ បញ្ចប់ភាពក្រីក្រគ្រប់រូបភាព នៅគ្រប់កន្លែង*




*គោលដៅទី៨៖ជំរុញកត្តាដែលបណ្ដាល និងរក្សាបាននូវនិរន្តរភាពនៃកំណើនសេដ្ឋកិច្ច ការងារធ្វើពេញលេញ និងមានផលិតភាព និងផ្ដល់ការងារសមស្របសម្រាប់ទាំងអស់គ្នា*




<u>ថែរក្សាជីវចម្រុះ និងប្រព័ន្ធមជ្ឈដ្ឋានដីគោក៖</u> ព្រៃឈើមានសារសំខាន់ចំពោះការថែរក្សាជីវចម្រុះ និងគាំទ្រដំណើរការបរិស្ថាន។

*គោលដៅទី១៥៖ ការពារស្ដារឡើងវិញ និងជំរុញការប្រើប្រាស់ប្រព័ន្ធមជ្ឈដ្ឋានដីគោកដោយមាននិរន្តរភាព គ្រប់គ្រងព្រៃឈើដោយចីរភាព ប្រយុទ្ធប្រឆាំងនឹងវាលខ្សាច់ (រហោស្ថានកម្ម) បញ្ឈប់ និងការពារឱនភាពដីធ្លី ព្រមទាំងបញ្ឈប់ការបាត់បង់ជីវចម្រុះ*




<u>រក្សានិរន្តរភាពផលិតកម្ម៖</u> ព្រៃឈើគាំទ្រផលិតកម្មដែលមាននិរន្តរភាពសម្រាប់ផលិតផលកសិកម្ម និងបរិស្ថាន។

*គោលដៅទី២៖ បញ្ចប់ភាពស្រេកឃ្លាន សម្រេចបានសន្តិសុខស្បៀង និងអាហារូបត្ថម្ភដែលត្រូវបានធ្វើឲ្យប្រសើរឡើង និងជំរុញនិរន្តរភាពកសិកម្ម*




*គោលដៅទី១២៖ ធានាការប្រើប្រាស់ដោយមាននិរន្តរភាព និងរក្សាគំរូផលិតកម្ម*



<u>កំណើនសេដ្ឋកិច្ច៖</u> ផលិតផលព្រៃឈើរួមចំណែកដល់សេដ្ឋកិច្ចនៃប្រទេសជាច្រើន តាមរយៈការរួមចំណែកចំពោះកំណើនសេដ្ឋកិច្ច ចំណូល និងការវិនិយោគ។

*គោលដៅទី៨៖ ជម្រុញកត្តាដែលបណ្ដាលនិងរក្សាបាន នូវនិរន្តរភាពនៃ កំណើនសេដ្ឋកិច្ច ការងារធ្វើពេញលេញ និងមានផលិតភាព និងផ្ដល់ការងារសមស្របសម្រាប់ទាំងអស់គ្នា*




*គោលដៅទី៩៖ កសាងហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈធន់មាំជំរុញឧស្សាហូបនីយកម្មប្រកបដោយនិរន្តរភាព និងបញ្ចូលគ្នា និងជំរុញការកែច្នៃ*




<u>សមភាព និងបរិយាប័ន៖</u> កម្មសិទ្ធិសមូហភាពនៃធនធានព្រៃឈើ នៅក្នុងការអភិវឌ្ឍប្រទេសកំពុងក្លាយជាបញ្ហាដ៏សាមញ្ញ ដោយផ្ដល់លទ្ធភាពនៃការប្រើប្រាស់ និងសិទ្ធិដល់សហគមន៍មូលដ្ឋាន។

*គោលដៅទី១០៖ កាត់បន្ថយភាពរើសអើងក្នុងបណ្ដាប្រទេសមួយចំនួន*




*គោលដៅទី១៦៖ ជំរុញឲ្យមានសង្គមដែលមានការបង្រួបបង្រួម និងមានសុខសន្តិភាព សម្រាប់ការអភិវឌ្ឍដោយមាននិរន្តរភាព។ ផ្ដល់ភាពយុត្តិធម៌សម្រាប់ទាំងអស់គ្នា និងស្ថាបនាស្ថាប័នដែលមានការរួបរួមគ្នា ការទទួលខុសត្រូវ និងមានប្រសិទ្ធភាពនៅគ្រប់កម្រិត*




<u>ជំរុញការរៀបចំគោលនយោបាយ និងភាពជាដៃគូ៖</u> សូចនាករ និងទិន្នន័យស្ដីពីព្រៃឈើ និងចំនួនប្រជាជននៅជុំវិញតំបន់ព្រៃឈើ អាចផ្ដល់ជាព័ត៌មានតាមតម្រូវការយ៉ាងច្រើន ស្ដីពីជីវភាពសហគមន៍ និងភាពក្រីក្រ។

*គោលដៅទី១៧៖ ពង្រឹងមធ្យោបាយអនុវត្ត និងពង្រីកទំនាក់ទំនងភាពជាដៃគូជាសាកលសម្រាប់ការអភិវឌ្ឍដោយមាននិរន្តរភាព*




<u>លើកកម្ពស់ការអប់រំ៖</u> ព្រៃឈើផ្ដល់ជាសម្ភារសិក្សាយ៉ាងច្រើនសន្ធឹក ដោយលើកទឹកចិត្តការអប់រំផ្នែកបរិស្ថាន និងនិរន្តរភាព។

*គោលដៅទី៤៖ ធានាការអប់រំដែលមានគុណភាពដូចគ្នា និងបន្ស៊ីគ្នា ព្រមទាំងលើកកម្ពស់ឱកាសសិក្សាដ៏យូរអង្វែងសម្រាប់ទាំងអស់គ្នា*




<u>លើកកម្ពស់អាហារូបត្ថម្ភ និងសុខភាព៖</u> ព្រៃឈើផ្ដល់នូវអាហារដែលមានអាហាររូបត្ថម្ភខ្ពស់ ប្រូតេអ៊ីន និងរុក្ខជាតិឱសថ។

*គោលដៅទី២៖ បញ្ចប់ភាពស្រេកឃ្លាន សម្រេចបានសន្តិសុខស្បៀង និងអាហាររូបត្ថម្ភដែលត្រូវបានធ្វើឲ្យប្រសើរឡើង និងជំរុញនិរន្តរភាពកសិកម្ម*




*គោលដៅទី៣៖ ធានាការរស់នៅមានសុខភាពល្អ និងលើកកម្ពស់សុខមាលភាពមនុស្សគ្រប់វ័យ*




<u>ជំរុញសមភាពយេនឌ័រ៖</u> ការប្រើប្រាស់ និងថែរក្សាធនធានព្រៃឈើ គឺមានសារសំខាន់ណាស់ចំពោះការផ្ដល់អំណាចដល់ស្ត្រី និងសមភាពយេនឌ័រ។

*គោលដៅទី៥៖ សម្រេចបានសមភាពយេនឌ័រ និងផ្ដល់អំណាចដល់ស្ត្រីទាំងអស់*




<u>ជួយគាំទ្រនិរន្តរភាពទីក្រុង៖</u> ព្រៃឈើមិនត្រឹមតែគាំទ្រអ្នកនៅជនបទប៉ុណ្ណោះទេ ប៉ុន្តែជួយរក្សានិរន្តរភាពនៃប្រជាជនដែលរស់នៅក្នុង និងជុំវិញទីក្រុងផងដែរ។

*គោលដៅទី១១៖ ធ្វើឲ្យទីក្រុង និងតំបន់លំនៅដ្ឋានរបស់មនុស្សមានទំនាក់ទំនងគ្នា សុវត្ថិភាព ធនទ្រាំ និងនិរន្តរភាព*




<u>អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ៖</u> ព្រៃឈើផ្ដល់ផលិតផលសំខាន់ៗសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សង់ផ្ទះ និងអភិវឌ្ឍទីក្រុងដោយមាននិរន្តរភាព។

*គោលដៅទី៩៖ កសាងហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈធន់មាំ ជំរុញឧស្សាហូបនីយកម្មប្រកបដោយនិរន្តរភាព និងបញ្ចូលគ្នា និងជំរុញការកែច្នៃ*



<u>ទប់ស្កាត់ការប្រែប្រួលអាកាសធាតុ៖</u> ព្រៃឈើមានសារសំខាន់នៅក្នុងការការពារការបំភាយឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

*គោលដៅទី១៣៖ ចាត់វិធានការបន្ទាន់ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ*




<u>ធនធានទឹក៖</u> ព្រៃឈើដើរតួនាទីសំខាន់ក្នុងវដ្តទឹកជាសាកល និងការការពារធនធានទឹក។

*គោលដៅទី៦៖ ធានាភាពដែលអាចប្រើប្រាស់បាន និងការគ្រប់គ្រងដោយមាននិរន្តរភាពនៃធនធានទឹក និងអនាម័យសម្រាប់ទាំងអស់គ្នា*




<u>ថាមពល៖</u> ព្រៃឈើផ្ដល់ ឬគាំទ្រប្រភពធនធានកកើតឡើងវិញ ដោយរួមបញ្ចូលថាមពលវារីអគ្គិសនី ឈើ និងធ្យូង។

*គោលដៅទី៧៖ ធានាការប្រើប្រាស់ថាមពលទំនើប ដែលមាននិរន្តរភាព ជឿទុកចិត្ត និងអាចលៃលកបានសម្រាប់ ទាំងអស់គ្នា*



<u>ការពារធនធានជលផល៖</u> ព្រៃកោងកាង គាំទ្រប្រព័ន្ធមជ្ឈដ្ឋានតំបន់ឆ្នេរ ស្តុកទុកការបូនបៃតង និងការពារកុំឲ្យឡើងកម្រិតនីវ៉ូទឹកសមុទ្រ។

*គោលដៅទី១៤៖ អភិរក្ស និងប្រើប្រាស់ដោយចីរភាពនូវធនធានជលផល សមុទ្រ និងមហាសមុទ្រសម្រាប់ ការអភិវឌ្ឍដោយមាននិរន្តរភាព*




***រៀបចំដោយ លោក ឈាង ដានី លោក គឹម សុបុណ្យ លោកស្រី លឹម សុភាព លោក សាយ ស៊ីនលី លោក ប៉ាង ផានិត និង លោក ញ៉ាន ប៊ុនថន***









# ដំណើរការនៃការគ្រប់គ្រងទីជម្រាលស្ទឹងព្រែកត្នោត ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ

ដោយ៖ បណ្ឌិត សុខ ហេង បណ្ឌិត សូ ធា និងបណ្ឌិត Edward V. Maningo ឆ្នាំ២០១៩

បញ្ហា និងទំនាស់ក្នុងការប្រើប្រាស់ដីនៅក្នុងតំបន់ទីជម្រាលស្ទឹងព្រែកត្នោត មានសភាពកាន់តែតានតឹងឡើងជាមួយនឹងកំណើនប្រជាជននៅក្នុងតំបន់។ កង្វះខាតដីធ្លីបានបង្កឱ្យមានទំនាស់លើធនធានដីរីករាលដាល ហើយបានឈានទៅដល់ការទន្ទ្រានយកដីបន្ថែមដែលធ្វើឱ្យមានការប៉ះពាល់ដល់ដីដែលពីមុននេះមិនធ្លាប់ជាដីលំនៅដ្ឋាន ដូចជាតំបន់ដែនជម្រកសត្វព្រៃជាដើម។ វិធីសាស្ត្រនៃការរៀបចំផែនការតាមតំបន់ទេសភាព បានក្លាយជាវិធីសាស្ត្រពេញនិយមក្នុងចំណោមអ្នកគ្រប់គ្រងធនធានធម្មជាតិដោយសារវាជាមធ្យោបាយមួយប្រកបដោយប្រសិទ្ធភាពក្នុងការទប់ស្កាត់នឹងភាពរេចរឹលនៃធនធានធម្មជាតិ និងលើកកម្ពស់សេវាកម្មអេកូឡូស៊ី និងអត្ថប្រយោជន៍ខាងផ្នែកជីវចម្រុះ។ តំបន់ទេសភាពមានច្រើនប្រភេទខុសៗគ្នា ហើយក៏មាននិយមន័យខុសៗគ្នាដែរ អាស្រ័យទៅតាមគោលបំណង និងផលប្រយោជន៍របស់អ្នកប្រើប្រាស់។ តាមទស្សនៈបែបគ្រប់គ្រងគេគួរចាត់ទុកថា តំបន់ទេសភាពគឺផ្សំឡើងពីអន្តរកម្មនៃប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់មួយ ហើយនៅក្នុងនោះគឺមានអន្តរអំពើរវាងមនុស្សជាមួយនឹងបរិស្ថានដែលនៅជុំវិញខ្លួន។ ក្នុងតំបន់ទេសភាពនៃទីជម្រាលមួយអន្តរកម្មរវាងការប្រើប្រាស់ដីផ្សេងៗគ្នា អាចកត់សម្គាល់បានដោយងាយស្រួលដូចជា៖ ការហូរច្រោះដី និងមុខងារខាងជលសាស្ត្រគឺជាសូចនាករបង្ហាញអំពីសុខភាពដីនៅតំបន់ខ្ពង់រាបខាងលើ។ តំបន់ទីជម្រាលស្ទឹងព្រែកត្នោត រួមផ្សំដោយប្រព័ន្ធអេកូឡូស៊ីផ្សេងៗគ្នាដែលរាយប៉ាយដោយដុំៗដូចជាដំណុះព្រៃឈើដែលឋិតនៅដាច់ៗពីគ្នា លាយឡំជាមួយនឹងតំបន់អភិវឌ្ឍន៍កសិកម្មដែលនៅរាយប៉ាយត្រង់នេះបន្តិចត្រង់នោះបន្តិច។ ជាច្រើនឆ្នាំកន្លងមកហើយ ការធ្វើកសិកម្មបានប្រែក្លាយដែនព្រៃឈើដែលមានពណ៌បៃតងស្រស់ឱ្យទៅជាតំបន់ដែលគ្មានគម្របព្រៃដ៏ធំល្វឹងល្វើយ។ ការថយចុះយ៉ាងលឿននូវគម្របព្រៃឈើបណ្ដាលមកពីកង្វះខាតនូវការរៀបចំផែនការឲ្យបានសមស្រប ដោយសារមិនមានការធ្វើអត្តសញ្ញាណកម្មឱ្យបានច្បាស់លាស់អំពីតម្រូវការ និងភាពសមស្របនៃការប្រើប្រាស់ដីស្របទៅតាមលក្ខខណ្ឌនៃទីតាំងនីមួយៗ។






*បទបង្ហាញស្តីពីទស្សនទាននៃទីជម្រាលជូនដល់បណ្ដាភាគីពាក់ព័ន្ធក្នុងសិក្ខាសាលាពិគ្រោះយោបល់នៅខេត្តកំពង់ស្ពឺ*

ការធ្វើផែនការកម្រិតតំបន់ទេសភាពត្រូវបានទទួលការយកចិត្តទុកដាក់កាន់តែច្រើនឡើង ព្រោះថាការយល់ដឹងអំពីអន្តរកម្មរវាងប្រព័ន្ធអេកូឡូស៊ីនៅកម្រិតតំបន់ទេសភាពកាន់តែមានភាពស៊ីជម្រៅ។ សកម្មភាពដែលបង្កឡើងដោយភាគីពាក់ព័ន្ធណាមួយនឹងជះឥទ្ធិពលទៅដល់ផ្នែកផ្សេងទៀតនៃតំបន់ទេសភាព។ ឧទាហរណ៍ ការពង្រីកផ្ទៃដីកសិកម្មនឹងប៉ះពាល់ដល់តំបន់អមសងខាងផ្លូវទឹក ដែនជម្រកសត្វព្រៃ និងមច្ឆជាតិ។ ការធ្វើអាជីវកម្មឈើ បានបង្កើនល្បឿននៃការហូរច្រោះដី និងបង្កឱ្យមានជាកំណល្បាប់។ ការគ្រប់គ្រងព្រៃឈើត្រូវផ្ដោតការយកចិត្តទុកដាក់ទៅលើជីវភាពរបស់ប្រជាជននៅក្នុងតំបន់ដែលរស់នៅពឹងអាស្រ័យលើព្រៃឈើ។ ការបង្កើនផលិតផលដំណាំកសិកម្មនៅតំបន់ខ្ពង់រាបតាមរយៈការប្រើប្រាស់ជី ថ្នាំកម្ចាត់សត្វល្អិត ឬការកាប់ឆ្ការព្រៃ ត្រូវតែគិតគូរដល់សហគមន៍នេសាទ និងសហគមន៍ដែលរស់នៅផ្នែកខាងក្រោមនៃខ្សែទឹក ដែលអាចរងផលប៉ះពាល់ដោយកំណល្បាប់ និងកំណើនរំហូរលើផ្ទៃដី។

ការរៀបចំផែនការប្រើប្រាស់ដីផ្អែកលើតំបន់ទេសភាព ត្រូវតែគោរពគោលការណ៍ជាមូលដ្ឋានមួយ ដើម្បីឲ្យគ្រប់ភាគីពាក់ព័ន្ធទទួលយកបាន គឺថាត្រូវតែអនុលោមតាមបទដ្ឋានបច្ចេកទេសគោរពបរិបទសង្គម និងគោលនយោបាយដែលមានស្រាប់។ ភាពសមស្របតាមលក្ខណៈបច្ចេកទេសងាយស្រួលគោរពតាម ព្រោះថាបច្ចុប្បន្នយើងមានបច្ចេកទេសគូរផែនទី សមត្ថភាពបច្ចេកទេសដែលអាចគិតគូរអំពីលទ្ធភាពផ្ទុករបស់ទីជម្រាល សូចនាករអំពីលទ្ធភាពសេដ្ឋកិច្ច និងលក្ខខណ្ឌសមប្រកបរបស់ដី។ ផ្ទុយទៅវិញ គោលនយោបាយ និងបរិបទសង្គម គឺជាកត្តាដែលមានភាពស្មុគ្រស្មាញ (និងត្រូវពិភាក្សាក្នុងចំណុចខាងក្រោមជាបន្តបន្ទាប់)។ ក្នុងន័យនេះ ការរៀបចំផែនការគ្រប់គ្រងទីជម្រាល តម្រូវឱ្យមានការគាំទ្រពីបុគ្គលម្នាក់ៗតាមរយៈការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅគ្រប់ដំណាក់កាលនៃការរៀបចំផែនការគ្រប់គ្រងតំបន់ទីជម្រាល។ ក៏ប៉ុន្តែការកៀរគរឲ្យមានការចូលរួម គឺជាការលំបាកព្រោះជាទូទៅគេមិនអាចប្រមូលផ្ដុំបានគ្រប់ភាគីពាក់ព័ន្ធដែលអាចនឹងរងឥទ្ធិពលពីផែនការនេះទេ។ ប្រសិនបើមិនមានវិធីសាស្ត្រសមស្របនោះទេ ការខ្វែងគំនិតគ្នារវាងភាគីពាក់ព័ន្ធមួយចំនួននឹងកើតមានឡើង ហើយមិនអាចធ្វើការសម្រេចចិត្តរួមគ្នាមួយបានឡើយ។

លេខាធិការដ្ឋានបណ្ដាញអាស៊ីប៉ាស៊ីហ្វិកសម្រាប់ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព(APFNet)បានផ្ដល់មូលនិធិគាំទ្រដល់ការរៀបចំផែនការគ្រប់គ្រងតំបន់ទីជម្រាលស្ទឹងព្រែកត្នោត តាមរយៈកិច្ចពិភាក្សាពិគ្រោះយោបល់នៅឯថ្នាក់មូលដ្ឋាន។ ទីជម្រាលស្ទឹងព្រែកត្នោត ជាករណីបង្ហាញអំពីដំណើរការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងការបង្កើតនូវចក្ខុវិស័យរួមមួយបើទោះបីជាមានទំនាស់ផលប្រយោជន៍ក្តី។ ដំណើរការរៀបចំផែនការគ្រប់គ្រងតំបន់ទីជម្រាលស្ទឹងព្រែកត្នោតត្រូវបានបែងចែកតាមដំណាក់កាលដូចខាងក្រោមៈ ការរៀបចំគំរូប្លង់បែងចែកការប្រើប្រាស់ដីឲ្យអស់លទ្ធភាព ការគូរផែនទីប្រើប្រាស់ដី និងការរៀបចំផែនការគ្រប់គ្រងតំបន់ទីជម្រាលផ្អែកលើការបែងចែកការប្រើប្រាស់ដីដែលបានរៀបចំរួចហើយនោះ។

កិច្ចពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធ ត្រូវបានចាត់ទុកថាជាកត្តាគន្លឹះនៃដំណើរការរៀបចំផែនការគ្រប់គ្រងទីជម្រាល និងក៏ជាដំណើរការធ្វើឲ្យមានភាពស្របច្បាប់នៃផែនការនេះ។

## ការពិគ្រោះយោបល់ក្នុងដំណើរការរៀបចំផែនការ

គម្រោងទីជម្រាលស្ទឹងព្រែកត្នោតប្រើប្រាស់វិធីសាស្ត្រតាមដំណាក់កាលក្នុងការរៀបចំផែនទីបែងចែកការប្រើប្រាស់ដី និងផែនការគ្រប់គ្រងទីជម្រាល។ ជាដំបូងគម្រោងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយព័ត៌មានជាមួយនឹងភាគីពាក់ព័ន្ធ ដើម្បីពន្យល់អំពីទស្សនទាននៃការរៀបចំផែនការតាមតំបន់ទេសភាព និងកំណត់លក្ខណៈវិនិច្ឆ័យនៃការប្រើប្រាស់ដី។ កិច្ចពិភាក្សាពិគ្រោះយោបល់នេះឡើង ដើម្បីធានាថាលក្ខណៈវិនិច្ឆ័យនៃការប្រើប្រាស់ដីត្រូវបានកំណត់ដោយភាគីពាក់ព័ន្ធនៅឯមូលដ្ឋាន ហើយនេះក៏ជាផ្នែកមួយនៃការធ្វើឲ្យមានភាពស្របច្បាប់នៃដំណើរការរៀបចំផែនការ។




*ជំហានក្នុងការរៀបចំធ្វើផែនការគ្រប់គ្រងទីជម្រាលស្ទឹងព្រែកត្នោត*

ម៉្យាងទៀត កិច្ចពិភាក្សាពិគ្រោះយោបល់បានកំណត់ចក្ខុវិស័យ និងសេចក្តីរំពឹងទុកអំពីសេវាកម្មរបស់ទីជម្រាលដែលជាធាតុចូលយ៉ាងសំខាន់ក្នុងការធ្វើពង្រាងផែនការគ្រប់គ្រងទីជម្រាល និងការធ្វើសំណើវិធានការនានាដើម្បីកាត់បន្ថយការប្រើប្រាស់ដីមិនសមស្រប។ សិក្ខាសាលាពិគ្រោះយោបល់បានបង្ហាញថា ការឯកភាពគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធលើលក្ខណៈវិនិច្ឆ័យនៃការប្រើប្រាស់ដី និងការបែងចែកការប្រើប្រាស់ដី គឺពិតជាអាចធ្វើបានតាមរយៈការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់។

លោក **ទេព ណែម** ជាមេឃុំត្រពាំងជោរ នៃស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ យោងតាមប្រសាសន៍របស់គាត់ “ នៅក្នុងឃុំរបស់យើង យើងធ្លាប់បានចូលរួមក្នុងសិក្ខាសាលាជាច្រើនដងអំពីការធ្វើផែនការគ្រប់គ្រងតំបន់ទីជម្រាល។ យើងបានធ្វើផែនការគ្រប់គ្រងតំបន់ទីជម្រាល។ នៅក្នុងឃុំត្រពាំងជោរ មានអ្នកអភិវឌ្ឍន៍ផ្នែកកសិកម្មជាច្រើនដូចជាៈ ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច និងចម្ការដែលគ្រប់គ្រងដោយកសិករ។ សកម្មភាពរបស់ពួកគេបានធ្វើឱ្យផ្ទៃដីព្រៃឈើរបស់យើងមានការថយចុះ។ ការកាប់ឆ្ការព្រៃបង្កឱ្យមានការហូរច្រោះ ដីស្រទាប់លើជាពិសេសនៅរដូវវស្សាបង្កើតបានជាកំណកកំណរល្បាប់ដែលជាហេតុធ្វើឱ្យស្ទឹងទន្លេ បឹងកាន់តែរាក់ទៅៗ។ ផែនការប្រើប្រាស់ដីដែលជម្រុញឲ្យមានការគ្រប់គ្រងតំបន់ទីជម្រាលស្ទឹងព្រែកត្នោតប្រកបដោយប្រសិទ្ធភាព នឹងផ្តល់អត្ថប្រយោជន៍ដល់ឃុំត្រពាំងជោរ។ យើងរំពឹងទុកថាផែនការនេះនឹងជួយបង្កើនគម្របព្រៃឈើ និងដើមឈើហូបផ្លែ និងទប់ស្កាត់ការហូរច្រោះដី។ ផែនការនេះនឹងត្រួតពិនិត្យការដាំដុះមិនថាដោយក្រុមហ៊ុន ឬជាលក្ខណៈគ្រួសារ នៅលើតំបន់ជម្រាល កាត់បន្ថយការប្រើដី និងបង្កើនប្រាក់ចំណូលគ្រួសារ។ ឃុំរបស់យើងមានសេចក្តីរីករាយជាខ្លាំងក្នុងការសហការ និងគាំទ្រផែនការនេះ”។



*ការតាំងបង្ហាញព័ត៌មានក្នុងសិក្ខាសាលាពិគ្រោះយោបល់*



*ការពន្យល់អំពីការបែងចែកការប្រើប្រាស់ដីជូនដល់ភាគីពាក់ព័ន្ធក្នុងសិក្ខាសាលាពិគ្រោះយោបល់*

## គូសផែនទី និងធ្វើសេចក្តីព្រាង ផែនការគ្រប់គ្រងទីជម្រាល

គូសផែនទីបែងចែកការប្រើប្រាស់ដី ត្រូវបានចាប់ផ្តើមដំណើរការបន្ទាប់ពីមានការឯកភាពគ្នាអំពីទីតាំង និងលក្ខណៈវិនិច្ឆ័យរបស់តំបន់ប្រើប្រាស់ដីផ្សេងៗគ្នា។ ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ត្រូវបានប្រើសម្រាប់គូសផែនទីស្របតាមលក្ខណៈវិនិច្ឆ័យដែលកំណត់ដោយសិក្ខាកាមក្នុងអង្គសិក្ខាសាលា។ ផែនទីបែងចែកការប្រើប្រាស់ដីនេះ គឺជាធាតុចូលសំខាន់មួយរបស់ផែនការគ្រប់គ្រងទីជម្រាល។

## ការពិនិត្យសុពលភាព

សិក្ខាសាលាត្រួតពិនិត្យសុពលភាពត្រូវបានធ្វើឡើងនៅថ្នាក់ស្រុកចំនួនពីរលើក(ស្រុកឱរ៉ាល់ និងស្រុកភ្នំស្រួច) ដើម្បីទទួលមតិកែលម្អពីគ្រប់ភាគីពាក់ព័ន្ធទៅលើពង្រាងផែនការគ្រប់គ្រងទីជម្រាល។ ការត្រួតពិនិត្យសុពលភាពនៃផែនការគ្រប់គ្រងតំបន់ទីជម្រាលនៅថ្នាក់មូលដ្ឋាន គឺជាផ្នែកមួយដ៏សំខាន់នៃដំណើរការរៀបចំផែនការ។ គោលបំណងនៃសិក្ខាសាលាទាំងពីរនេះ គឺដើម្បីបញ្ជាក់ថា តើការរៀបចំនៃផែនការនេះឆ្លើយតបទៅនឹងបំណងប្រាថ្នា និងស្របតាមលក្ខណៈវិនិច្ឆ័យប្រើប្រាស់ដី ដែលបានកំណត់ដោយភាគីពាក់ព័ន្ធនៅក្នុងសិក្ខាសាលាលើកមុននោះដែរឬទេ។ អ្នកចូលរួមភាគច្រើនបានយល់ស្របលើការបែងចែកការប្រើប្រាស់ដីដែលបានរៀបចំនេះ។ ទោះជាយ៉ាងនេះក្តីក៏នៅមានការកែប្រែតិចតួចដែរដោយពួកគាត់ចង់ឱ្យមានការកំណត់ទីតាំងសម្រាប់តំបន់អេកូទេសចរណ៍។ ឆ្លើយតបនឹងសំណូមពរនេះតំបន់មួយចំនួនក្នុងទីជម្រាលត្រូវបានពិនិត្យ និងបែងចែកឡើងវិញសម្រាប់ការអភិរក្សដើម្បីឲ្យស្របនឹងគម្រោងអេកូទេសចរណ៍ដែលបានស្នើឡើង។ ផ្ទៃដីធ្វើកសិកម្មនានាដែលស្ថិតនៅក្នុងចង្កោមនៃតំបន់ដែលបានកំណត់ថាសម្រាប់អភិវឌ្ឍន៍អេកូទេសចរណ៍ ត្រូវបានផ្តល់ជាអនុសាសន៍ឲ្យធ្វើការគ្រប់គ្រងដីប្រកបដោយចីរភាពតាមរយៈការអនុវត្តកសិកម្មតាមបែបអភិរក្ស ដូចជាកសិ-រុក្ខកម្ម ឬកសិ-ទេសចរណ៍ជាដើម។ ជារួមគម្រោងបានបង្ហាញឲ្យឃើញថា នៅពេលដែលមានការឯកភាពគ្នាជាមុនក្នុងចំណោមភាគីពាក់ព័ន្ធលើលក្ខណៈវិនិច្ឆ័យនៃតំបន់ប្រើប្រាស់ដីនោះមតិជំទាស់មានតិចតួចបំផុតនៅពេលដែលលទ្ធផលនៃការបែងចែកតំបន់ប្រើប្រាស់ដីត្រូវបានផ្សព្វផ្សាយ។

## បញ្ហាប្រឈម

ដំណើររៀបចំធ្វើផែនការគ្រប់គ្រងតំបន់ទីជម្រាលបានបង្ហាញឱ្យឃើញពីប្រសិទ្ធភាពនៃវិធីសាស្ត្រដែលបាន

ប្រកាន់យកក្នុងការបែងចែកតំបន់ប្រើប្រាស់ដីដែលអាចទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធ។ បញ្ហាមួយចំនួនដែលបានលើកឡើងនិងធ្វើការដោះស្រាយរួចនៅក្នុងសិក្ខាសាលាមុនៗ ត្រូវបានលើកឡើងជាថ្មីម្តងទៀតនៅក្នុងសិក្ខាសាលាត្រួតពិនិត្យសុពលភាព ការណ៍នេះធ្វើឱ្យយើងអាចយល់បានថា សិក្ខាកាមមួយចំនួនមិនបានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់កន្លងមកទេ។ បណ្តាមន្ទីរអង្គភាពពាក់ព័ន្ធមួយចំនួនមិនបានបញ្ជូនតំណាងដែលបានចូលរួមក្នុងសិក្ខាសាលាលើកដំបូង តែបែរជាចាត់បញ្ជូនតំណាងផ្សេងទៀតដែលមិនទាន់មានការយល់ដឹងអំពីទស្សនទាន និងដំណើរការក្នុងការរៀបចំផែនការតាមបែបផែនទេសភាព។ បញ្ហានេះកើតមានជាទូទៅនៅពេលដែលកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធត្រូវបានធ្វើឡើងជាបន្តបន្ទាប់។ រាល់សំណួរ ឬការជំទាស់នានាត្រូវបានដោះស្រាយតាមរយៈការពន្យល់បកស្រាយនូវអ្វីដែលបានសម្រេចរួចហើយនៅក្នុងសិក្ខាសាលាមុនៗមក។

គម្រោងនេះបានបង្ហាញថាសិក្ខាសាលាពិគ្រោះយោបល់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ គឺជាសមាសភាគមួយយ៉ាងសំខាន់ក្នុងដំណើរការធ្វើផែនការគ្រប់គ្រងទីជម្រាល ដោយអនុលោមតាមបទដ្ឋានបច្ចេកទេស បរិបទសង្គម និងគោលនយោបាយដែលមានស្រាប់។ ការធ្វើផែនការគ្រប់គ្រងតំបន់ទេសភាពមួយ ដោយការកៀរគរឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធនានាដើម្បីដាក់ចេញនូវចក្ខុវិស័យរួមមួយសម្រាប់អនាគត គឺជារឿងដែលអាចធ្វើបាន ទោះបីជាមានការខ្វែងគំនិតគ្នាខ្លះអំពីគោលបំណង ឬផលប្រយោជន៍ក៏ដោយ។ បទពិសោធន៍កន្លងមកក៏បានបង្ហាញថាការធ្វើផែនការដោយមានការពិគ្រោះយោបល់មិនមែនជាដំណើរការដែលធ្វើតែម្តងហើយចប់រួចរាល់នោះទេ។ ការធ្វើឲ្យមានភាពស្របច្បាប់នូវការយល់ឃើញរបស់ភាគីពាក់ព័ន្ធនានា គឺជាដំណើរការដែលមានលក្ខណៈជាប្រព័ន្ធ និងយូរអង្វែង៕





*សមាជិកសហគមន៍នៅមូលដ្ឋានចូលរួមធ្វើលំហាត់ទាក់ទងនឹងការរៀបចំផែនការប្រើប្រាស់ដី*



# របៀបបណ្ដុះគ្រាប់ឬស្សី

ដោយលោក ឃៀង អៀងតិច

ប្រភព ៖ khmerna.com







ចំពោះបងប្អូនកសិករ ដែលចង់ដាំដើមឬស្សី មិនពិបាកបណ្ដុះកូនដាំនោះទេ។ ការបណ្ដុះកូនឬស្សី គឺងាយស្រួលជាទីបំផុត ដូច្នេះហើយទើបនៅព្រៃឬស្សី វាមានព្រៃក្រាស់ ដោយសារតែគ្រាប់របស់វាហើរតាមខ្យល់ទៅធ្លាក់នៅលើដី ពេលដែលមានភ្លៀងធ្លាក់សើមគ្រប់លក្ខខណ្ឌសមស្រប វានឹងដុះចេញជាកូនឬស្សី លូតលាស់ទៅជាដើមឬស្សី។



វិធីងាយៗដើម្បីបណ្ដុះគ្រាប់ឬស្សី លោកអ្នកគ្រាន់តែអនុវត្តដូចខាងក្រោម៖

-យកគ្រាប់ឬស្សីបកសំបក ឬស្រោមខាងក្រៅឲ្យអស់

-យកគ្រាប់ឬស្សីទៅដាក់ត្រាំទឹកឲ្យបាន១យប់

-ស្រង់យកគ្រាប់ឬស្សីដែលរីកធំបន្ទាប់ពីត្រាំទឹក ១យប់ យកវាទៅដាក់នៅលើក្រដាសជូតមាត់ ឬកន្សែងពោះគោ

-ផ្សើមទឹកឲ្យសើម ដាក់វាក្នុងប្រអប់បិទជិត រក្សាទុករយៈពេល៣ថ្ងៃវានឹងដុះឫស ហើយយើងអាចឆ្កឹះយកកូនឬស្សីទៅដាក់ផ្សាំក្នុងថង់ផ្សាំ ដែលមានដីលាយធ្យូងអង្កាមម៉ដ្ឋ។

-ថែទាំវាឲ្យធំកម្ពស់កន្លះម៉ែត្រ ចាំយកវាទៅដាក់ដាំក្នុងចម្ការ៕



# រុក្ខជាតិឱសថ

# ក្ធម្ព

# *Mirtagyna speciosa Korth,*

# RUBIACEAE

ក្ធម្ពមានឈ្មោះឡាតាំង *Mirtagyna speciosa Korth* ស្ថិតក្នុងអំបូរ RUBIACEAE។ ជារុក្ខជាតិឈើទំហំមធ្យម មានកម្ពស់ពី១០-១៥ម៉ែត្រ។ ស្លឹកទោល ទល់ទងរាងពងក្រពើ ឬពងក្រពើទ្រវែងបណ្ដោយ ១០-១៥ សង់ទីម៉ែត្រ ទទឹង ៦-៩ សង់ទីម៉ែត្រ មានកូនស្លឹក១គូដុះបញ្ច្រាស់ជាមួយទងស្លឹក។ ផ្កាកញ្ចុំ ផ្កាចេញនៅចុងមែកជាចង្កោមរាយ ផ្ការាងជាឆ្នុក ពេលរីកពណ៌លឿងខ្ចី ពេលជិតរោយពណ៌ត្នោត លឿងតិចៗ។ ផ្លែមូលៗ ប៉ុនចុងម្រាមដៃ។ វាច្រើនមានដុះនៅតំបន់ដីទំនាប មាត់បឹង ភ្លឺស្រែ។

## ការប្រើប្រាស់ជាឱសថ

**ផ្នែកប្រើប្រាស់ ៖** សម្បកដើម ស្លឹក ឫស យកប្រើបានគ្រប់រដូវ។

**ការព្យាបាល ៖**

-**ស្លឹក៖** ស្លឹកខ្ចីហាលស្ងួតកិនជាម្សៅ ឬស្ងោធ្វើជាថ្នាំ ជួយឲ្យពិសារបាយឆ្ងាញ់។ នៅថៃ ស្លឹកព្យាបាល មួល រាក ឈឺក្រពះ ប៉ុន្តែបើប្រើច្រើនលើសកម្រិតអាចបណ្ដាលឲ្យក្អួត និងរាក ។

-**សម្បក និងឫស៖** នៅឥណ្ឌា សម្បក និង ឫស ប្រើជាថ្នាំព្យាបាលគ្រុន ឈឺពោះ។

ប្រជាជនកម្ពុជាយើងនិយមប្រើសម្បកដើម ឬស្លឹកក្ធម្ព ព្យាបាលស្ត្រីទាស់កូនខ្ចី និងព្យាបាលគ្រុនចាញ់។

បញ្ជាក់៖ ថ្មីៗនេះគេទើបស្រាវជ្រាវរកឃើញនៅលើស្លឹកក្ធម្ព មានសារធាតុញៀនបំបាត់ឈឺចាប់(Narcotique drug)។បន្ទាប់ពីបានប្រើស្លឹកក្ធម្ព ធ្វើឲ្យមានកម្លាំងធ្វើការបានយូរជាងធម្មតា រីករាយសប្បាយម្នាក់ឯងអណ្ដែតអណ្ដូង។ ប៉ុន្តែការប្រើស្លឹកក្ធម្ពយូរពេកបណ្ដាលឲ្យហូបបាយមិនបានចុះទម្ងន់ ស្បែកស្ងួតពណ៌ប្រផេះ ក្នុងករណីខ្លះធ្វើឲ្យមានជំងឺសរសៃប្រសាទ។







ដោយលោក **ឃៀង អៀងតិច** រដ្ឋបាលព្រៃឈើ

*ឯកសារយោង៖ សៀវភៅ រុក្ខជាតិឱសថបុរាណខ្មែរ ភាគ១*



# គោលការណ៍អនុវត្តន៍ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីស្តារលទ្ធភាព និងបន្លាស់ទីសត្វទោច

ដោយលោក **វ័ន្ត ម៉ុនឡើន** ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ
ដីព្រៃ និងសត្វព្រៃ នៃរដ្ឋបាលព្រៃឈើ

អង្គការអភិរក្សសត្វព្រៃជាច្រើន មានគោលបំណងរួមគ្នាក្នុងការសម្របសម្រួលសកម្មភាពអភិរក្សសត្វទោចនៅទូទាំងពិភពលោក។ ដោយសារសត្វទោចកំពុងទទួលរងការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរ នៅទូទាំងតំបន់ដែលពួកគេរស់នៅ ដូច្នេះការបន្លាស់ទី ការស្តារឡើងវិញ ក៏ដូចជាការបង្កើតវត្តមាននឹងក្លាយជាសមាសធាតុដ៏សំខាន់ក្នុងកិច្ចការអភិរក្ស ។

កម្មវិធីស្តារលទ្ធភាពឡើងវិញ និងបន្លាស់ទីនេះ កំពុងប្រែក្លាយទៅជាសមាសធាតុមួយដែលកាន់តែសំខាន់សម្រាប់ផែនការសកម្មភាពអភិរក្ស ដើម្បីជួយដល់ពពួកសត្វដែលកំពុងទទួលរងការគម្រាមកំហែង។ ការបន្លាស់ទីនេះនឹងបកស្រាយអំពីបញ្ហាអភិរក្សទៅតាមកម្រិតខុសៗគ្នា ដោយទី១៖ ទោចដែលរក្សាទុកក្នុងតំបន់ហ៊ុមព័ទ្ធ ជាទូទៅ គឺជាសត្វទទួលរងគ្រោះពីការជួញដូរសត្វព្រៃខុសច្បាប់ដែលត្រូវបានចាប់យកមកពីក្នុងព្រៃ ទទួលបាននូវការជួយសង្គ្រោះ និងស្តារលទ្ធភាពឡើងវិញ និងបន្ទាប់មកក៏ត្រូវដោះលែងត្រឡប់ទៅក្នុងព្រៃវិញ ទី២៖ ដោះលែងទោចទៅក្នុងតំបន់ដែលសត្វប្រភេទនេះបានផុតពូជ ឬចំនួនពួកគេមិនអាចរស់នៅស្ថិតស្ថេរយូរអង្វែង ហេតុដូច្នេះហើយចាំបាច់ត្រូវបង្កើនចំនួននេះឡើងវិញ។ ខាងក្រោមនេះជាគោលការណ៍ណែនាំត្រូវបានបង្កើតឡើងដោយកិច្ចសហការរួមគ្នារវាងអង្គការអភិរក្សមួយចំនួនដែលធ្វើការងារពាក់ព័ន្ធនឹងការអភិរក្សអំបូរទោច។

## គោលការណ៍ចម្បង

គោលការណ៍បម្រុងគឺជាមធ្យោបាយដើម្បីធ្វើការសម្រេចចិត្តក្នុងការគ្រប់គ្រងហានិភ័យដែលបញ្ជាក់ពីគោលការណ៍ ឬវិធានការការពារ បើទោះជាមិនមានភាពប្រាកដប្រជាផ្នែកវិទ្យាសាស្ត្រអំពីថា តើឥទ្ធិពលដែលបង្កគ្រោះថ្នាក់នឹងកើតមានឡើង ឬយ៉ាងណាក៏ដោយ។ មធ្យោបាយមួយនេះគួរតែត្រូវបានទទួលយក នៅពេលធ្វើផែនការបន្លាស់ទីសត្វទោច មានបន្ទុកនៃភស្តុតាងមួយបង្ហាញថា បន្លាស់ទីមិនបង្កគ្រោះថ្នាក់ដល់សត្វទោច ដែលគម្រាមកំហែងដោយជំងឺឆ្លង ការបង្កកំណើតដោយមិនបានព្រៀងទុក ការរំខានហួសប្រមាណពីទោចដទៃ ការធ្វើឲ្យថប់អារម្មណ៍ ការប្រកួតប្រជែងរកចំណី និងផលប៉ះពាល់ផ្សេងទៀតនោះទេ។ បន្លាស់ទីក៏បង្កផលប៉ះពាល់ផងដែរទៅដល់ពពួកសត្វទោចដែលមានទៅទីតាំងនោះស្រាប់ក្នុងការទំនាក់ទំនងទៅកាន់សត្វទោចដទៃ ឬអាចប៉ះពាល់ដល់បូរណភាពអេកូឡូស៊ីនៃតំបន់ដែលពួកគេរស់នៅ។ ការអភិរក្សសត្វទោចឲ្យមានកំណើនស្ថិតស្ថេរនៅក្នុងព្រៃ គឺចាំបាច់ត្រូវទទួលយកចំណុចជាអាទិភាពចំពោះសុខមាលភាពនៃសត្វប្រភេទនេះនៅកន្លែងចិញ្ចឹម។



## តារាងពណ៌នាសង្ខេប

| និយមន័យ/ប្រភព | ពណ៌នាសង្ខេប |
|---|---|
| ការជួយសង្គ្រោះ | ការផ្លាស់ទីពពួកពានរព្រៃចេញពីស្ថានភាពគ្រោះថ្នាក់ ឬការដោះស្រាយជម្លោះរវាងមនុស្ស និង ពានរ ក្នុងគោលបំណងធ្វើឲ្យការរស់នៅរបស់ពួកគេប្រសើរឡើង។ |
| ការស្ដារលទ្ធភាពឡើងវិញ | ដំណើរការគ្រប់គ្រងសត្វទោចដែលបានផ្លាស់ទីជម្រក ឈើ រងរបួស ឬ កំព្រា ឲ្យទទួលបាននូវសុខភាពល្អ និងមានជំនាញឡើងវិញ វាទាមទារការបំពេញមុខងារជាធម្មតា និងរស់នៅដោយម្ចាស់ការលើខ្លួនឯង។ |
| បន្លាស់ទី | ការផ្លាស់ទីសត្វទោច ដែលត្រូវបានដោះលែងពីតំបន់មួយទៅកាន់តំបន់មួយផ្សេងទៀត។ |
| បន្លាស់ទីបែបអភិរក្ស | បន្លាស់ទីបែបអភិរក្សគឺជាការផ្លាស់ទី និងដោះលែងសត្វទោចដែលគោលដៅចម្បងគឺការអភិរក្សដ៏មានអត្ថប្រយោជន៍៖ គោលដៅនេះនឹងជួយធ្វើឲ្យកាន់តែប្រសើរឡើងនូវស្ថានភាពអភិរក្សប្រភេទសត្វដែលពាក់ព័ន្ធសំខាន់ៗនៅតាមតំបន់ ឬនៅទូទាំងពិភពលោក និង/ឬការស្ដារឡើងវិញនូវដំណើរការ ឬមុខងារនៃប្រព័ន្ធអេកូឡូស៊ីធម្មជាតិ។ |
| បន្លាស់ទីពីព្រៃមួយទៅព្រៃមួយ | ការចាប់សត្វទោចក្នុងគោលបំណងផ្លាស់ទីពីជម្រកធម្មជាតិមួយទៅជម្រកមួយផ្សេងទៀត។ |
| ការស្ដារកំណើនឡើងវិញ | បន្លាស់ទីទៅក្នុងតំបន់ដែលជាប្រភពជម្រកដើម និងរួមបញ្ចូលសកម្មភាពទាំងពីរនេះ៖ ការពង្រឹង និងការដោះលែង។ |
| ការពង្រឹង | ការផ្លាស់ទី និងការដោះលែងសត្វទោច (ទោចព្រៃ ឬទោចចិញ្ចឹម) ត្រឡប់ទៅកាន់ទីតាំងដែលមានទោចប្រភេទដូចគ្នារស់នៅ។ |
| ការដោះលែង | ជាការនាំយក និងដោះលែងសត្វទោចទៅកាន់ជម្រកដើមដែលពួកគេធ្លាប់រស់នៅពីមុន។ |
| ការដាក់បញ្ចូលអភិរក្ស | ការដាក់បញ្ចូល អភិរក្សគឺជាការផ្លាស់ទី និងដោះលែងសត្វទោចក្នុងគោលបំណងឲ្យពួកគេបានរស់នៅក្នុងទីជម្រកដើមរបស់ពួកគេវិញ។ |
| កំណៃប្រែប្រព័ន្ធអេកូឡូស៊ី | កំណៃប្រែប្រព័ន្ធអេកូឡូស៊ីគឺជាការផ្លាស់ទី និងដោះលែងសត្វទោចទៅកាន់ទីតាំងដើមរបស់ពួកគេ ដើម្បីដើរតួនាទីក្នុងប្រព័ន្ធអេកូឡូស៊ីជាក់លាក់មួយ។ |
| ការដោះលែងប្រកបដោយសុវត្ថិភាព | ការដោះលែងសត្វទោចចិញ្ចឹមនៅក្នុង ឬក្រៅទីតាំងដើមរបស់ពួកគេ ជាកន្លែងដែលមានភស្តុតាងចង្អុលបង្ហាញថាពួកគេនឹងរស់នៅប្រកបដោយសុវត្ថិភាព៕ |

### ការអភិរក្ស និងបន្លាស់ទីប្រកបដោយសុវត្ថិភាព

ដើម្បីធានាថាបន្លាស់ទីមានឥទ្ធិពលដល់ការអភិរក្សទោចដែលត្រូវបានធ្វើបន្លាស់ទីរួច គួរតែអាចរួមចំណែកពង្រឹងដល់ចំនួនសត្វព្រៃដែលមានស្រាប់ រួមចំណែកក្នុងការបង្កើតចំនួនសត្វព្រៃថ្មីនៅក្នុងតំបន់ភូមិសាស្ត្រដែលអំបូរទោចរស់នៅរួមចំណែកស្ដារដំណើរការឬមុខងារប្រព័ន្ធអេកូឡូស៊ីធម្មជាតិឡើងវិញ។ ឧទាហរណ៍ដូចជា ចំនួនសត្វដែលត្រូវបានធ្វើកំណើន ឬដោះលែងមិនអាចនៅស្ថិតស្ថេរយូរអង្វែងបានទេ។ ក្នុងឧទាហរណ៍មួយនេះ បន្លាស់ទី ឬការធានានូវចំនួនសត្វ អាចជាផ្នែកមួយនៃចំនួនដែលបានផ្លាស់ប្ដូរ ដែលវាសមស្រមដើម្បីធ្វើការបង្ហាញពីបញ្ហាដែលអាចផ្ដល់នូវផលចំណេញ។

## ការគ្រប់គ្រងបម្រែបម្រួលនៃចំនួន

វាត្រូវបានណែនាំជាពិសេសអំពីគម្រោងដែលផ្សារភ្ជាប់ទៅនឹងការបន្លាស់ទីសត្វទោច ដែលស្ថិតនៅក្នុងគោលគំនិតនៃការពិចារណាលើមធ្យោបាយគ្រប់គ្រងបម្រែបម្រួលនៃចំនួនសត្វទោច។ ប្រការនេះ តម្រូវឲ្យមានការគ្រប់គ្រងយ៉ាងសកម្មជាមួយស្ថាប័នផ្សេងក្នុងការផ្តល់ជម្រកដល់ទោចចិញ្ចឹមក្នុងប្រភេទតែមួយ និងក្រុមអ្នកគ្រប់គ្រងអភិរក្សជម្រកដើម ធ្វើការនៅក្នុងទីតាំងដែលមានទោចប្រភេទដូចគ្នារស់នៅ។ បណ្តាញការងារនេះ អនុញ្ញាតឲ្យការយល់ដឹងមានភាពកាន់តែច្បាស់លាស់ថែមទៀតចំពោះវិធីសាស្ត្រដែលសត្វទោចនីមួយៗអាចរួមចំណែកក្នុងលទ្ធផលអភិរក្សជារួមជាជាងគ្រាន់តែយកចិត្តទុកដាក់លើលទ្ធផលបន្លាស់ទីចំពោះគម្រោង និងទីតាំងនីមួយៗ។ គោលបំណងចុងក្រោយនៃមធ្យោបាយមួយនេះនឹងប្រែក្លាយជាការរួមបញ្ចូលគ្នារវាងលទ្ធផលអភិរក្សក្នុងទីតាំងដើម និងក្រៅទីតាំងដើមដើម្បីធ្វើឲ្យស្ថានភាពអភិរក្ស កាន់តែប្រសើរឡើង។

## ស្ថេរភាពនៃចំនួនសត្វទោច

ប្រសិនបើគោលបំណងនៃផែនការបន្លាស់ទីធ្វើឡើងដើម្បីបង្កើតចំនួនថ្មីមួយដូច្នេះ វាគឺមានសារសំខាន់ក្នុងការបញ្ជាក់ថានឹងមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីធានាចំនួនសត្វទាំងនោះអាចរស់នៅបានក្នុងលក្ខខណ្ឌបម្រែបម្រួលអាកាសធាតុផ្សេងៗ(ដូចជាគ្រោះធម្មជាតិ) និងអាចរក្សាប្រភេទខុសគ្នានៃហ្សែន មេបាបានយ៉ាងត្រឹមត្រូវ។ ថ្មីៗនេះ ការប៉ាន់ស្មានពីកំណើនថេរក្នុងកម្រិតតិចបំផុតមួយនៅក្នុងចំណោមសត្វទោចដែលបានដោះលែងគឺមិនអាចធ្វើទៅបាននោះទេ។ ប៉ុន្តែក្នុងកាលៈទេសៈនេះសត្វទោចនឹងមិនអាចទទួលយកនូវលក្ខខណ្ឌរស់នៅណាមួយក្នុងពេលតែមួយដើម្បីធ្វើឲ្យចំនួនពួកគេនៅថេរបាននោះទេ។ ការធ្វើឲ្យកំណើននៅថេរក្នុងកម្រិតទាបបំផុតមួយអាចសម្រេចទៅបានតាមរយៈក្រុមដែលបន្លាស់ទីដោយជោគជ័យ និង/ឬ ដំណើរការបង្កាត់ពូជតាមធម្មជាតិ និង/ឬ ការធានាបានថាចំនួននោះអាចជាផ្នែកនៃបម្រែបម្រួលចំនួនសត្វទោចទាំងអស់។

## ការរួមចំណែករបស់អាជ្ញាធរក្នុងតំបន់

ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការធ្វើបន្លាស់ទីដែលត្រូវបានស្នើសុំគឺមានសារសំខាន់ណាស់។ ផ្អែកលើស្ថានភាពនៃទីតាំងដោះលែងដែលបានជ្រើសរើស ការចូលរួមរបស់អាជ្ញាធរក្នុងតំបន់នឹងមានភាពខុសគ្នា។ ប៉ុន្តែកម្មវិធីបន្លាស់ទីនីមួយៗនឹងនៅតែទាមទារការអនុញ្ញាតពីភ្នាក់ងាររាជរដ្ឋាភិបាលដែលពាក់ព័ន្ធ។ គោលការណ៍របស់រាជរដ្ឋាភិបាលក្នុងការធ្វើបន្លាស់ទីអាចនឹងធ្វើឡើងខុសៗគ្នា ហើយវាពិតជាសំខាន់ ក្នុងការយកចិត្តទុកដាក់ទៅលើបញ្ញត្តិ និងច្បាប់ថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់ខេត្ត ដើម្បីធានានូវមូលដ្ឋានច្បាប់សម្រាប់ការធ្វើបន្លាស់ទី និងធានាបានថា ការអនុញ្ញាតដ៏សមស្របនឹងត្រូវបានផ្តល់ឲ្យជាអាទិភាពដើម្បីបន្តដំណើរការមួយនេះ (Beck, et al., 2007) ។

## ការប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដីធ្លី

អំណះអំណាងមួយចំនួនអំពីភាពអចិន្ត្រៃយ៍នៃទីតាំងដែលត្រូវបានជ្រើសរើសសម្រាប់គម្រោងបន្លាស់ទីគួរតែត្រូវបានទទួលយកមុននឹងការបន្លាស់ទីត្រូវបានធ្វើឡើងដើម្បីជៀសវាងការខ្វះខាតឱកាសសម្រាប់ការអភិរក្ស និងការខាតបង់ធនធានបន្តពូជ។ ផែនការប្រើប្រាស់ដីធ្លីដែលត្រូវបានស្នើនាពេលបច្ចុប្បន្នសម្រាប់ទីតាំងដោះលែងដែលត្រូវបានស្នើសុំគួរតែត្រូវបានសិក្សាស្រាវជ្រាវ និងពិភាក្សាជាមួយនឹងអាជ្ញាធរដែលពាក់ព័ន្ធ។ ទីតាំងដោះលែងមួយគួរតែអាចផ្តល់នូវទីជម្រកដែលមានសុវត្ថិភាពរយៈពេលវែងជាមួយនឹងសក្តានុពលដែលមានដែនកំណត់សម្រាប់ការកាត់បន្ថយទំហំការរុករានដី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ឬការផ្លាស់ប្តូរសំខាន់ៗនៅជុំវិញតំបន់ដោយសកម្មភាពទាំងនេះ។ ទោះយ៉ាងណាក៏ដោយ ការថែទាំប្រកបដោយស្តង់ដារត្រឹមត្រូវតម្រូវឲ្យទីតាំងដោះលែងដែលពុំមានការគាំទ្រណាមួយនោះត្រូវបានវាយតម្លៃយ៉ាងហ្មត់ចត់ជាមួយនឹងអំណះអំណាងសមហេតុផលចំពោះការការពាររយៈពេលវែង។

## ការវាយតម្លៃទីតាំងដោះលែង

ការជ្រើសរើសទីតាំងសមស្របមួយគឺជាគន្លឹះក្នុងការធ្វើផែនការបន្លាស់ទី (IUCN SSC 2013)។ កង្វះការថែទាំ

ប្រកបដោយស្តង់ដារក្នុងតំបន់នៃផែនការនេះអាចបង្ហាញលទ្ធផលបរាជ័យចំពោះគម្រោងដោយហេតុផលមួយចំនួន។ វាក៏អាចលេចចេញជាលទ្ធផលដែលបង្កការខូចខាតទៅដល់ឥទ្ធិពលនៃការអភិរក្សរយៈពេលវែងច្រើនជាងនោះចំពោះសត្វទោចនីមួយៗប្រសិនបើការបន្លាស់ទីត្រូវធ្វើឡើងចំពោះប្រភេទសត្វដែលមិនមានដើមកំណើតទៅតំបន់នោះ។

គេត្រូវផ្តោតទៅលើ៖

- ត្រូវបានការពារយ៉ាងត្រឹមត្រូវ ហើយការគម្រាមកំហែងត្រូវបានត្រួតពិនិត្យ ឬគ្រប់គ្រង
- មានទីជម្រកគ្រប់គ្រាន់តាមតម្រូវការតាមរដូវកាល និង
- មានទំហំធំល្មម ឬមានទំនាក់ទំនងសមស្របដើម្បីគាំទ្រដល់ចំនួនសត្វឲ្យនៅថេរ (ឬយុទ្ធសាស្ត្រគ្រប់គ្រងបម្រែបម្រួលចំនួនសត្វត្រូវបានបង្កើតឡើង)។

## ការស្តារលទ្ធភាពឡើងវិញ

### បញ្ហាជំងឺដង្កាត់

សត្វទោចចាំបាច់ត្រូវតែទទួលការធ្វើតេស្តព្យាបាលដែលជាផ្នែកដ៏សំខាន់មួយ ធ្វើឡើងនៅពេលមកដល់មជ្ឈមណ្ឌលជាលើកដំបូង និងអំឡុងពេលដែលពួកគេរស់នៅទីនោះដើម្បីធានាថា ជំងឺផ្សេងៗមិនត្រូវបានចម្លងទៅកាន់ទោចដទៃដែលនៅក្នុងទ្រុង ហើយក៏មិនមានឆ្លងទៅសត្វព្រៃដទៃទៀតតាមរយៈកម្មវិធីដោះលែងផងដែរ។ មិនមានទោចណាមួយគ្មានផ្ទុកនូវបាក់តេរី ឬប៉ារ៉ាសិតទាំងស្រុងនោះទេ និងដូចជាការវាយតម្លៃហានិភ័យនៃជំងឺនេះដែរ គួរតែធ្វើឡើងក្នុងដំណាក់កាលធ្វើផែនការ និងមានការពិនិត្យឡើងវិញម្តងហើយម្តងទៀត(IUCN/SSC 2013)។ ចំណុចដែលត្រូវអនុវត្តដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់៖

- មានទីតាំងពិនិត្យសុខភាពដាច់ដោយឡែក និងដាក់លាក់មួយសម្រាប់ការមកដល់ដំបូងរបស់សត្វ
- ជម្រកដាច់ដោយឡែកសម្រាប់ទោចដែលមានសុខភាពល្អរស់នៅរយៈពេលយូរ
- ជម្រកដាច់ដោយឡែកសម្រាប់ប្រភេទដែលបង្ហាញរោគសញ្ញានៃជំងឺ ឧទា.របេងTB វីរុសរីត្រូ ជាដើមដែលត្រូវកម្ចាត់ចេញពីសត្វទោចឲ្យទទួលបានសុខភាពល្អ និងចេញពីទីតាំងពិនិត្យសុខភាព
- ទំនាក់ទំនងជាមួយនឹងមនុស្សគួរតែរក្សានៅកម្រិតតិចតួចបំផុតដើម្បីបញ្ចៀសពីការឆ្លងជំងឺ។
- តម្រូវឲ្យប្រើស្រោមដៃ ម៉ាស់ និងណែនាំឲ្យមានវ៉ែនតាការពារ ស្បែកជើងកវែង និងធុងទឹកជម្រះ បាតជើងពីមេរោគឆ្លង ជាមធ្យោបាយការពារពីការឆ្លងជំងឺ ជាពិសេសគឺនៅទីតាំងពិនិត្យសុខភាព ឬក៏តំបន់ដែលមានសត្វទោចឈឺ។
- ជំងឺរបេងដែលជាញឹកញាប់កើតមានតែលើមនុស្សក្នុងតំបន់មួយចំនួន សត្វទោចក៏ត្រូវបានរកឃើញមានឆ្លងមេរោគនេះផងដែរ ហើយការពិនិត្យរកមេរោគនេះចំពោះបុគ្គលិកអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ការនិងគ្រប់គ្រងជំងឺមួយនេះដែរ។ បុគ្គលិកគួរតែត្រូវបានត្រួតពិនិត្យយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។ ក្នុងករណីសង្ស័យលើទោចណាមួយថាមានផ្ទុកវីរុសរបេងម៉ាស់វះកាត់ស្តង់ដារមិន អាចមានប្រសិទ្ធភាពក្នុងការបង្ការពីការស្រូបយកដំណក់សារធាតុចម្លងជំងឺរបេងតាមរយៈដង្ហើមបានទេ ព្រោះម៉ាស់ទាំងនោះមួយចំនួនរចនាឡើងដោយមិនអាចបិទបាំងមុខបានជិតល្អ និងមិនអាចចម្រោះដំណក់សារធាតុចម្លងជំងឺរបេងទុកដោយឡែកបាន។ ប៉ុន្តែត្រូវណែនាំឲ្យប្រើម៉ាស់ប្រភេទ N95 ជំនួសវិញ។
- បុគ្គលិកដែលមានទំនាក់ទំនងនឹងសត្វទោចគួរតែត្រូវបានត្រួតពិនិត្យសុខភាព និងព្យាបាលមេរោគឆ្លងឲ្យបានទាន់ពេលផងដែរ។ បុគ្គលិកដែលរកឃើញថាមានរោគសញ្ញានៃជំងឺណាមួយមិនគួរពាក់ព័ន្ធជាមួយនឹងសត្វទោច ឬបុគ្គលិកដទៃនោះទេ។ រោគសញ្ញាទាំងនោះរួមមានមិនត្រឹមតែរាករូស ឈឺពោះ មេរោគឆ្លងដោយទឹកនោម ជំងឺស្បែក ដំបៅបើក រោគសញ្ញាផ្លូវដង្ហើមនោះទេ នៅមានរោគសញ្ញាដទៃផ្សេងទៀតផងដែរ។
- កាកសំណល់ដែលអាចចម្លងមេរោគគួរតែទុកដាក់ឲ្យបានត្រឹមត្រូវ ដើម្បីធានាកុំឲ្យមានហានិភ័យនៃការឆ្លងរោគ។

### ការតុបតែងទ្រុងសមស្របតាមឥរិយាបថ

នៅក្នុងទ្រុង ឬតំបន់ហ៊ុមព័ទ្ធគួរតែផ្តល់នូវបរិស្ថានធម្មជាតិឲ្យបានគ្រប់គ្រាន់ដែលអាចឲ្យសត្វទោចបង្ហាញនូវឥរិយាបថតាមបែបធម្មជាតិរបស់ពួកគេបានច្រើនតាមដែលអាចធ្វើទៅបាន។ ដូច្នេះវាអាចធ្វើឲ្យការអង្កេតដែលគួរឲ្យជឿទុកចិត្តត្រូវបានធ្វើឡើង ដើម្បីឲ្យមានស្ថេរភាពដល់ការបន្លាស់ទីបែបអភិរក្ស។ វិធីសាស្ត្រជាក់ស្តែងដែលធ្វើឡើង

ភាគច្រើនគឺដាក់វត្ថុផ្សេងៗនៅក្នុងទ្រុង ឬ តំបន់ហ៊ុមព័ទ្ធ ដើម្បីឲ្យសត្វទោចតោង និងបញ្ចេញសកម្មភាពយ៉ាងមានលំនឹង ដូចជាមែកឈើ ខ្សែពួរ និងកង់សម្រាប់យោលជាដើម។ ការតុបតែង (Enrichment) ទាំងនោះមានការបំពាក់សម្ភារៈមួយចំនួនដែលជាលទ្ធផលនៃការប្រែប្រួលឥរិយាបថជាវិជ្ជមានរបស់អំបូរពានរួមមាន៖

- គ្រោងឫស្សីក្រាស់
- ដើមឈើដែលគ្មានឫស
- វត្ថុថ្មី / ប្លែក
- វត្ថុលេងជាប្រភេទអាហារ
- ទោង
- វត្ថុសម្រាប់កាន់ / តោង។ ល។

## ការជ្រើសរើសទោចដើម្បីដោះលែង

### ការពិនិត្យជំងឺ

ការគ្រប់គ្រងបសុព្យាបាល និងពិធីការដាក់នៅដាច់ដោយឡែកដែលមានមូលដ្ឋានត្រឹមត្រូវគួរតែត្រូវបានត្រួតពិនិត្យក្នុងដំណាក់កាលស្ដារលទ្ធភាពឡើងវិញជាមួយនឹងថ្នាំបង្ការ និងការពិនិត្យសុខភាពមុននឹងដោះលែង។ វិធីសាស្ត្រដែលល្អ បសុពេទ្យ អ្នកបច្ចេកទេសខាងបសុព្យាបាល ឬពេទ្យសត្វ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវមានការពាក់ព័ន្ធនៅក្នុងការជ្រើសយកសត្វនីមួយៗដែលសមស្រមសម្រាប់ធ្វើបន្លាស់ទី ឬដោះលែង។ ការចម្លងជំងឺទៅកាន់ក្រុមពានរដែលមាននៅតំបន់ដោះលែងតាមរយៈលទ្ធផលនៃការបន្លាស់ទី វាមានសក្ដានុពលក្នុងការធ្វើអាព្យាក្រិតភាពតម្លៃនៃការអភិរក្សរបស់កម្មវិធីនេះ ដែលបង្កជាហានិភ័យដល់ក្រុមសត្វប្រភេទដូចគ្នា និងសត្វដទៃផងដែរ។ ដោយទទួលស្គាល់ថាការយល់ដឹងរបស់ពួកយើងអំពីជំងឺដែលកើតចំពោះអំបូរសត្វទោច បើធៀបទៅគឺនៅមានកម្រិតទាបនៅឡើយ ពួកយើងត្រូវជឿជាក់ថា អំបូរពានរអាចចាត់ទុកដូចជាអាងស្ដុកទឹកមួយដែលអាចចម្លងមេរោគទៅមនុស្ស ឬផ្ទុយមកវិញ មនុស្សអាចចម្លងទៅពួកគេ។

ពិធីការធ្វើបសុព្យាបាលដែលបានកំណត់យ៉ាងច្បាស់លាស់ទាំងនោះ គួរតែត្រូវបានអនុវត្តទៅលើការបញ្ចប់ ឬអនុម័តលើការវិភាគអំពីហានិភ័យ។ ដោយសារតែពិធីការនេះអាចមានតម្លៃខ្ពស់ ហើយក្នុងករណីមួយចំនួនវាមានដំណើរការយូរផងនោះ ធាតុមួយនេះគួរតែត្រូវបានរួមបញ្ចូលទៅក្នុងផែនការបន្លាស់ទី និងការគ្រប់គ្រងហិរញ្ញវត្ថុ។ គោលការណ៍វិភាគអំពីហានិភ័យដូចជាការវិភាគ Stoplight Hazard Analysis ដែលបានគូសបង្ហាញខាងក្រោម គួរត្រូវបានប្រើប្រាស់ដើម្បីធានាថា ទោចដែលចាត់ទុកថាមានលក្ខខណ្ឌសមស្របសម្រាប់ធ្វើបន្លាស់ទី គឺមិនមានមេរោគបង្កជាជំងឺ ដែលផ្ដល់ជាហានិភ័យដល់ទោចដែលរស់នៅតំបន់នោះស្រាប់ ឬកាត់បន្ថយលទ្ធភាពដែលអាចរស់រានបានរបស់ទោចដែលត្រូវបានដោះលែងនោះទេ។

### ការវាយតម្លៃអំពីផ្លូវអារម្មណ៍ និងឥរិយាបថ

ទោចគួរតែត្រូវបានកំណត់ច្បាស់អំពីអាវៈយវៈ និងឥរិយាបថដែលសមស្របសម្រាប់ការដោះលែងជាអាទិភាព ដើម្បីផ្ទេរទៅកាន់តំបន់ហ៊ុមព័ទ្ធមួយដែលអាចឲ្យពួកគេបន្សាំទៅនឹងបរិយាកាសថ្មី។ ជាថ្មីម្ដងទៀត ពួកគេនឹងត្រូវបានកំណត់អំពីឥរិយាបថពួកគេក្នុងដំណាក់កាលមួយនេះដើម្បីប្រាកដថាពួកគេ អាចទទួលបានច្រកចេញពីទ្រុងដោះលែង និងត្រឡប់ទៅក្នុងព្រៃបានដោយសុវត្ថិភាព (Cheyne 2009b; Cheyne et al. 2008, 2012) ។

ការផ្ទេរទៅកាន់បរិស្ថានថ្មីអាចបង្ហាញនូវលទ្ធផលល្អក្នុងការកើតឡើងជាថ្មីម្ដងទៀតនៃឥរិយាបទអវិជ្ជមានដែលធ្លាប់បង្ហាញពីមុន ដូចជាការបន្លាស់ទីនៅលើដី ការផ្អាក ឬបញ្ឈប់នូវសម្លេងយំហៅគ្នា និងឥរិយាបថមិនប្រក្រតីផ្សេងទៀត(A.Ario, pers. comm. 2013)។ ឥរិយាបថទាំងនេះអាចកើតឡើងដោយសារតែភាពស្មុគស្មាញនៃអារម្មណ៍អាស្រ័យដោយមជ្ឈដ្ឋានរស់នៅថ្មី ប៉ុន្តែវាក៏អាចជាសញ្ញាណបង្ហាញនូវផលវិបាកមួយក្នុងការទទួលយកនូវមជ្ឈដ្ឋានថ្មី និងការវាយតម្លៃដែលគួរឲ្យប្រុងប្រយ័ត្នមួយ ដែលនឹងត្រូវធ្វើឡើងជាអាទិភាពសម្រាប់ការដោះលែង។

ទោចដែលត្រូវបានជ្រើសរើស ដើម្បីធ្វើការបន្លាស់ទីគួរតែបង្ហាញឥរិយាបទដែលចាំបាច់សម្រាប់ការរស់រាន និងបន្តពូជនៅក្នុងព្រៃ។ ឥរិយាបថទាំងនោះរួមមានការចាប់តោងយ៉ាងស្ទាត់ជំនាញ ចំណូលចិត្ត ប្រើប្រាស់(ចាប់តោង) ផ្នែកខាងលើនៃទ្រុង ចំណង់ចំណូលចិត្តចំពោះស្លឹកឈើ/ផ្លែឈើព្រៃ និងរក្សាការរួមរស់ ជាគូ(មួយនឹងមួយ) ជាវិជ្ជមាន (ឧ. សម្អិតសម្អាងខ្លួន លេង ច្រៀង និងពាក់គ្នា) (Cheyne et al. 2008, 2012; Smith 2010)។ សត្វទោចគួរតែមានសមត្ថភាពការពារខ្លួន និងគេចពីការគម្រាមកំហែង (ឧ. ការយំបន្ទរជាសម្លេងដាស់តឿនគ្នា ដើម្បីគេចចេញ

ពីសត្វកាចសាហាវ)។ ទោចទាំងនោះគួរតែជាទោចពេញវ័យ និងគ្រប់អាយុបង្កកំណើត ហើយពួកគេគួរតែជាផ្នែកមួយនៃគ្រួសារ ឬគូដែលមានចំណងស្និតរមួត ឬក៏ក្នុងករណីដោះលែង ពួកគេបានបង្ហាញនូវទំនាក់ទំនងសង្គមជាវិជ្ជមានជាមួយនឹងទោចផ្សេងទៀត។

សត្វទោចមិនគួរចំណាយពេល ឬផ្លាស់ទីនៅលើដីក្នុងទីតាំងហ៊ុមព័ទ្ធនោះទេ ដោយសារតែប្រការនេះទំនងជាអាចបង្កើននូវហានិភ័យក្នុងការប្រមាញ់ពីសត្វសាហាវ។ ទីតាំងហ៊ុមព័ទ្ធជារឿយៗ គួរតែត្រូវបានសង់ឡើងក្នុងមធ្យោបាយមួយដែលមិនលើកទឹកចិត្តដល់ឥរិយាបថបែបនេះ ហើយប្រសិនបើឥរិយាបថនេះ កើតមានបន្ទាប់ពីការដោះលែងវាគួរតែត្រូវបានគ្រប់គ្រងដោយប្រើវិធីបង្អាក់។ ទោចដែលនឹងត្រូវដោះលែង គួរតែទទួលបានរបបអាហារធម្មជាតិគ្រប់គ្រាន់ជាអាទិភាព ដើម្បីទទួលបានការដោះលែងសមស្របមួយ និងអាចកំណត់ដឹងនូវប្រភពទឹកបានច្បាស់។

## ការបន្លាស់ទីបែបអតិរេក្ស

### ការរៀបចំទីតាំងដោះលែង

ទីតាំងដោះលែងគួរតែត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ ដើម្បីសម្រួលដល់ការត្រួតពិនិត្យទោចដែលត្រូវបានដោះលែងបានល្អប្រសើរ។ ទីតាំងដោះលែងគួរតែមានភ្ជាប់នូវផែនទី និងការកំណត់ព្រំប្រទល់។ យោងតាមលក្ខខណ្ឌភូមិសាស្ត្រ ការសាងសង់ប្រព័ន្ធផ្លូវលំអាចតម្រូវឲ្យមានដើម្បីដំណើរការចេញចូលកាន់តែងាយស្រួលថែមទៀត និងជំរុញដល់ការកត់ត្រា និងទំនាក់ទំនងព័ត៌មានក្រោយពីដោះលែងកាន់តែមានភាព ត្រឹមត្រូវច្បាស់លាស់។ ហេដ្ឋារចនាសម្ព័ន្ធដែលនៅក្បែរមួយចំនួនក៏ជាតម្រូវការមួយដើម្បីសម្រួលដល់បុគ្គលិក ក៏ដូចជាដើម្បីតំណភ្ជាប់បណ្តាញអគ្គិសនី ទឹក និងប្រព័ន្ធទំនាក់ទំនង និង ទ្រុងបន្សាំសម្រាប់ទោចផងដែរ។

### ទ្រុងបន្សាំ

ទ្រុងបន្សាំប្រើក្នុងគោលបំណងអនុញ្ញាតឲ្យទោចទទួលដឹងពីបរិស្ថានថ្មី ក៏ដូចជាការវាយតម្លៃទៅលើឥទ្ធិពលជ្រៀតជ្រែកពីទោច ឬសត្វដទៃ។ ទ្រុងបន្សាំទាំងនោះគួរតែមានទំហំធំល្មម ដែលអាចឲ្យទោចសម្តែងនូវសកម្មភាពជាប្រក្រតី ហើយវាកាន់តែប្រសើរថែមទៀត ប្រសិនបើធំជាងទ្រុងពីមុនរបស់ពួកគេ ប៉ុន្តែជារឿយៗ វាមិនអាចធ្វើទៅបានដោយសារតែកត្តាភូមិសាស្ត្រនៃទីតាំងដោះលែង។ វាក៏សំខាន់ផងដែរ ប្រសិនបើទ្រុងមានទំហំធំល្មមដែលអាចសម្រួលដល់ការពន្យារដោះលែងដោយមិនបានព្រាងទុក។

ការផ្តើមឡើងនូវការយំបន្ទរជាប្រក្រតីគឺជាការចង្អុលបង្ហាញទូទៅថា ទោចទាំងនោះមានភាពសុខ ស្រួលផ្នែកអារម្មណ៍នៅក្នុងបរិស្ថានថ្មីរបស់ពួកគេ និងបង្ហាញនូវឥរិយាបថជាគន្លឹះផ្សេងទៀតដែលយើងចង់បាន បន្ទាប់មកការដោះលែងពីក្នុងទ្រុងបន្សាំនឹងត្រូវធ្វើឡើងយ៉ាងសមស្រប។ ការយំបន្ទរក៏នឹងជួយកំណត់ថាតើ ទោច ឬសត្វដទៃដែលរស់នៅក្បែរនោះទំនងជានឹងបង្ហាញពីការប្រកួតប្រជែងកំណត់ដែនដី ពេលដែល ទោចត្រូវបានដោះលែង ឬយ៉ាងណា។

## ការបន្លាស់ទី

បញ្ហាចោទខាងក្រោមមានប្រសិទ្ធភាពជាពិសេសចំពោះការបន្លាស់ទី ដែលត្រូវបានកំណត់យ៉ាងច្បាស់នៅទីនេះថាជាការចាប់ដោយគ្មានការព្រៀងទុក និងចលនាផ្លាស់ទីរបស់ទោចព្រៃពីជម្រកធម្មជាតិមួយទៅជម្រកមួយផ្សេងទៀត។ ការបន្លាស់ទីនេះដែរគាំទ្រដល់គោលការណ៍ណែនាំដែលត្រូវបានចុះបញ្ជីក្នុងឯកសារនេះពីមុន ឧទា. ការវាយតម្លៃកាពីតម្រាមកំហែង ទីតាំង និងជម្រក ការការពារ និងការត្រួតពិនិត្យក្រោយដោះលែង ប៉ុន្តែការចាប់យកទោចព្រៃចេញត្រូវធ្វើឡើងប្រកបដោយហេតុផលត្រឹមត្រូវគ្រប់គ្រាន់។ បន្ថែមពីនេះ កិច្ចខិតខំប្រឹងប្រែងទាំងអស់គួរតែត្រូវធ្វើឡើងដើម្បីបន្លាស់ទីក្រុមទោចទាំងមូលជាមួយគ្នា ជៀសវាងការរំខានដល់ការភ្ជាប់ទំនាក់ទំនងសង្គម និងការបង្កឲ្យថប់អារម្មណ៍បន្ថែម។

ផែនការបន្លាស់ទី ជាទូទៅត្រូវបានគេយកចិត្តទុកដាក់ខ្ពស់អាស្រ័យដោយធាតុពិតសត្វទោចទទួលរងការជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរពីការបាត់បង់គុណភាពព្រៃឈើ អាស្រ័យដោយធម្មជាតិនៃការរស់នៅលើដើមឈើរបស់ពួកគេ។ បញ្ហាដែលជះឥទ្ធិពលដល់សត្វទោចរួមមាន៖ ១-ការបាត់បង់ជម្រក (ឧទា.ដោយការកាប់ព្រៃឈើ) ២-ការរស់នៅដាច់ពីគេ

(ឧទា.ទោច/គ្រួសារទោចនៅជាប់នឹងដើមឈើតូចៗមួយចំនួន) ៣-ការបែកខ្ញែក៖ ទោចត្រូវបង្ខំចិត្តបន្លាស់ទីនៅលើដីផ្ទាល់ក្នុងការទៅដល់ព្រៃឈើនៅផ្នែកផ្សេងទៀត ដើម្បីស្វែងរកអាហារបានគ្រប់គ្រាន់ ដែលប្រការនេះធ្វើឲ្យពួកគេងាយទទួករងគ្រោះពីការប្រមាញ់របស់សត្វសាហាវ និងបង្កជាជម្លោះរវាងមនុស្ស និងទោច។ ការបែកខ្ញែកនេះក៏អាចនាំទៅរកហានិភ័យនៃការខ្វះចំណីអាហារគ្រប់គ្រាន់ ដែលអាចបង្កើនមេរោគ/បាក់តេរីបង្កជាជំងឺនៅក្នុងទីតាំងដែលមានមនុស្សរស់នៅ ហើយចំនួនទោចនឹងធ្លាក់ចុះរយៈពេលវែងមួយតាមរយៈចំនួនដ៏តិចតួច និងដំណើរការកើតឡើងដោយចៃដន្យ។

## ការត្រួតពិនិត្យក្រោយដោះលែង

### ការប្រមូលទិន្នន័យភ្លាមៗបន្ទាប់ពីការដោះលែង/ការបំពេញបន្ថែម

ទោចត្រូវបានកំណត់ទីតាំងបន្ទាប់ពីដោះលែងរួចដោយធ្វើការសិក្សាពីគំរូផ្លូវនៃដែនជម្រករបស់ពួកគេ និងតាមដានពួកគេទៅកាន់កន្លែងដែលអាចមើលឃើញពួកគេដេកនៅពេលយប់។ ការយំបន្ទរបស់ប្រភេទសត្វមួយចំនួនក៏អាចនឹងត្រូវបានប្រើដើម្បីប៉ាន់ស្មានពីកន្លែងដែលក្រុមទោចកំពុងស្ថិតនៅ ប៉ុន្តែទោចច្រើនគូមិនច្រៀងជារៀងរាល់ថ្ងៃនោះទេ ដូច្នេះវិធីសាស្ត្រមួយនេះគឺនៅមានកម្រិត។ (Brockelman and Ali 1987; Brockelman and Srikosamatara 1993; Cheyne et al. 2007; Hamard et al. 2010; Nijman and Menken B.J. 2005)។ ដោយសារតែទោចមានទម្លាប់យំបែបនេះ វាត្រូវបានគេរំពឹងថា ឆ្លងកាត់ពេលវេលាដ៏ខ្លីមួយ យើងអាចដឹងពីទីតាំងជ្រកកោន និងផ្លូវធ្វើដំណើរប្រចាំថ្ងៃនៃទោចដែលត្រូវបានដោះលែង។ ការត្រួតពិនិត្យក្រោយដោះលែងរួមបញ្ចូលនូវការប្រមូលទិន្នន័យអំពីឥរិយាបថ ដែនជម្រក អេកូឡូស៊ី ការភ្ជាប់ទំនាក់ទំនងរវាងពួកគេ និងអំពីអន្តរកម្មដែលទោចមានជាមួយនឹងទោច ឬសត្វដទៃនៅក្នុង តំបន់ដោះលែង ឧទា. ស្វា និងសត្វស្លាបជាដើម។





ទោចមុខដែលបានដោះលែងនៅព្រៃឧទ្យានអង្គរ និងបានផ្តល់កំណើតកូននៅទីនោះ

| យើងស្នើអនុវត្តន៍ការត្រួតពិនិត្យក្រោយដោះលែងក្នុងកម្រិតទាបបំផុតមួយតាមតារាងពេលវេលាខាងក្រោម៖ | | |
|---|---|---|
| **មធ្យោបាយ** | **រយៈពេល** | **កំណត់សម្គាល់** |
| ការអង្កេតមើលឥរិយាបថផ្ទាល់ | ៤ខែដំបូង | ផ្តល់ចំណីបន្ថែមក្នុងអំឡុងពេលនេះជាពិសេស។ ចំណីទាំងនេះនឹងត្រូវកាត់បន្ថយដើម្បីធានាថា ទោចអាចស្វែងរកចំណីបានគ្រប់គ្រាន់ដោយខ្លួនពួកគេផ្ទាល់នៅក្នុងទីតាំងដោះលែង។ |
| ទិន្នន័យអំពីទីតាំងនៃទោចក្នុងគូនីមួយៗ | ៥ទៅ១២ខែ | ការត្រួតពិនិត្យនឹងធ្វើឡើងកាន់តែញឹកញាប់ថែមទៀតនៅពេលដែលរដូវកាលមានការប្រែប្រួល ដើម្បីធានាបានថា ទោចទាំងនោះអាចស្វែងរកចំណីបានគ្រប់គ្រាប់ដែលអាចបញ្ជាក់បានតាមរយៈការពិនិត្យមើលផ្ទាល់ទៅលើលក្ខខណ្ឌដងខ្លួន៕ |

ទោចគួរត្រូវបានកំណត់ដឹងពីទីតាំងឲ្យបានញឹកញាប់តាមដែលអាចធ្វើទៅបាន ក្នុងរយៈពេលយ៉ាងហោចណាស់១ឆ្នាំ ឬរហូតដល់ពួកគេមានបទពិសោធន៍គ្រប់គ្រាន់រាល់គ្រប់រដូវកាលនៅក្នុងព្រៃ។ បន្ទាប់ពីនេះ ទីតាំងនោះនឹងត្រូវបានសិក្សាជាប្រចាំដើម្បីស្វែងយល់ពីទិសដៅ/ស្ថានភាពនៃចំនួនសត្វច្រើនឆ្នាំបន្តទៀត។ យើងកំណត់បានពីភាពជោគជ័យនៃការបន្លាស់ទី ដោយទោចក្នុងជំនាន់១អាចរស់រាន និងបង្កើតបានកូនមួយ ដែលកូនទោចនោះរស់នៅជាមួយម្តាយរហូតដល់ផ្តាច់ដោះ ដែលនេះគឺជាឱកាសរស់រាន និងបន្តពូជនៅ ក្នុងព្រៃមានលក្ខណៈដូចគ្នាទៅនឹងទោចដទៃ។ ដូច្នេះ ទិន្នន័យអំពីកូនទោចដែលកើតមក និងកំពុងរស់រាននេះ ក៏នឹងផ្តល់នូវព័ត៌មានពីភាពល្អប្រសើរនៃទោចដែលបានដោះលែង និងកំពុងតែលូតលាស់ធំធាត់ ជាជោគជ័យមួយដែលផ្តែកលើការបង្កើត ឬបង្កើនចំនួន ក៏ដូចជាភាគរយដែលទោចអាចរស់រានមានជីវិត។ ទន្ទឹមនឹងនោះ ភាពបរាជ័យក៏តែងតែកើតមានផងដែរ៕

### *ឯកសារយោង* References


Brockelman, W. Y., & Ali, R. (1987). Methods of surveying and sampling forest primate populations. In R. A. Mittermeier & R. W. Marsh (Eds.), *Primate Conservation in the tropical rainforest.* (pp. 23–62). New York: Alan Liss.

Brockelman, W. Y., & Srikosamatara, S. (1993). Estimation of Density of Gibbon Groups by Use of Loud Songs. *American Journal of Primatology*, *29*(1), 93–108.

Campbell, C. O., Cheyne, S. M., & Rawson, B. . (2015). *Best Practice Guidelines for the Rehabilitation and Translocation of Gibbons*. Gland, Switzerland.

Carlstead, K., Seidensticker, J. C., & Baldwin, R. (1991). Environmental enrichment for zoo bears. *Zoo Biology*, *10*, 3–16.

Chetry, D., Chetry, R., & Bhattacharjee, P. C. (2007). *Hoolock, The Ape of India*. Mariani, Assam, India: Gibbon Conservation Centre and Gibbon Wildlife Sanctuary.

Cheyne, S. M. (2005). Re-introduction of captive-raised gibbons in Central Kalimantan, Indonesia. *Reintroduction News*, *24*, 22–25.

Cheyne, S. M. (2009a). Challenges and Opportunities of Primate Rehabilitation – Gibbons as a Case Study. In K. A. I. Nekaris, V. Nijman, M. Bruford, J. Fa, & B. Godley (Eds.), *Primate Conservation: Measuring and mitigating trade in primates*. Endangered Species Research.

Cheyne, S. M. (2009b). The Role of Reintroduction in Gibbon Conservation: Opportunities and Challenges. In S. M. Lappan, D. L. Whittaker, & T. Geissmann (Eds.), *The Gibbons: New Perspectives on Small Ape Socioecology and Population Biology* (pp. 477–496). New York: Springer.

Cheyne, S. M., Campbell, C. O., & Payne, K. L. (2012). Proposed guidelines for gibbon rehabilitation and reintroduction. *International Zoo News*, *46*, 1–17.

Cheyne, S. M., Chivers, D. J., & Sugardjito, J. (2008). Biology and Behaviour of Released Gibbons. *Biodiversity and Conservation*, *17*, 1741–1751.

Cheyne, S. M., Thompson, C. J. H., Phillips, A. C., Hill, R. M. C., & Limin, S. H. (2007). Density and Population Estimate of Gibbons (Hylobates albibarbis) in the Sabangau Catchment, Central Kalimantan, Indonesia. *Primates*, *49*(1), 50–56. doi:DOI: 10.1007/s10329-007-0063-0

Dickie, L. A. (1994). *Environmental Enrichment in Captive Primates: a survey and review.* University of Cambridge, Cambridge.

Hamard, M. C. L., Cheyne, S. M., & Nijman, V. (2010). Vegetation correlates of gibbon density in the peat-swamp forest of the Sabangau catchment, Central Kalimantan, Indonesia. *American Journal of Primatology*, *72*(7), 607–616. doi:10.1002/ajp.20815

Hebert, P. L., & Bard, K. (2000). Orang-utan use of vertical space in an innovative habitat. *Zoo Biology*, *19*, 239–251.

IUCN/SSC. (2013). *Guidelines for Reintroductions and other Conservation Translocations* (Version 1.). Gland, Switzerland: IUCN Species Survival Commission.

Kleiman, D. G. (1989). Reintroduction of captive mammals for conservation: guidelines for reintroducing endangered animals into the wild. *Bioscience*, *39*, 152–161.

Komdeur, J., & Deerenberg, C. (1997). The importance of social behavior studies for conservation. In J. . Clemmons & R. Buchholz (Eds.), *Behavioral approaches to conservation in the wild* (pp. 262–277). Cambridge (UK): Cambridge University Press.

Nijman, V., & Menken B.J., S. (2005). Assessment of census techniques for estimating density and biomass of gibbons (Primates: Hylobatidae). *The Raffles Bulletin of Zoology*, *53*(1), 169–179.

Reinhardt, V., & Smith, M. D. (1988). PVC pipes effectively enrich the environment of caged rhesus macaques. *Laboratory Primate Newsletter*, *27*(3), 4–5.

Smith, J. (2010). Reintroducing Javan gibbons (Hylobates moloch): An assessment of behavioral preparedness. *The Gibbon's Voice*, *12*(1), 2–7.

# ៦ គោព្រៃ

**ដោយ ឃឿង អឿងតិច** ការិយាល័យផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ

គោព្រៃជាសត្វចតុប្បាទដែលត្រូវចាត់ចូលជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា តាមព្រះរាជក្រឹត្យលេខ នស.រកត/០៣០៥ / ១៤៩ ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកំណត់ប្រភេទសត្វ និងរុក្ខជាតិ ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា។ ឈ្មោះ **គោព្រៃ** ជាន័យដើម និងន័យត្រង់នៃភាសាជាតិខ្មែរតែម្តង ដែលប្រទេសនានាលើពិភពលោកសរសេរ និងហៅឈ្មោះសត្វនេះថា គោព្រៃ (Kouprey) ដូចសម្លេងហៅរបស់ខ្មែរ ហើយត្រូវបានសត្វវិទូអន្តរជាតិទទួលស្គាល់ និងដាក់នាមដូចៗគ្នា ទោះជាភាសាអង់គ្លេស អេស្ប៉ាញ និងបារាំង គឺប្រើ ពាក្យតែមួយ "Kouprey" ។ វាមានឈ្មោះវិទ្យាសាស្ត្រ "*Bos sauveli* " មានប្រវែងដងខ្លួនពី ២,១ - ២,៣ម៉ែត្រ មានកម្ពស់ពី ១,៧ - ១,៩ម៉ែត្រ និងទម្ងន់ពី ៧០០ - ៩០០គីឡូក្រាម។ គោព្រៃមានរូបរាងស្រដៀងនឹងទន្សោង មានប៊ូរ វែងធ្លាក់ចុះដល់ជង្គង់ និងហៀរស្ទើរតែដល់ដីចំពោះគោឈ្មោល។ ចាប់ពីជើងក្រោមជង្គង់ចុះមក មានពណ៌ស ឬប្រផេះ និងប្រផេះចាស់នៅពេលមានអាយុច្រើន។ ស្នែងគោព្រៃឈ្មោល និងញី មានលក្ខណៈប្លែកគ្នា ដោយស្នែងឈ្មោលធំជាង ដុះចេញកោងទៅមុខ និងងើបឡើងលើ ព្រមទាំងមានព្រុយចុងស្នែង។ ស្នែងគោព្រៃឈ្មោលស្ថិតឆ្ងាយពីមួយទៅមួយប្រវែងប្រហែល ៨០ស.ម ហើយចាប់ផ្តើមមានសំណាករលាត់ជាព្រុយចុងស្នែងនៅអាយុប្រហែលជា៣ឆ្នាំ។ ការដែលគោព្រៃឈ្មោលមានស្នែងសុទ្ធតែរលាត់ចុងបែបនេះព្រោះវាចូលចិត្តគាស់ដី និងត្រដុសដើមឈើបង្កើតជាទ្រង់ទ្រាយស្នែងយ៉ាងនេះ




ប្រភព៖ *Khmerload និង អត្ថបទស្រាវជ្រាវរបស់លោក លិ វុឌ្ឍី លោក ត្រី ម៉ៈផល រដ្ឋបាលព្រៃឈើ*

កម្រសត្វណាមានដូចវាណាស់។ ចំណែក ស្នែងញីដុះមកខាងមុខរាងងើបបន្តិច ហើយគួចរមួលឡើងលើ។







គោព្រៃរស់នៅច្រើនបំផុតតាមវាល និងព្រៃភ្នំនៅភាគខាងជើងប្រទេសកម្ពុជា វាត្រូវបានគេប្រទះឃើញជាលើកដំបូងនៅឆ្នាំ១៩៣៧។ គោព្រៃរស់នៅទួលទាបៗ

ដែលមានដើមឈើខ្លះ ហើយអាហារចម្បងរបស់វាគឺស្មៅ។ គោព្រៃជាសត្វចូលចិត្តភាពងងឹត វារកស៊ីតាមវាលនៅពេលយប់ ប៉ុន្តែនៅក្រោមដើមឈើនៅពេលថ្ងៃ។ ជាធម្មតា វារស់នៅជាហ្វូងប្រហែលជា២០ក្បាល ដែលមានមេគោ និងកូនគោ ប៉ុន្តែអាចមានគោព្រៃឈ្មោលដែរនៅរដូវក្ដៅ។



រូបចម្លាក់គោព្រៃ ឈ្មោល ញី និងកូន នៅច្រកផ្លូវចូលនៃឧទ្យានសួនសត្វ និង មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ



រូបចម្លាក់គោព្រៃ ឈ្មោល ញី ជានិមិត្តរូបសម្គាល់ខេត្តមណ្ឌលគិរី

គោព្រៃជាថនិកសត្វស្លូតរស់នៅជាហ្វូងៗ ដែលគេអាចឃើញមាននៅលាយជាមួយហ្វូងទន្សោង ខ្ទីង ឬ ប្រើស។ ជាសត្វវៀងវៃ រហ័សរហួន ឆាប់ភ្ញាក់ផ្អើលជាងប្រភេទសត្វក្នុងត្រកូលគោសាទិសដូចគ្នា ពូកែស្រង់ក្លិន និង គេចវេសចេញពីមនុស្ស។ វាមានកម្លាំងខ្លាំង ពូកែធន់នឹងកម្ដៅថ្ងៃ អត់ធន់នឹងចំណីអាហារដែលមានគុណភាពទាប និងធន់នឹងជំងឺគោឆ្កួត។

គេប៉ាន់ស្មានថា គោព្រៃមានតិចជាង២៥០ក្បាលនៅទូទាំងពិភពលោក។ ចំនួនដ៏ទាបនេះគឺបណ្ដាលមកពីគ្មានការហាមឃាត់ក្នុងការបរបាញ់របស់ទាហាន និងអ្នកស្រុក ការឆ្លងជំងឺពីសត្វស្រុក និងការបាត់បង់ជម្រក។ ក្រោយរបប ប៉ុល ពត គោព្រៃក៏ត្រូវហាមបរបាញ់ម្ដងទៀតតាមរយៈប្រកាសលេខ ៣៥៩ កសក,ប្រក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៩៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។





គោព្រៃដែលត្រូវបានគេបាញ់សម្លាប់

គោព្រៃជាសត្វកម្របំផុតដែល **ព្រះមហាវីរៈក្សត្រ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរម រតនកោដ្ឋ** បានកំណត់ និងប្រកាសថា ជាសត្វនៃនិមិត្តរូបនៃកម្ពុជា ក្នុងឆ្នាំ១៩៦៤។ សត្វនេះសំបូរជាងគេបំផុតនៅប្រទេសកម្ពុជាប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្នពិភពលោកបានចាត់ទុកថា ជាប្រភេទសត្វជិតផុតពូជបំផុត (Critical Endangered) ហើយបានចុះក្នុងបញ្ជីសៀវភៅក្រហម IUCN ផងដែរ។ បើទោះជាយ៉ាងណា គ្មានគោព្រៃណាត្រូវបានគេប្រទះឃើញក្រោយឆ្នាំ១៩៨៣ទេ ហើយនៅទសវត្សចុងក្រោយនេះ មានការរុករកសត្វនេះជាច្រើនដងតាមរយៈថ្មើរជើង ការដាក់ម៉ាស៊ីនថតស្វ័យប្រវត្តិ និងការហោះហើរជាដើម នៅតែមិនទទួលបានលទ្ធផលអ្វីទេ។ ដូច្នេះហើយទើបរបាយការណ៍របស់ IUCN នៅឆ្នាំ២០០៨ បានចាត់បញ្ចូលគោព្រៃថា កំពុងរងគ្រោះធ្ងន់ធ្ងរ (អាចផុតពូជ)។

គួររំលឹកថាគោព្រៃមួយក្បាលដែលគេបានចាប់ ហើយផ្ញើទៅសួនសត្វវ៉ាំងសែនណ៍ (Vincennes Zoo, Paris) ឯក្រុងប៉ារីស នៅឆ្នាំ១៩៣៧ បានស្លាប់នៅដើមសង្គ្រាមលោកលើកទី២។ គោព្រៃមួយក្បាលនោះហើយដែលត្រូវបានកំណត់ជាគម្រូប្រភេទ (Holotype) ដោយជីវវិទូបារាំង អាឈីល អឿរបាំង (Achille Urbain)។



គោព្រៃឈ្មោលក្មេងនៅសួនសត្វវ៉ាំងសេន ប៉ារីស ឆ្នាំ១៩៣៧

គោព្រៃជាទូទៅចាប់ផ្តើមបន្តពូជនៅរដូវក្តៅ ដែលគោព្រៃញីពរពោះរយៈពេលពី៨ទៅ៩ខែ ហើយកើតកូនម្តងបានតែមួយទេ។ គោព្រៃញីចាកចេញពីហ្វូងដើម្បីទៅបង្កើតកូននៅក្នុងព្រៃជ្រៅ ហើយនៅពេលដែលកូនគោព្រៃមានអាយុ១ខែ ទើបត្រលប់ចូលមករកហ្វូងវិញ។

តាមសំណេរអំពីសត្វសាស្ត្រដែលបោះពុម្ពពីការស្រាវជ្រាវដោយសាកលវិទ្យាល័យណតវេស្ទើន(Northwestern University, London) នៅទីក្រុងឡុងបានបញ្ជាក់ថា តាមការប្រៀបធៀបតម្រៀបរបស់មីតូកុងទ្រី(Mitochondrial Sequences)បានបង្ហាញថា គោព្រៃអាចជា អម្បូរបង្កាត់(Hybrid)រវាងគោធំ(Zebu)និងទន្សោង(Banteng)។ ក្រោយមក អ្នកនិពន្ធបានដកសេចក្តីសន្និដ្ឋាននេះចេញវិញ ដោយសារតែការរកឃើញនូវសំណល់ហ្វូស៊ីលលលាដ៏ក្បាលគោព្រៃដែលមានអាយុនៅចុងសម័យផ្លេស្តូសែន (Pleistocene) ឬក៏ដើមសម័យអូឡូសែន (Holocene) ដែលអាចឲ្យគេសន្និដ្ឋានបានថា គោព្រៃមិនមែនជាអម្បូរបង្កាត់នោះទេ។ បើយោងទៅតាមការវិភាគហ្សែន (Genetic Analysis) ជាច្រើនដងទៀតបានបង្ហាញថា គោព្រៃមិនមែនជាអម្បូរបង្កាត់ទេ។ មានលទ្ធភាពខ្លះដែលថា អម្បូរទី២ តែមានមាឌតូចជាងគោព្រៃរបស់សណ្តានគោព្រៃនៅរស់។

ដូច្នេះ *ចំណុចសំខាន់គឺ គោព្រៃគឺជាពូជដាច់ដោយឡែក ដែលមិនមែនជាពូជកូនកាត់ទេ ហើយក៏មិនមែនជាទន្សោង ឬខ្ទីងឡើយ។*



គោព្រៃឈ្មោល *Bos sauveli*



សត្វខ្ទីងឈ្មោល ( Gaur)



ហ្វូងសត្វខ្ទីងក្នុងព្រៃធម្មជាតិ ថតបានដោយ
ម៉ាស៊ីនថតស្វ័យប្រវត្តិក្នុងខេត្តព្រះវិហារ



ហ្វូងសត្វទន្សោងក្នុងព្រៃធម្មជាតិ

ក្រៅពីនេះ គោព្រៃក៏ត្រូវចរិកទុកនៅក្នុងបទចំរៀងប្រជាប្រិយរបស់ខ្មែរតាំងពីយូរយារណាស់មកហើយ ជាពិសេសបទចំរៀងដែលមានលក្ខណៈរៀបរាប់អំពីធម្មជាតិប្រដូចភាពសុខសាន្តនៃការរស់នៅរវាងមនុស្ស សត្វ និងធម្មជាតិ គឺតែមួយ។ ជាមួយគ្នានេះ រូបសំណាកគោព្រៃក៏ត្រូវបានដាក់ជាសញ្ញាសម្គាល់លើឯកសណ្ឋានស្ថាប័នរដ្ឋ គឺលើដៃអាវមន្ត្រីរាជការរដ្ឋបាលព្រៃឈើ តាមរយៈអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥ ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ។ ក្នុងនោះក៏មានក្រុមអ្នកច្នៃម៉ូតសម្លៀកបំពាក់ក៏បានយករូបភាពគោព្រៃទៅបោះពុម្ពលើសម្លៀកបំពាក់គេផងដែរ ហើយក៏មានក្រុមបាល់ទាត់ខ្មែរយើងក៏បានដាក់ឈ្មោះថា ក្រុមគោព្រៃកម្ពុជា ទៀតផង។





រូបសញ្ញាគោព្រៃ សត្វនិមិត្តសញ្ញាជាតិ សម្រាប់ដេរប៉ះ លើ
ដៃអាវខាងឆ្វេង នៃឯកសណ្ឋានរបស់មន្ត្រីរដ្ឋបាលព្រៃឈើ

## ពីនេះពីនោះ...

ឯកសារយោង៖ គេហទំព័រ Khmer Note & brightside

ដោយលោក ឃៀង អៀងតិច ការិយាល័យផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ

# វិធីសាស្ត្រក្នុងការយករួចខ្លួនពីការដេញប្រហារ ពីសត្វសាហាវទាំង ១២ ដែលអ្នកគួរតែចងចាំ

យើងសង្ឃឹមថាអ្នកនឹងមិនជួបសត្វតោដែលស្រេកឃ្លានហើយមិនត្រូវរត់ចេញពីសត្វរមាស ឬហែលចេញពីក្រពើ ឬក៏សត្វសាហាវផ្សេងៗទៀត ប៉ុន្តែប្រសិនបើវាកើតឡើងមែននោះ ជាការសំខាន់បំផុតដែលយើងចាំបាច់ត្រូវតែដឹងអំពីឥរិយាបថរបស់សត្វទាំងនោះ ដើម្បីរកវិធីសាស្ត្រសមស្របឲ្យបានត្រឹមត្រូវក្នុងការគេចខ្លួនឲ្យរួចជីវិត។

ខាងក្រោមនេះជាវិធីសាស្ត្រខ្លីៗមួយចំនួនដែលអ្នកគួរតែយល់ដឹង និងចងចាំ ដើម្បីត្រៀមលក្ខណៈជាមុនក្នុងការជួយសង្គ្រោះជីវិតរបស់អ្នក ប្រសិនបើអ្នកជួបហេតុការណ៍អាក្រក់ទាំងនោះ។

### ១.ត្រីឆ្លាម

រឿងដែលអ្នកគួរតែយល់ដឹងនោះគឺ ក្នុងចំណោមត្រីឆ្លាម១៥០ប្រភេទក្នុងសមុទ្រ គឺមានត្រឹមតែ ២០ប្រភេទប៉ុណ្ណោះដែលប្រហារមនុស្សជាចំណីរបស់វា ហើយអ្វីដែលគួរឲ្យអ្នកបារម្ភនោះគឺ ប្រសិនបើត្រីឆ្លាមមានបំណងដេញប្រហារអ្នកហើយ គឺអ្នកពិបាកនឹងរត់គេចផុតពីវាណាស់។ ហេតុនេះដើម្បីជាជំនួយខ្លះៗក្នុងការការពារខ្លួនពីការតាមប្រហាររបស់ត្រីឆ្លាម អ្នកគួរតែយល់ដឹងនូវចំនុចមួយចំនួន។ អ្នកគួរតែចៀសវាងបណ្តោយឲ្យឈាមហូរ ឬក៏បន្ទោរបង់នៅក្នុងទឹក ដែលជាប្រភពអាចឲ្យវាតាមរកអ្នកយ៉ាងងាយតាមរយៈការហិតក្លិន ទោះបីជាស្ថិតក្នុងចម្ងាយច្រើនគីឡូក្រាមក៏ដោយ។ ប្រសិនបើអ្នកជួបត្រីឆ្លាមភ្លាមៗ សូមកុំព្យាយាមហែលគេចបែរខ្នងពីវាដោយភ័យខ្លាច ដែលកាន់ធ្វើឲ្យខ្លួនកាន់តែគ្រោះថ្នាក់។ វិធីល្អអ្នកគួរតែហែលយឺតៗ ហើយក្នុងករណីដែលអ្នកគ្មានផ្លូវគេច សូមព្យាយាមវាយប្រហារទៅលើគ្រាប់ភ្នែក និងស្រកីរបស់វាដែលជាចំនុចខ្សោយរបស់ត្រីឆ្លាម។



## ២.កង់គូរូ




សត្វកង់គូរូ នឹងដេញប្រហារអ្នកនៅពេលដែលអ្នកឈ្លានពានទឹកដីវាតែប៉ុណ្ណោះ។ ក្នុងករណីនេះ អ្នកគួរតែព្យាយាមក្អក ឬបង្ហាញអាការៈធ្វើដូចជាមនុស្សឈឺ និងគេចឃើតៗ។ សូមកុំព្យាយាមបែរខ្នងរត់គេចពីវា ព្រោះសត្វកង់គូរូអាចហក់លោតបានក្នុងចម្ងាយឆ្ងាយ ហើយតាមទាន់អ្នកក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ។

## ៣.គោ




ប្រសិនបើអ្នកជួយនឹងសត្វគោ សូមកុំព្យាយាមរត់គេច។ អ្នកត្រូវព្យាយាមសម្លឹងមើលទៅក្នុងភ្នែករបស់វា និងព្យាយាមធ្វើយ៉ាងណាឲ្យខ្លួនរបស់អ្នកមានទំហំធំ ដូចជាការលើកដៃ ឬត្រដាងអាវក្រៅ។ ការធ្វើបែបនេះនឹងធ្វើឲ្យវាខ្សោយជាងអ្នក ហើយវាចៀសវាងមិនប្រយុទ្ធជាមួយទេ។ អ្នកអាចជ្រើសរើសយកការនិយាយជាមួយវា ដោយប្រើសម្លេងធំ ខ្លាំងៗ និងជឿជាក់ ដែលបញ្ជាក់ថា អ្នកមិនខ្លាចវាឡើយ។ ចំណុចនេះពិតជាពិបាកធ្វើណាស់ ព្រោះថា មនុស្សគ្រប់រូបបើជួបហេតុការណ៍នេះ ច្បាស់ជាភ័យព្រលឹងចុងសក់បាត់ទៅហើយ...។

## ៤.ដំរី




ដំរីជាសត្វមួយប្រភេទដែលមានភាពវៃឆ្លាត និងជាសត្វរួសរាយ។ ពួកវាដេញប្រហារលុះត្រាតែវាគិតថាអ្នកបង្កគ្រោះថ្នាក់ដល់កូនរបស់វាតែប៉ុណ្ណោះ ដែលភាគច្រើនគឺដំរីញីតែម្ដង។ ប្រសិនបើអ្នកជួបហេតុការណ៍នេះ ត្រូវយកចិត្តទុកដាក់លើកាយវិការរបស់វា។ ប្រសិនបើភ្លុក និងត្រចៀករបស់វាបះទៅក្រោយនោះមានន័យថាវាកំពុងតែខឹងនឹងអ្នក។ ក្នុងពេលដែលវាចាប់ផ្ដើមវាយប្រហារ សូមកុំរត់គេចត្រង់ៗ ជំនួសដោយការរត់ ត្រូវព្យាយាមរករបស់អ្វីមួយដែលអាចធ្វើជាខែលបាំងចន្លោះខ្លួនអ្នក និងសត្វដំរី ដែលអាចជាដើមឈើ ឬដុំថ្មធំៗជាដើម។

## ៥.រមាស



រមាសជាសត្វដែលមានការសម្លឹងអន់បំផុត ដែលជាហេតុធ្វើឲ្យវាឆាប់ភ័យ និងធ្វើការវាយប្រហារតបតទៅវិញ។ រមាសអាចបង្កើនល្បឿនជាង ៦០គីឡូម៉ែត្រក្នុងមួយម៉ោង ព្រមទាំងពិបាកនឹងរត់គេចពីវាបំផុត។ តែទោះជាយ៉ាងណាក៏មានវិធីខ្លះអាចជួយសង្គ្រោះបានដែរ។ វិធីតែមួយដែលអាចរត់គេចពីសត្វរមាសបានគឺមានតែលាក់ខ្លួនក្រោយដើមឈើតែប៉ុណ្ណោះ ដែលជាឧបសគ្គតែមួយគត់របស់រមាស។ អ្នកក៏អាចជ្រើសរើសយកការលាក់ខ្លួនក្នុងគម្ពោតព្រៃ ឬស្មៅក្រាស់ៗបានដែរ ព្រោះភ្នែកវាអន់ តូចៗ ព្រឹមៗ។

## ៦.ដំរីទឹក



សត្វប្រភេទនេះ មើលទៅហាក់ស្អាតស្លូតណាស់ តែទោះជាយ៉ាងណាក្តី អត្រានៃមនុស្សស្លាប់ដោយសារវាគឺខ្ពស់ជាងក្រពើទៅទៀត។ ទោះវាមានទម្ងន់ធ្ងន់ តែល្បឿនរបស់ដំរីទឹកអាចរត់បានរហូតដល់ ៣០គីឡូម៉ែត្រក្នុងមួយម៉ោងឯណោះ ហើយវាថែមទាំងឆាប់ខឹងទៀតផង។ ប្រសិនបើស្ថិតក្នុងអាកាសធាតុក្តៅ ចូរកុំព្យាយាមចូលទៅក្នុងរូងឈើ។ ក្នុងកំឡុងពេលគ្រោះរាំងស្ងួត ទឹកស្រក ដំរីទឹក តែងតែលាក់ខ្លួននៅក្នុងស្មៅខ្ពស់ៗ។ ដើម្បីកុំឲ្យដំរីទឹកដេញប្រហារ អ្នកគួរតែឡើងលើដើមឈើ ថ្មធំ ឬកន្លែងស្រួចៗ ហើយរង់ចាំនៅទីនោះរហូតដល់វាចាកចេញ។

៧.គោ




ទោះជាយ៉ាងណាក្តី សត្វគោមិនមែនត្រឹមតែដេញប្រហារអ្វីដែលមានពណ៌ក្រហម (ឬពណ៌ផ្សេងទៀត) នោះទេ តែវាប្រតិកម្មនឹងចលនាផងដែរ។ ហេតុនេះហើយបានជាគោតែងតែបោលទៅរកជល់អ្នក ដូច្នេះអ្នកត្រូវឈរឲ្យស្ងៀមស្ងាត់។ អ្នកគួរតែប្រើមួក អាវយឺត ឬក៏សម្លៀកបំពាក់ផ្សេងៗទៀតជានុយ ដោយរង់ចាំគោមកដល់ជិតដល់អ្នកត្រូវគប់របស់ទាំងនោះចេញពីអ្នកជានុយបញ្ឆោតវា ហើយវានឹងរត់ទៅតាមរបស់នោះជាមិនខាន។

៨.សារ៉ាយរមាស់




ព្រុយរបស់សារ៉ាយរមាស់គឺវែង និងអាចធ្វើឲ្យយើងចុកចាប់។ ដើម្បីទាញវាចេញ អ្នកអាចយកទឹកនោមចាក់ទៅលើព្រុយវា ហើយលាងខ្លួនដោយទឹកអំបិល។ ការប្រើទឹកសាបលាងនឹងធ្វើឲ្យស្ថានភាពឈឺចាប់កាន់តែធ្ងន់ធ្ងរ។ ប្រើជន្ទៀសដើម្បីចាប់យកផ្នែករបស់វាដែលនៅសេសសល់ចេញឲ្យអស់ ព្រមទាំងលាបក្រែមព្យាបាល។

## ៩.សត្វក្រពើ




ក្រពើជាសត្វមួយដែលមានថ្គាមរឹងមាំបំផុត។ ប្រសិនបើអ្នកត្រូវវាវាយប្រហារ គឺពិតជាមានការពិបាកក្នុងការរត់គេចណាស់។ វិធីល្អគឺត្រូវវាយចំភ្នែក និងបំពង់ក ដែលជាចំណុចខ្សោយរបស់វា ដើម្បីជាឱកាសគេចខ្លួនរបស់អ្នក។ ប្រសិនបើនៅលើគោកវាដេញតាមអ្នកនោះ ត្រូវរត់បត់បែនព្រមទាំងស្រែកខ្លាំងៗ។ តែក្នុងករណីនៅក្នុងទឹក សូមកុំព្យាយាមបញ្ចេញសម្លេង ហើយហែលគេចខ្លួនដោយស្ងាត់ៗបំផុត។

## ១០.ពស់




ពស់ភាគច្រើនគ្មានគ្រោះថ្នាក់ និងគ្មានពិសទេ។ មនុស្សប្រមាណជាង៨០% ដែលត្រូវពស់ចឹកគឺដោយសារតែពួកគេព្យាយាមចាប់វា ឬប៉ះពាល់វា។ ប្រសិនបើអ្នកចាប់អារម្មណ៍ថា ត្រូវពស់តាម សូមប៉ះអ្វីឲ្យញ័រៗ នោះវានឹងចាកចេញពីអ្នក។ ប្រសិនបើអ្នកត្រូវពស់ចឹក សូមកុំព្យាយាមបឺតពិសចេញពីមុខរបួសដូចដែលយើងឃើញនៅក្នុងខ្សែភាពយន្តឲ្យសោះ។ វាជាការល្អប្រសើរគឺលាងមុខរបួសជាមួយនឹងទឹកម៉ាស៊ីន រុំរបួស រឹតកៀបសរសៃឈាម និងទៅរកការសង្គ្រោះបន្ទាន់ពីគ្រូពេទ្យ។

## ១១. ស្វាធំ (Gorillas)



ស្វាធំ ត្រូវបានហៅថា ជាស្ដេចព្រៃ ដោយសារតែវាតែងតែការពារបងប្អូន និងតំបន់រស់នៅរបស់វា។ ស្វានេះនឹងមិនវាយប្រហារអ្នកទេប្រសិនបើអ្នកប្រព្រឹត្តល្អ តែក្នុងករណីដែលត្រូវប្រមាញ់ពីវាវិញនោះ អ្នកគួរតែអង្គុយចុះ ធ្វើខ្លួនឲ្យតូចបំផុត។ ព្យាយាមនិយាយខ្សឹបៗ និងគេចពីខ្សែភ្នែករបស់វា។ អ្នកអាចរមៀលដូចជាបាល់ ធ្វើខ្លួនឲ្យមើលទៅទន់ខ្សោយបំផុត ព្រោះស្វាធំជាសត្វដែលមានអំនួត វានឹងមិនធ្វើបាបអ្នកទន់ខ្សោយជាងវានោះទេ។

## ១២.ពពួកឃ្មុំ




ពពួកឃ្មុំនឹងការពារសំបុករបស់វា ហើយវានឹងទិចអ្នក បើទោះបីជាអ្នកគ្រាន់តែដើរកាត់ក៏ដោយ។ ពណ៌ស្រគាំគឺទាក់ទាញសត្វឃ្មុំជាពិសេស។ ដូច្នេះបើអ្នកពាក់អាវខ្មៅងងឹតនោះឱកាសនៃការផ្ដើលដោយសត្វឃ្មុំកាន់តែខ្ពស់។ ប្រសិនបើអ្នកត្រូវឃ្មុំដេញតាម ត្រូវព្យាយាមពួនក្នុងកន្លែងងងឹត។ កង្វះពន្លឺធ្វើឲ្យវាវង្វេងបានយ៉ាងងាយ។

ពពួកឃ្មុំមានច្រើនប្រភេទ ឃ្មុំខ្លះទិចគ្រាន់តែឈឺហើម ឯខ្លះទៀត ដូចជាឪម៉ាល់ជាដើម វាពិសខ្លាំងណាស់ បើទិចច្រើនអាចគ្រោះថ្នាក់ដល់ជីវិតផង៕




ដោយ ឃឿង អឿងតិច ការិយាល័យផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ

## ☺ យល់ខុស

*មានគ្រួសារមួយចូលចិត្តការសប្បាយ ច្រៀងរាំណាស់ ហើយបានពិភាក្សាគ្នារឿងរកប្រពន្ធឲ្យកូនប្រុស ដោយរកគ្រួសារណាមានចំណង់ចំណូលចិត្តដូចគ្នា។ ពួកគេរកបានដូចបំណងមែន គឺកូនក្រមុំគេផ្ទះជិតខាងគ្នា។*

*បន្ទាប់ពីរៀបការរួច កូនប្រុសទៅនៅខាងស្រី...*

**ប្ដី** ៖ អូនហេតុអីក៏ផ្ទះអូនឃើញតែឈ្លោះគ្នាស្រែកខ្លាំងៗ បង្កហិង្សាញឹកញាប់ម៉េះ? មុនការ បងឮសូរតែសប្បាយ ច្រៀងរាំតើ!

**ប្រពន្ធ** ៖ អូៗៗ ... សុំទោសបង! បែបបងយល់ច្រឡំហើយ ការដែលបងបានស្ដាប់ឮសំឡេងភ្លេងខ្លាំងៗនោះ មិនមែនកំពុងសប្បាយ ជប់លៀង ច្រៀងរាំអីនោះទេ គឺកំពុងផ្ទុះសង្គ្រាមបង្ករឈាមផ្ទៃក្នុង ហើយអូនអ្នកចាក់ភ្លេងបន្លំកុំឲ្យគេឮខ្មាសគេតើ ....!

**ប្ដី** ៖ អុញ !?!

## ☺ មនុស្សអស្ចារ្យ

មានកម្មវិធីប្រជុំបូកសរុបនៅក្នុងក្រុមហ៊ុនមួយ... ប្រធានផ្នែកបានបញ្ជាទៅលេខាខ្លួនថា បន្តិចទៀតនេះមានការប្រជុំធំក្នុងក្រុមហ៊ុនយើង ចឹងឯងត្រូវធ្វើរបាយការណ៍លម្អិតឲ្យទាន់ឲ្យខ្ញុំដើម្បីរាយការណ៍។ លេខាប្រកែកតវ៉ាថា *ធ្វើម៉េចទាន់? យ៉ាងតិចណាស់ក៏ប្រើពេលមួយថ្ងៃពេញដែរ ហេតុអ្វីមិនប្រាប់ខ្ញុំមុន?* ប្រធានផ្នែកគំរាមថា *ត្រូវធ្វើឲ្យទាន់ជាចាំបាច់ ហើយឯងនឹងក្លាយជាមនុស្សអស្ចារ្យ*។ ដល់ពេលប្រជុំលេខាហុចសឺមីមួយឲ្យប្រធានផ្នែក។ ប្រធានផ្នែកបើកមើលឃើញសុទ្ធតែក្រដាសសទទេរជិតដប់សន្លឹក ក៏ភ័យភ្នែកស្លី! រួចសួរទៅលេខា *ចុះហេតុអីក៏គ្មានអក្សរមួយតួចឹង?* លេខាឆ្លើយថា *អត់អក្សរហើយអាចអានកើតយ៉ាងត្រឹមត្រូវនោះទើបជាមនុស្សអស្ចារ្យ ហើយលោកជាមេខ្ញុំ ចឹងខ្ញុំមិនហ៊ានធ្វើជាមនុស្សអស្ចារ្យកាត់មុខកាត់មាត់មេទេទាន!*។

## ☺ ឡានទិញឆាញ់

ខ្ញុំជាក្មេងខិល ពូកែនិយាយច្រើនតែម្នាក់ឯង។ ថ្ងៃមួយខ្ញុំឡើងជិះឡានក្រុង ដោយអង្គុយពីក្រោយតែកុងឡាន។ ខ្ញុំនិយាយម្នាក់ឯងឥតឈប់ " *បើប៉ាខ្ញុំជាស្ដេច ម៉ាក់ខ្ញុំជាម្ចាស់ក្សត្រី នោះខ្ញុំ ជាព្រះរាជបុត្រា។ បើប៉ាម៉ាក់ខ្ញុំជាទេវតា ខ្ញុំគឺជាកូនទេវតា។ បើប៉ាម៉ាក់ខ្ញុំជាខ្លា ខ្ញុំជាកូនខ្លា...*"។ តៃកុងឡានធុញផង និងថ្លង់ផងក៏ស្រែកឡើងថា៖ "*ចុះបើឪឯងជាអ្នកប្រមឹក ហើយម៉ែឯងជាស្រីចោរម្សៀត តើឯងនឹងក្លាយជាស្អីទៅវិញ?*" ខ្ញុំឮក៏ឆ្លើយភ្លាមថា៖ "*ជាតៃកុងឡានក្រុង*"។

## ☺ ញើសផ្អើល

*ក្នុងអំឡុងខែឧសភា ឆ្នាំ២០១៩កន្លងទៅ ធាតុអាកាសក៏ក្ដៅ ភ្លើងក៏ដាច់ តាចឹមបែកញើសជោកខ្លួន ហើយគាត់ក៏ហៅចៅតេវរបស់គាត់ ឲ្យយកផ្លិតមកបក់ឲ្យគាត់....*

**តាចឹម៖** មើល៍ចៅតេវ! ចៅឯងយកផ្លិតមកបក់ឲ្យតាបន្តិច!

*មួយសន្ទុះក្រោយមក តាចឹម ក៏លាន់មាត់៖*

**តាចឹម៖** យីអម្បាញ់មិញឃើញញើសតាច្រើនណាស់ ឥឡូវបាត់ទៅណាអស់រលីង!

**ចៅតេវ៖** បាទលោកតា! អម្បាញ់មិញវាទំនៅលើខ្លួនលោកតា តែឥឡូវវាផ្អើលមកទំនៅលើខ្លួនចៅម្ដងហើយតា!

**តាចឹម៖** ហាក់ !?!?!?!?

## ☺ ពិសកូនប្រសារ

ពូប្រុញរើសកូនប្រសារជាមនុស្សភ្នែកប្រាក់ ព្រោះយល់ថា ជាមនុស្សល្អ ឆ្លាត និងនាំលាភ។ មុនរៀបការពូប្រុញចង់ទិញឡានសម្រាប់ជាចំណងដៃកូនទាំងពីរ គាត់បានហុចសៀវភៅរូបភាពម៉ូតឡានមួយទឹករបស់ហាងលក់ឡានមួយកន្លែងឲ្យអនាគតកូនប្រសាររើស។ បុរសភ្នែកប្រាក់បានមើលរូបឡានបញ្ច្រាស់បះកង់ឡើងលើ។ ពូប្រុញឆ្ងល់ក៏សួរថា ៖ *ហេតុអ្វីបានមើលបញ្ច្រាស់បះកង់ឡើងលើបែបនេះ?* បុរសភ្នែកប្រាក់ដែលតាមពិតគាត់ខ្វាក់មើលមិនឃើញផង ក៏ឆ្លើយដោះសារថា ៖ *បាទ! ខ្ញុំពិនិត្យមើលគ្រឿងក្រោម ខ្លាចពុកបាត ឬឡានកាត់ត ...*។ ពូប្រុញ ៖ *ប្រសើរណាស់កូនប្រសារខ្ញុំ ពិតជាឆ្លាត ម៉ត់ចត់មែន*៕



# ស្តាយស្រណោះ

(តចប់) បទកាកគតិ

ដោយលោក ឈិ ទុន្ស៊ី

ស្លួនកំណាព្យ







យើងថតរូបបាន គោព្រៃបុរាណ កាលឆ្នាំហាសិប(1950)
គោរស់ក្នុងព្រៃ យ៉ាងច្រើនរសិប រស់នៅនែបនិត្យ
ជាមួយទន្សោង ។

គោព្រៃមានច្រើន កាលនោះក្រអឺន ក្នុងស្រុកសំរោង
ចុងកាល់ជាំក្សាន និងឆែបយោងគោង ឃើញវាច្រើនម៉ោង
កោះញែក(ម)ណ្ឌលគីរី ។

តមកត្រសង ដល់ខ្លាដំបង ត្រូវបាញ់គ្រប់ទី
ថតបានចុងក្រោយ តែមួយ ឬពីរ ក្នុងព្រៃគីរី
ឆ្នាំពីរពាន់ប្រាំ ។

ក្រោយឆ្នាំនោះមក យើងបានប្រឹងរក រកជាប្រចាំ
រកគ្រប់កន្លែង រកដោយសកម្ម រកមកច្រើនឆ្នាំ
តែមិនឃើញសោះ ។

ហេតុនេះខ្ញុំស្តាយ ឱ! បងប្អូនអើយ ខ្ញុំស្តាយស្រណោះ
សត្វព្រៃនៅខ្មែរ ជាសត្វល្អស្រស់ បានបាត់ពូជអស់
រលស់ពីដី ។

សព្វថ្ងៃនេះសោត បញ្ហាក៏ចោទ ដល់សត្វដំរី
ខ្លាឃ្មុំខិន ប្រមាដែរអើ និងកែះផងក្តី
រងការគំរាម ។

ទោច និងរញ្ញី រស់តាមគីរី ន័យយប់ទីមទាម
ដោយសារព្រៃខើច និងព្រានស្វាព្រាម ឃើញខ្លែតចាប់ឆ្លាម
មិនមានអាសូ ។

បងប្អូនទាំងអស់ សូមជួយស្រណោះ សូមជួយការបួរ
បែរពីបាញ់សត្វ ការពារជាថ្នូរ ទុកព្រៃឲ្យពោរ
ពេញសត្វរស់នៅ ។៚

